លី.ធាមតេង

# អក្សរសាស្ត្រខ្មែរ



# LA LITTERATURE KHMERE

CA 37

បណ្ណាគារ សេង-ងួន-ហួត

# អក្សរសាស្ត្រខ្មែរ

# LA LITTERATURE KHMERE

លី-ធាមតេង

សមាជិកក្រុមអភិបាលសមាគមអ្នកនិពន្ធខ្មែរ

សាស្ត្រាចារ្យជំនួយខាងវិជ្ជាខ្មែរនៅមធ្យមសិក្សា

រៀបរៀង

បោះពុម្ពលើកទី២

បណ្ណាគារ

លេខ ៦៣ វិថីព្រះបាទបន្ទាយ ភ្នំពេញ

រក្សាសិទ្ធិ

ព.ស. ២៥០៣ ★ គ.ស. ១៩៦០

សូមឧទ្ទិស

ស្នាដៃនេះជូនដល់វិញ្ញាណក្ខន្ធ

កវី និងអ្នកនិពន្ធ

**ដែលបានឃ្លាតទៅកាន់បរលោកនាៗ**



# សេចក្ដីផ្ដើម

ដើម្បីប្រសិនជាគេយកពាក្យ "អក្សរសាស្ត្រ" ក្នុងន័យដ៏ទូលំទូ
មកអភិប្រាយ គេនឹងអាចនាំបញ្ចូលក្នុងពាក្យនេះនូវផ្ទាំងសិលាចារិក
ណាទាំងឡាយដែលជាមូលដ្ឋានដំបូងបង្អស់ នៃទំព័រអក្សរសាស្ត្រខេមរៈ
ផ្ទាំងសិលាចារិកខ្មែរដែលមានអាយុចាស់ជាងគេបំផុត ហើយស
ជាភាសាសំស្ក្រឹតគឺ សិលាចារិក វ៉ូកាញ់ ដែលគេរកឃើញនៅកម្ពុជា
ក្រោម ។ ផ្ទាំងសិលាចារិកនេះ បានត្រូវបុព្វបុរសខ្មែរចារទុកឡើង
ពាក់កណ្ដាលសតវត្សទី ៣ នៃគ្រឹស្តសករាជ។ ម៉្យាងទៀតគួរសំគាល់ថា
ចាប់ពីដើមសតវត្សទី ៧ នៃគ្រឹស្តសករាជ ខ្មែរយើងបានប្រើភាសាសំស្ក្រឹ
ជាមួយភាសាខ្មែរសមញ្ញរួមគ្នាក្នុងផ្ទាំងសិលាចារិកនានា ដើម្បីកត់ត្រ
នូវព្រឹត្តិការណ៍សំខាន់ៗដែលទាក់ទង និងប្រវត្តិសាស្ត្រប្រចាំជាតិរបស់
ចំពោះសិលាចារិកទាំងអស់នោះ ដែលជូនកាលចារភ្ជាប់ និងក្លោ
ទ្វារប្រាសាទ ឬសសរស្តម្ភជាក់ខាងក្នុង និងខាងក្រៅប្រាង្គប្រាសាទនានា
ជាប្រភពឯកសារអក្សរសាស្ត្រជាតិមួយយ៉ាងសំខាន់អនេក ដើម្បីការ
ចងក្រងនៃប្រវត្តិសាស្ត្រខ្មែរ ។ គួររលឹកឡើងវិញថា ៖សិលាចារិ
ខ្មែរដែលមានចំនួនរាប់ពាន់ផ្ទាំង ពាសពេញដែនដីនៅក្នុងភូមិភា
ឥណ្ឌូចិនទាំងមូល មិនគ្រាន់តែរៀបរាប់ពីរាជវង្សានុវង្សនៃព្រះម
ហាក្សត្រខ្មែរប៉ុណ្ណោះទេ ដូចជាស្នាព្រះហស្តនៃស្ដេចគ្រប់ព្រះអង្គ ជ
ទៀត ទំនៀមទំលាប់ ក្រឹត្យក្រម ការទូត រាជការ ទុកជាបទបញ្ញ
តាមប្រាសាទ ដែលមានទាំងព្រំប្រទល់នៃប្រទេសកម្ពុជា ដើងក្នុងរជ្ជកាល
មួយៗផង ។

ា យសា រសា វៈសំខាន់ និងគុណសម្បត្តិដ៏វិសេសវិសាលនេះហើយ
ជាអ្នកនិពន្ធផ្នែកអក្សរសាស្ត្រខ្មែរ លី ធាមតេង បានទាក់
ញទឹកចិត្តយើងអោយចាប់អារម្មណ៍ទៅលើបញ្ហានេះជាយ
កគួរអក្សរ ដែនផ្កាឯសិលាចារិកខ្មែរបុរាណមកអធិប្បាយ.ាត
ជាងថែវែកញែកបង្ហាញយើងយ៉ាងកេង្បាះកេង្បាយជាទីបំផុត
សៀវភៅរបស់លោក ៗ មិនតែប៉ុណ្ណោះ ាសា តអ្នកប្រាជ្ញខាង
ក្សរសាស្ត្រខ្មែរយើងនេះ ថែមទាំងជាកត់ទម្លូទៅលើអ្នកនិ
ខ្មែរជាទៀមបង្ងនាសម័យមុនៗ ដែលបន្សល់ទុកឲ្យជំនិត្រ
ល់ត្រពង់របស់ខ្លួនជាច្រើនដើម្បីជាកេរ្តិ៍មតកក្រអូបឈ្ងុយឈ្ងប់លើស
ដល់កុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយផង ។ នេះជាភារៈ
និងជាវិភាគទានមួយដ៏ក្រមនឹងមាន ហើយដែលមាននយ័
សារជ្រាលជ្រៅ គួរអោយយើងស្ងើចសរសើរគ្រប់គ្នា ដោយស្មោះ
គអស់ពីដួងចិត្ត ។

ក្នុងន័យនេះហើយជាពិសេសក្នុងគ្រាដ៏អភ័ព្វនេះដែលប្រទេស
ជាជាទីស្នេហា ដែនយើងបានបាត់បង់នូវទ្រព្យសម្បត្តិជាតិគ្រប់បែប
ងទាំងអស់ហើយ មានការខ្វះខាតគ្រប់វិស័យជាដំណំ យើងខ្ញុំ
ងអស់ដែលមានចិត្តស្រឡាញ់រាប់អានអក្សរសិល្ប៍ អក្សរសាស្ត្រ
តិចតួចប្រហាវជ្រាវប្រមែប្រមូលឯកសារនានា ដែលចៀសផុតពី
ាសសកម្មដែនភ្លើងសង្គ្រាមដើម្បីយកមកបោះពុម្ពផ្សាយ ក្នុងវត្ថុបំណង
ដ៏ឧត្តុង្គឧត្តម្ភ៍ ការរក្សាទុកព្រមទាំងការបង្កើនសម្បត្តិវប្ប -
ជាតិទុកជា ឈ្នា ដែលបន្តដល់កុលបុត្រកុលធីតាជំនាន់ក្រោយ ។
គម្រោងការបោះពុម្ពថ្មីទៀងវិញនូវឯកសារបញ្ជាប់នេះ

ពុំអាចនឹងប្រព្រឹត្ត ធ្វើទៅរួចបានជាស្ថាពរ បើប្រសិនជាគ្មានការ
ឧបត្ថម្ភផ្ចិតផ្ចង់បំផុតពីសំណាក់លោកគ្រូ មី ស៊ែល " ផ្នែកប្រវត្តិ-
សាស្ត្រ និងភូមិសាស្ត្រ " និងលោក ញ សុផារះ ព្រមទាំងគរុសិស្ស
ទាំងអស់នៅជំរំសម្តេចឪ " ណាយចឺ " ។

ជាទីបវសានក្តី ដោយគោរពនិងស្មោះស្ម័គ្រ យើងខ្ញុំទាំងអស់គ្នា
សូមលើកដៃទាំងខ្ទេរឧទ្ទិសភាគផលកុសល ជូនចំពោះលោកសី ជាម
និងទិពាវិញ្ញាណក្ខន្ធ នៃបុព្វបុរសខ្មែរទាំងអស់គ្រប់សម័យ ដែលបានគាំពារ
ត្រួតត្រាចំបាច់ថែរក្សាអក្សរសាស្ត្រជាតិ កុំអោយវិនាសអន្តរាយបាន
ដើម្បីទុកជាកេរ្តិ៍ដំណែលដ៏ថ្លៃថ្លា ដល់កូនខ្មែរគ្រប់ជំនាន់ ។

ធ្វើនៅជំរំសម្តេចឪ ថ្ងៃ ទី២៧ ខែ សីហា ឆ្នាំ ១៩

ដោយលោក មី ស៊ែល និងគរុសិស្ស-ផ្នែកគ្រូប

រំគ្រូ " ផ្នែកប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ " ទាំងអស់ដូចមានរាយនាម
ខាងក្រោមនេះ :

១ - លោក ប្រាក់ សុផុន ២ - លោក ទោល ឆេង
៣ - លោក អ៊ឹង សុភាព ៤ - លោក មាស ហន
៥ - លោក ម៉ៅ ណាយ ៦ - លោក លី សុខាន
៧ - លោក គន់ វីរៈ ៨ - លោក យិន សឿន
៩ - លោក គួ ចាន់វីរៈ ១០ - លោក សុន សុង
១១ - លោក ព្រំ ខេត្តា

# ឧទ្ទិស

ខ្ញុំសូមឧទ្ទិសស្នាដៃដ៏ខិតខំ នឹងផ្ចិតផ្ចង់បំផុតរបស់ខ្ញុំនេះ ជូនចំពោះវិញ្ញាណក្ខន្ធនៃបិតាខ្ញុំ នាម លី-ម៉ុង ដែលលោកបានខំបង្ហាត់ចិត្តខ្ញុំ ឲ្យចេះស្រឡាញ់អក្សរសាស្ត្រខ្មែរតាំងពីអាយុ ៧ ឆ្នាំ ។ គ្រានោះលោកបានសរសេរសាស្ត្រារឿងមួយយ៉ាងវែង ដោយគំនិតផ្ទាល់របស់លោក ឲ្យឈ្មោះថារឿង «សុវណ្ណរត្នា» សំរាប់បង្ហាត់ខ្ញុំឲ្យចេះអានជាបទថែបខ្មែរបុរាណយ៉ាងត្រឹមត្រូវ នឹងធ្វើឲ្យខ្ញុំក្រេបជញ្ជក់រសជាតិអក្សរសាស្ត្រខ្មែរតាំងពីនោះរហូតមក ។

ល.ធ.គ.



# អារម្ភកថា

ជាយូរមកហើយដែលខ្ញុំជាប់ជំពាក់ចិត្ត ក្នុងបញ្ហាអក្សរសាស្ត្រខ្មែរ ៗ គោលបំណងនេះ ក៏ដាស់តឿនចិត្តខ្ញុំឲ្យប្រឹងប្រែងស្រាវជ្រាវរកនូវលក្ខណ៍ការណ៍សំខាន់ ៗ របស់អក្សរសាស្ត្រជាតិយើង ដើម្បីប្រមូលក្រងគោលគំនិតឲ្យបានគ្រប់គ្រាន់ ៗ ក្នុងការស្វែងស្រាវជ្រាវ, ខ្ញុំតែងជួបនឹងឧបសគ្គជាច្រើន សឹងតែអស់សង្ឃឹមថាពុំអាចធ្វើទៅទៀតកើត ប៉ុន្តែចិត្តមានះនៅតែមានជានិច្ច ពុំរាគពីខ្លួនខ្ញុំឡើយ ៗ ដូចលោក-អ្នកអានធ្លាប់ជ្រាបស្រាប់ហើយ លក្ខណ៍គោលផ្សេង ៗ នៃអក្សរសាស្ត្រយើង សឹងតែស្ថិតនៅក្នុងសាឋិកំបាំង សឹងតែទាំងអស់ ៗ អក្សរបារីកសុទ្ធតែនៅទីជ្រកប់នៅកណ្តាលព្រៃ ឬ ទីណាដ៏ស្ងាត់ ហើយសុទ្ធតែជាភាសាបាលី – សំស្ក្រឹតថែមទៀត ៗ សាស្ត្រា ឬ ក្រាំងផ្សេង ៗ ស្ថិតនៅតាមវត្តអារាម ហើយបោះបោយមិនបានគត់មត់ល្អទេ ៗ រឿងព្រេង ឬ បទចម្រៀងសោតក៏នៅតែតាមមាត់អ្នកស្រុក ជាពិសេស

គឺអ្នកនៅឆ្ងាយពីទីក្រុង ៗ តែជាសំណាងល្អដែរ, ដាយូ
មកហើយ រាជការយើងខាងក្រសួងធម្មការ បានបង្កើតជ
ក្រុមមួយហៅថា «ពុទ្ធសាសនបណ្ឌិត្យ» ដែលមានការ
ប្រមូលឯកសារគ្រប់សព្វ ខាងវប្បធម៌របស់ខ្មែរ តាំងពីបូរម
បូរាណមក គឺមាន៖ ក្រុមជំនុំទំនៀមទំលាប់, ក្រុមជំនុំប្រែ
ព្រះត្រៃបិដក, ក្រុមស្រាវជ្រាវក្បួនខ្នាតផ្សេងៗ, ក្រុមវេក្ប
សាស្ត្រា, ក្រាំង គម្ពីរនឹងសៀវភៅគ្រប់បែបគ្រប់យ៉ាង ដែល
យើងហៅថាបណ្ណាល័យ ។ ដូចនេះ ក្រុមពុទ្ធសាសនបណ្ឌិត្យ
មិនមែនមានការៈតែត្រឹមស្រាវជ្រាវ ឬ ផ្សាយពុទ្ធសាសនា
មួយមុខនោះទេ គឺពិតជាវិជ្ជាស្ថានវប្បធម៌មួយ យ៉ាងជាក់ប្រា-
កដរបស់ខ្មែរ ។ អាស្រ័យលើឯកសារយ៉ាងចំណាន ៗ របស់
វិជ្ជាស្ថាននេះឯង ដែលជួយបំភ្លឺផ្លូវ, ដឹកនាំដំណើរស្រាវជ្រាវ
របស់ខ្ញុំឲ្យបានស្រួលច្រើន ។ ព្រោះគម្ពីរក្បួនខ្នាត ឬ សៀវ-
ភៅរបស់អ្នកប្រាជ្ញសរសេរពីការស្រាវជ្រាវបុរាណវត្ថុរបស់ខ្មែរ
សុទ្ធតែមានដម្កល់នៅក្នុងទីនោះ ៗ តែទោះបីជាខ្ញុំបានទទួល

ផលល្អពីបណ្ណាល័យនេះហើយក្ដី ខ្ញុំត្រូវតែចំណាយពេលក្រៅពីអានសៀវភៅ, ពីការកត់ត្រាតាមសៀវភៅទាំងនោះជាច្រើនទៀត ព្រោះត្រូវការស៊ើបសួរ, ប្រមែប្រមូលបញ្ជាក់លើការណ៍ដែលជួបប្រទះក្នុងសៀវភៅនោះថែមទៀតផង ៗ ឯរឿងរ៉ាវសាស្ត្រា ឬ ក្រាំងណាដែលពុំមាននៅក្នុងបណ្ណាល័យនេះទេ ក៏ត្រូវតែស្វែងរកឲ្យឃើញដែរ ដោយធ្វើដំណើរទៅកាន់ទីឆ្ងាយ ៗ មានវត្តអារាម នឹង បុរាណប្រាសាទនានាដែលមានជាប់ទាក់ទងនឹងរឿងរ៉ាវនេះជាដើម ៗ

ដោយសារការស្វះស្វែងពិនិត្យអស់រយៈកាលជាង ៧ ឆ្នាំមកហើយ ទើបខ្ញុំប្រមូលឯកសារ នឹងគោលគំនិតខាងអក្សរ-សាស្ត្របានច្រើនបន្តិច ល្មមឲ្យពឹងផ្អែកខ្លួនឯងបានខ្លះ ៗ ប៉ុន្តែខ្ញុំពុំទាន់រកមធ្យោបាយណា នឹងផ្សាយការសន្សំរបស់ខ្ញុំនេះបាននៅឡើយ ៗ លុះមកដល់ គ.ស. ១៩៥៧ ទើបក្រសួងឃោសនាការ បានអនុញ្ញាតឲ្យសមាគមអ្នកនិពន្ធខ្មែរផ្សាយអំពីអក្សរសាស្ត្រតាមវិទ្យុជាតិ ដើម្បីណែនាំឲ្យបណ្ដាជនខ្មែរ

ជាគ្រឿងបំភ្លឺមួយជាជាងគ្មានពន្លឺសោះដែរ » ។ ប្រសិនណា ជាថ្ងៃក្រោយទៅ មានសិល្បករចំណានណា ជួយរបនាកូន ប្រទីបខ្ញុំ ពោលគឺកិច្ចការនេះ ឲ្យកាន់តែភ្លឺរន្ទាលច្បាស់ចាំង ថែងឡើងនោះ រឹងរិតតែសមប្រាថ្នាជាក់ស្តែងឡើង សំរាប់ជា សាធារណប្រយោជន៍តទៅ ។

លុះយល់សព្វគ្រប់ដូចពណ៌នាមកខាងលើ ខ្ញុំក៏ដាច់ចិត្ត រៀបចំសរសេរជាអត្ថបទខ្លី ៗ ល្មមយកទៅថ្លែងផ្សាយតាម វិទ្យុជាតិ រៀងរាល់ថ្ងៃព្រហស្បតិ៍ ចាប់តាំងពីខែ កញ្ញា គ.ស. ១៩៥៧ មក ។ កាលណាបានផ្សាយជាច្រើនលើក ចំនួនជិតពីរឆ្នាំទៅហើយ មានមិត្តភក្តិខ្ញុំជាច្រើនយល់ថា៖ កិច្ចការរបស់ខ្ញុំនេះ មានប្រយោជន៍ដល់អ្នកសិក្សាណាស់ ។ គេក៏ពោលដាស់តឿនឲ្យខ្ញុំចងក្រងបោះពុម្ពជាសៀវភៅឡើង ព្រោះការស្តាប់តាមត្រចៀក ម្តងបន្តិច ៗ មកនោះ ជាការ រាត់រាយពន់ពេក ។

កាលពីខែតុលា គ.ស. ១៩៥៨ ប្រទេសនានាដែលជន

ស្គាល់ផ្ទៃមុខវិជ្ជានេះផង ៗ គណៈកម្មការនៃសមាគមក៏បាន ប្រគល់ភារៈការផ្សាយនេះ ដែលជាបន្ទុកមួយយ៉ាងធ្ងន់មកលើខ្លួនខ្ញុំ ៗ ខ្ញុំទទួលភារៈដោយទើសទាល់ព្រោះក្នុងចិត្តបារម្ភជាខ្លាំងថា៖ ធ្វើម្ដេចហ្ន៎! ឲ្យរឿងរ៉ាវអក្សរសាស្ត្របានលេចរូបរាងទៅបង្ហាញជនរួមជាតិឲ្យបានច្បាស់លាស់ បើខ្ញុំនៅងងឹតងងល់នៅឡើយ ៗ ហើយបើងាកមើលមកអាត្មាឯងក៏ឃើញថាមានចំណេះស្ទួចស្ដើងពេក ពុំសមល្មមហ៊ានពារទៅលើកិច្ចការដ៏ធំនេះសោះ ព្រោះក្រែងជួនជាប៉ះទៅលើការខុសឆ្គងខ្លះទៅ, មុខជាត្រូវពាក្យនិន្ទាពីអ្នកផងមិនខាន ៗ តែក្នុងគ្រាជាមួយគ្នានេះ មានគំនិតថ្មីមួយមករំលឹកស្មារតីខ្ញុំថា៖ ការយល់ដូចខាងលើនេះ ជាហេតុនាំឲ្យរិចរិលទៅវិញទេ ព្រោះថា៖ កិច្ចការដែលធ្វើទៅហើយ រមែងតែមានត្អាំត្អងជាមិនខាន គឺមានតែអ្នកមិនធ្វើសោះនោះទេ ដែលមិនចេះខុសសោះ ៗ ហើយម្យ៉ាងទៀត ខ្ញុំយល់ថា « ក្នុងទីងងឹតសូម្បីតែទៀនប្រទីបតូចក៏ដោយ បើគ្មានចង្កៀងធំទេ ក៏រាប់បានថា

ជាតិអាស៊ីនិងអាហ្វ្រិក បានប្រមូលគ្នាធ្វើសន្និសីទនៅទីក្រុងតាស្កេន (សហភាពសូវៀត) ស្ដីពីអក្សរសាស្ត្រនិងវប្បធម៌ ។ ខ្ញុំក៏មានកិត្តិយស បានទទួលសេចក្ដីទុកចិត្តពីអ្នកនិពន្ធនានា ដែលតម្រូវឲ្យខ្លួនខ្ញុំនិងមិត្តសំឡាញ់ខ្ញុំ, លោកម៉ា-ឡាយខេម, ធ្វើជាដំណាងប្រទេសកម្ពុជា ឲ្យទៅកាន់សន្និសីទនោះ ។ ឱកាសនេះ លទ្ធផលក្នុងការស្រាវជ្រាវរបស់ខ្ញុំ ក៏បានទៅលាតត្រដាងបង្ហាញរូបរាងអក្សរសាស្ត្រនិងវប្បធម៌ជាតិ ដល់បណ្ដាដំណាងប្រទេសនានា ។ ពេលនោះទៀត គេមានបង្កើតការពិព័រណ៌សៀវភៅរបស់ជនជាតិទាំងអស់ ដែលបានទៅរួមប្រជុំ ។ ខ្មែរយើងក៏បានបញ្ចេញសៀវភៅ ជាង ៥០ ក្បាលតាំងនឹងគេដែរ តែមានភៀវជាច្រើនបេះតែសួររកសៀវភៅដែលស្ដីពីអក្សរសាស្ត្រខ្មែរ ហើយដែលកាលនោះយើងពុំទាន់មាននៅឡើយ ។ លុះត្រឡប់មកវិញ ខ្ញុំនឹករកតែប្រាជ្ញាធ្វើយ៉ាងណាឲ្យកើតបានជាសៀវភៅនេះនឹងគេឡើង ។

លុះមកដល់ គ.ស. ១៩៥៩ នេះ ក្រសួងសិក្សាធិការ

បានចាត់ឲ្យខ្ញុំទៅបង្រៀននៅអនុវិទ្យាល័យព្រះនរោត្តម, ខ្ញុំក៏បានឱកាសធ្វើវិសិដ្ឋការចំពោះមុខវិជ្ជានេះថែមទៀត ។

រហូតមកដល់សព្វថ្ងៃនេះ កិច្ចការរបស់ខ្ញុំក៏បានលេចរូបឆោមឡើងសំរាប់ជួយផ្តល់សេចក្តីត្រូវការ ឲ្យអ្នកសិក្សាអក្សរ-សាស្រ្តខ្មែរ ដែលសម័យបច្ចុប្បន្នកំពុងតែស្វះស្វែងតម្រូវតាមកម្មវិធីសិក្សាផង ទឹងតម្រូវតាមឋានៈប្រទេសយើងដែលជារដ្ឋឯករាជ្យគ្រប់លក្ខណៈផង ។ ខ្លួនខ្ញុំក៏មានចិត្តរីករាយណាស់ ដោយបានបំពេញករណីយកិច្ចតាមបំណងដែលមានជាយូរមកហើយ ទុកដូចជាខ្ញុំបានសងបំណុលមួយដែលធ្លាប់ជំពាក់ក្នុងចិត្តជាច្រើនឆ្នាំមកហើយដែរ ។

ហេតុនេះ ខ្ញុំសូមអភ័យទោសពីសំណាក់អស់លោក-អ្នកប្រាជ្ញទាំងឡាយ ត្រង់ណាមានការខុសឆ្គងត្រង់ណា សូមមេត្តាជួយកែប្រែតម្រង់ឲ្យបាន ព្រោះស្នាដៃនេះជាការល្បងរបស់ខ្ញុំក្នុងកិច្ចសិក្សា និង វែកញែកអំពីអក្សរសាស្រ្តខ្មែរ ។

ជាបញ្ចប់ ខ្ញុំសុំលំឱនកាយគោរពដល់វិញ្ញាណខន្ធអស់លោកកវី-អ្នកនិពន្ធ ពីព្រេងនាយ ដែលបានទុកស្នាដៃឲ្យយើងរហូតសព្វថ្ងៃនេះ ។

ភ្នំពេញ មីនា ១៩៥៩

លី-ធាមតេង

ដំរីជើងបួនគង់មានភ្លាត់
អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច



ជំពូកទីមួយ

# ដើមកំណើតភាសា និង អក្សរខ្មែរ

## ក– ដើមកំណើតភាសាខ្មែរ

បើយើងសង្កេតតាមសេចក្ដីកត់ត្រាក្នុងប្រវត្តិសាស្ត្រខ្មែ
យើងឃើញថា នៅលើកោះមួយ ដែលបុរាណឲ្យនាមថ
កោះគោកធ្លក(១) មានបណ្ដាជនរស់នៅជាអន្លើងណាស់ម
ហើយ គឺតាំងពីសម័យមុនប្រវត្តិសាស្ត្រទៅទៀត ។ ឯមនុស្
ទាំងនេះ រស់នៅដោយពួក ៗ ផ្សេង ៗ ពីគ្នា ពុំបេះបំណ
ចុះចូលគ្នា ឬ មានការប្រាស្រ័យគ្នាទៅវិញទៅមកនៅឡើយ
ទេ ។ បើនរណារស់នៅក្រុមត្រង់ណា ក៏ទាក់ទងប្រាស្រ័យ
គ្នាតែក្នុងបំណោមជិតខាងខ្លួនប៉ុណ្ណោះ ឥតរវល់ចង់ជួបក

---

១– បានជាឈ្មោះ គោកធ្លក ព្រោះកោះនេះមានធ្លកមួយដើមដុះនៅកណ្ដាល

ក់ជាមួយចំណោមអ្នកដទៃទៀយ ។ ឯកសារដែលគេ
ប្រាស់ក្នុងកិច្ចរស់នៅអចិន្ត្រៃយនោះ គឺមានរូបគោមជាក់
ាកេជដោយខ្សែកៗ ពីគ្នាដែរ ពុំអាចស្តាប់គ្នាបានដោយងាយ
នចំណោមមួយទៅចំណោមមួយទៀយ ។

លុះចំណេរតមក នៅគ្រាដែលចាប់ផ្តើមមានប្រវត្តិ-
ាស្ត្រអ្នកស្រុកដែលរស់នៅលើកោះគោកធ្លក ក៏បានប្រមូល
បផ្តុំគ្នាជាប្រជាជាតិមួយ នៅក្រោមមេត្រួតត្រាតែមួយ ។
អ្នកត្រួតត្រានោះជាស្ត្រីគេទប្រកបដោយរូបគោម និង ប្រាជ្
ងវៃដែលអ្នកកត់ត្រា បានដាក់នាមប្លែកៗពីគ្នា ។ ខ្លះថានាង
សក់ក្រអូប » ឬ នាង « សុវណ្ណកេសី » ដូចមានរឿង
ពង្សប្រចាំស្រុកនៅមណ្ឌលបូរីនិទានថា ៖ នាងនេះ បានចាញ់
ាកនាយឈ្មួញសំពៅបរទេស ដែលបញ្ឆោតឲ្យនាងចុះទៅ
ាំសប្បាយក្នុងសំពៅ ហើយគេស្រាវយុថ្កាចេញសំពៅទៅ
ណ្តាលសមុទ្រកុំឲ្យនាងចុះវិញបាន ។ល។ តាមរឿង
ទានផ្សេងទៀតថា ៖ នាងនេះមាននាមជានាង « នាគី »

ដែលជាកូនទាគមកលេងទឹកសមុទ្រ ហើយត្រូវបានជួប
មួយព្រះថោង[១]ជារាជបុត្រ ព្រះបាទអាទិច្ចវង្ស គ្រងរាជ
នៅឥន្ទបត្តបុរី[២] ដែលចេញមកក្រសាលតាមរលកខ្ទប់ឆ្នេ
សមុទ្រ ហើយក៏បានរៀបអភិសេកជាមួយគ្នាទៅ ។

តាមឯកសាររបស់អ្នកកត់ត្រា ជាតិចិន[៣]បានកត់ទា
ថា ព្រះនាង «លីវ-យី»[៤]ដែលនៅពេលនោះមានពួកអន្ដោ
ប្រវេសន៍ ជាតិព្រាហ្មណ៍មកពីប្រទេសឥណ្ឌា ប៉ែកខាងត្បូ
ចូលមកកាត់ត្រាតក្នុងស្រុក ហើយមេនៃពួកនោះបានលើកព្រ
នាងនេះធ្វើជាអគ្គមហេសី នៅគ្រប់គ្រងលើផែនដីគោកធ្លក
រហូតមក ។ ព្រះចៅនេះឯងដែលសិលាចារឹកបានថ្វាយ
ព្រះនាមថា «ព្រះបាទកៅណ្ឌិន្យ» ហើយដែលអ្នកកត់ត្រា

---

១– ព្រះថោង ក្លាយពីពាក្យសៀម «ព្រះថង» ប្រែថាស្ដេចមាស ព្រោ
នៅគ្រងរាជ្យលើដែនសុវណ្ណភូមិ ដែលគេហៅថា ដែនដីមាស ។ ២– តាម
ឯកសារប្រវត្តិសាស្ត្រខ្លះ ថានាមនេះជានាមប្រទេសខ្មែរបុរាណ ។ ៣–លោក
Pelliot បានប្រែជាភាសាបារាំងពីឯកសារលោក ជីវ-តាក្វាន់ 周達光
ឲ្យឈ្មោះសៀវភៅនោះថា : Le Founan ។ ៤– ពាក្យនេះក្លាយពីភាសាចិ
លីវ-យេ ( 柳葉 = Lieuo - Ye ) ប្រែថា ស្លឹកស្វល ។

ន បានថ្វាយនាមថា «ហ៊ុន-ទៀន»(១) ។ ព្រះរាជានេះ
ើយ ជាបឋមក្សត្ររបស់យើង ដែលបានរៀបចំកសាង
ណាចក្រនគរភ្នំ(២)ជាដំបូង ។

ដូចនេះ បើយើងសង្កេតតាមហេតុការណ៍ដូចពណ៌នា
មកហើយនេះ ឃើញថាបណ្ដាជនដែលរស់នៅលើកោះ
ាកក្ដុកទាំងប៉ុន្មាន មានភាសានិយាយប្រចាំជាតិរៀបអស់ទៅ
ក៏យ ។ កស្ដាន គឺការបេះប្រាស្រ័យគ្នីគ្នា, រួបរួមគ្នាជា
ង្គមជាតិមួយ នៅក្នុងកិច្ចត្រួតត្រារបស់ព្រះនាងនាគីសោមា
លីវយើ ។

ភាសាទាំងនេះឯង ទៅបែកជាចែក ជាជាន់ ហេតុ
ព្យៅថ្ងៃនេះ គឺភាសាតូចតាចរបស់អ្នករស់នៅក្នុងព្រៃ នា
ាណាខេត្តកម្ពុជាយើងនេះ ដូចជាជាតិព្នង, ជង, រដែ,

---

១– 混填 = Houen-T'ien (P.Pelliot, Le Founan) ។
២– ពាក្យ ភ្នំ នេះ ដែលបានសរសេរក្លាយទៅជា ហ្វូណាម (扶南 =
ou-nam) ហើយដែលបារាំងសរសេរក្លាយទៅទៀតជា Fou-nan ។

១. Kon-jin

សម្រែ, គួយជាដើម ។ មានអ្នកប្រាជ្ញស្រាវជ្រាវខាងភា
ជាច្រើនរូប បានកត់ត្រានិងធ្វើការសិក្សាបញ្ជាក់ពីភាសាខ្មែ
យើង ហើយដែលគេកប់បញ្ចូលភាសាទាំងអស់ខាងលើ ថែ
ទាំងភាសាអ្នកជិតខាងខ្លះថានៅក្នុងចំណោមភាសាខ្មែរ ។

យើងរមែងឮអ្នកផងពោលដោយភ័ន្តច្រឡំថា ភាសាខ្មែ
យើង មានដើមកំណើតមកពីភាសាសំស្ក្រឹតនិងភាសាបាលី
ព្រោះគេឃើញក្នុងភាសាយើងសព្វថ្ងៃមានលាយច្របល់ដោយ
ពាក្យបាលីជាច្រើន ដូចពាក្យថា : ផល, កល, ហេតុ, គេ
គេហដ្ឋាន, . . . និងសំស្ក្រឹត ដូចពាក្យ : មិត្រ, ប្រព្រឹត្ត, ត្រឹ
ស្រី, . . . ។ ប៉ុន្តែយើងអាចដោះស្រាយវិញដោយងាយថា
ពាក្យទាំងឡាយដែលក្លាយចេញមកពីបាលី និងសំស្ក្រឹតនេ
មិនមែនកើតឡើង តាំងពីមុនសម័យជនជាតិឥណ្ឌាចូលស្រុ
ពោលគឺមុនរាជ្យព្រះបាទកៅណ្ឌិន្យនោះទេ ។ ព្រោះពាក្យទាំ
នេះសុទ្ធតែចូលមកជាមួយនិងអារ្យធម៌ឥណ្ឌា ក្នុងរវាងគ្រិស្ត
សតវត្សទី ២ ក្រោយដែលព្រះបាទកៅណ្ឌិន្យ កសាងអាណា

កូនគេកុំរបហើយ ៗ ម្យ៉ាងទៀត យើងអាចសួរទៅវិញ
៖ បើថាភាសាខ្មែរមានដើមកំណើតមកពីភាសាសស្ក្រឹត
ំ បាលី ដូចនេះ តើបណ្ដាជនខ្មែរដំបូងសម័យគោកធ្លក
នគ្រាឥណ្ឌៀននាំភាសាទាំងពីរមកនោះ , ជនជាតិនេះចេះ
យាយឬទេ? បើចេះនិយាយតើនិយាយភាសាអ្វី ? ត្រង់នេះ
ញ្ញាយើងឲ្យច្បាស់ថា ភាសាខ្មែរមិនមែនមានដើមកំណើត
ពីភាសាបាលី និងសំស្ក្រឹតដែលជាមូលដ្ឋានលទ្ធិសាសនា
ង ៗ ដែលហូរចូលមកស្រុកយើងសម័យក្រោយនេះទេ ៗ
តិជាខ្មែរ មានភាសាកំណើតរបស់ខ្លួនពីយូរអង្វែងមកហើយ
នភាសានោះមិនសូវសម្បូណ៌ល្អលាស់ប៉ុន្មាន ៗ ពាក្យ
ចន៍នៅតិច, មិនទាន់មានសំនួនវោហារគ្រប់លក្ខណៈ ៗ

ដូចនេះ យើងត្រូវសំគាល់ថា ភាសាបាលីនិងសំស្ក្រឹត
ន់តែជាភាសាចំណូលថ្មី ដែលហូរតាមអារ្យធម៌ឥណ្ឌៀ
របូកបញ្ចូល បន្ថែមក្នុងភាសាដើមរបស់យើងប៉ុណ្ណោះ ៗ

# ១– ដើមកំណើតអក្សរខ្មែរ

ឯអក្សរខ្មែរមិនមែនកើតឡើងស្មើនឹងភាសាទេ ព្រ
សម័យដែលមនុស្សស្ថិតនៅលើកោះគោកធ្លក ជាដំបូងនេ
គ្រាន់តែបង្កើតបានទូវភាសាសំរាប់និយាយប្រាស្រ័យ
ប៉ុណ្ណោះ ចំណែកអក្សរសំរាប់ជាគ្រឿងចារឹកសំគាល់មិនទ
មានកើតនៅឡើយទេ ។ ដូចនេះ មនុស្សជំនាន់នោះមិនត
ចេះសរសេរសំបុត្រស្នាម ផ្ញើទៅមករកគ្នា ឬចេះកត់ត្រាអ្វី
ឡើយ ។ បើគេចង់កត់ចំណាំអ្វីមួយ គេមានតែគ្រឿងចង
ក្នុងចិត្តប៉ុណ្ណោះ ។ មនុស្សសម័យនោះ ទំនងជាយកវ
គេខផ្សេង ៗ ជាគ្រឿងចំណាំ ដូចជាយកដូវស៊ុកឈើលា
ឬឈើថ្លុះធ្វើជាគ្រឿងចំណាំខាងពេលវេលាជាដើម ។

លុះចំណេរតមក ដល់គ្រាដែលខ្មែរបានទទួលភាស
ឥណ្ឌាក៏បង្កើតដោយសន្និដ្ឋានជារូបរាងអក្សរ ដោយអ្ន

ព្រា ផ្ទសមយិទ្ធា : ប្រមើលយកតាម អក្សរនិងឡៀង មួយ បែ

ខាងទក្ខិណាបថ (១) ។ អក្សរឥណ្ឌាមានច្រើនយ៉ាង
ាស់ ប៉ុន្តែបែបអក្សរដែលមានអាយុចាស់ជាងគេគឺអក្សរ
្រាហ្មី » អ្នកស្រុកឥណ្ឌាបូរាណបានសន្មតថា ជាអក្សរ
លព្រះព្រហ្មបានបង្កើតមក ទុកសំរាប់ឲ្យមនុស្សប្រើប្រាស់
តាមពិត គឺមនុស្សខ្លួនឯងទេ ដែលជាអ្នករកមធ្យោបាយ
ង្កើតតួអក្សរ ដែលជាគំនូសសំគាល់សំរាប់សរសេរប្រាស្រ័យ
ទៅវិញទៅមក ។ អក្សរព្រាហ្មីនេះ មានរូបរាងជាតួ
បអង្គ ៗ ប្លែក ៗ ពីគ្នា តែមានពិធីផ្សំស្រៈ, ព្យញ្ជនៈ, ចំនួន
ចអក្សរដែលខ្មែរយើងប្រើសព្វថ្ងៃនេះ ។ មានអក្សរច្រើន
បទៀត ដែលកើតបន្តមកពីអក្សរព្រាហ្មី ហើយមានពិធី
ប្រហាក់ប្រហែលគ្នា ខុសមួយតែត្រង់រូបភាពប៉ុណ្ណោះ ។
ះបាទកៅណ្ឌិន្យ ដែលជាបឋមក្សត្រខ្មែរ ទ្រង់បានដឹកនាំ
នត្រឹមតែចំណៀមទំលាប់, ប្រពៃណី, សាសនាឥណ្ឌា
កសារព្រោះ ឲ្យសាយភាយលើប្រទេសយើងប៉ុណ្ណោះទេ,

---

១–ភូមិភាគផ្នែកខាងត្បូងលើខ្ពង់រាប Dekkan ។

ទ្រង់បាននាំតាំងបែបអក្សរឥណ្ឌៀ(១) នៅផ្នែកទក្ខិណាប
(ខាងត្បូង) មកផ្សាយនៅក្នុងប្រទេសយើងផង ៗ អក្សរន
មានបែបភាពពងមូល ៗ ដែលយើងប្រឌិតយកលំនាំតាម
កើតបានជារូបពង់អក្សរជាតិយើងសព្វថ្ងៃនេះ ៗ យើងគួរ
ទុកថា៖ ប្រជាជាតិខ្មែរយើងតាំងពីបុរាណមក ជាជាតិមួ
មានសិល្បៈនឹងទេពកោសល្យជាប់នឹងខ្លួនជានិច្ច គឺថា បើ
អ្វីមួយ លុះណាតែខ្លួនពេះរចនា ទើបសុខចិត្តសន្និដ្ឋានថាបា
ការ ៗ ដូចជាការប្រើអក្សរឥណ្ឌៀប៉ែកខាងត្បូងនេះជាដើ
បុព្វបុរសយើង មិនមែនប្រើតាមរបៀបឥណ្ឌៀសុទ្ធ ៗ
លោកបានប្រឹងរចនាកែច្នៃបែបអក្សរនេះបន្តិចម្តង ៗ គ្រា
កើតបានជាបែបពិសេសដោយឡែក គឺធ្វើឲ្យមានលក្ខណ
ជាអក្សររបស់ជាតិខ្លួនពិត ៗ ។

មានអ្នកប្រាជ្ញស្រាវជ្រាវគួរអក្សរជាច្រើនរូប បានផ្ទៀ

១– មានអ្នកស្រាវជ្រាវខ្លះថា អក្សរនោះឈ្មោះអក្សរគ្រិន្ថៈ តែយើងរកពុំទា
បានប្រទះឃើញរូបរាងអក្សរនោះសោះ ។

អក្សរសិលាចារឹកខ្មែរបុរាណ នឹងអក្សរឥណ្ឌាប៉ែកខាងត្បូង ក៏ឃើញថា មានទ្រង់ទ្រាយដូចគ្នាមែន ដូចជាសិលាចារឹកខ្មែរនៅវ៉ុកាញ់ (ញ៉ាត្រាំង-វៀតណាម) នឹងសិលាចារឹកនៅភ្នំហាន់ជ័យ (កំពង់ចាម) ជាដើម ។ ប៉ុន្តែ តួអក្សរទាំងនោះមិនមែនដូចគ្នានឹងអក្សរយើងសព្វថ្ងៃទេ ព្រោះបុព្វបុរសយើងចេះតែរកវិធីកែប្រែ ដូចបានពោលរួចមកហើយខាងលើ ។ គឺជាអក្សរ ដែលខ្មែររៀបចំឲ្យកាន់តែស្រួលបន្តិចម្តង ៗ នេះហើយ ដែលប្រទេសជិតខាងខ្លះ បាននាំយកបែបនេះទៅកាឡៃធ្វើជាអក្សរគេតទៅទៀតផង ។

ដោយមានអំបូរចេញមកពីប្រភពជាមួយគ្នា ទាំងភាសា, ទាំងអក្សរដូចនេះហើយ ទើបអ្នកប្រាជ្ញទាំងឡាយឲ្យឈ្មោះភាសាអ្នកជិតខាងខ្លះថាមានអំបូរក្នុងវង្សភាសា «មន-ខ្មែរ» ដ្បិតសម័យបុរាណ មានតែជាតិទាំងពីរនេះទេ ដែលបានលូតលាស់ខាងវប្បធម៌, អារ្យធម៌ជាងគេក្នុងចំណោមប្រទេសនានានៅជ្រោយសុវណ្ណភូមិនេះ ។

ដើម្បីឲ្យបានច្បាស់ប្រាកដ យើងសូមជូនគំរូអក្សរ តាមសម័យខ្លះៗ ដែលយើងឃើញ៖

គំរូទី ១



គំរូទី ១ នេះ ជាអក្សរសម័យដំបូង បន្ទាប់ពីការបំឡែងចេញពីអក្សរព្រាហ្មី ។

គំរូទី - ២



អក្សរគំរូទី ២ នេះ គេឃើញមានប្រើនៅក្នុងសតវត្សទី ៦ នាសិលាចារឹកនៅភ្នំហាន់ជ័យ (កំពង់ចាម)។

គំរូទី-៣



អក្សរគំរូទី ៣ គេឃើញមានប្រើនៅក្នុងសិលាចារឹកទាំងឡាយ កាលពីសតវត្ស ១១ ដល់ទី ១២ ។

គំរូទី-៤



គំរូទី ៤ ជាអក្សរដែលយើងប្រទះឃើញនៅលើផ្ទាំងសិលាចារឹក នាប្រាសាទ អង្គរវត្ត កសាងពីសតវត្សទី ១៤ ដល់ទី ១៨ ។

សរុបសេចក្ដីទៅ យើងអាចចាំបានថា៖ ខ្មែរមានភាសា
ប្រចាំជាតិជាយូរអង្វែងកាលណាស់មកហើយ គឺតាំងពីមុន
សម័យប្រវត្តិសាស្ត្រម៉្លេះ ៗ ឯអក្សរវិញ ទើបតែនឹងចាប់មាន
ឡើងត្រឹមរដ្ឋកាលព្រះបាទកៅណ្ឌិន្យ ជាមួយគ្នានឹងអារ្យធម៌
ឥណ្ឌា ដែលចូលមកស្រោបពាសពេញប្រទេសយើង នៅ
សតវត្សទី ២ នៃគ្រឹស្ដសករាជ ។ អានុភាពខ្លាំង នៃអារ្យធម៌
នេះ គឺចាប់តាំងពីសតវត្សទី ២ នោះមក ប៉ុន្ដែអក្សរដើម ចេះតែ
មានអក្សរវិទូជាច្រើនរូប ព្យាយាមកែប្រែឲ្យកាន់តែស្រួលរៀន,
ស្រួលចាំឡើងទៀត ។ ឯភាសាសោត ក៏មានការប្រែក្លាយ
បញ្ចូលជាច្រើនក្នុងភាសាដើមយើងដែរ ព្រោះមានពាក្យ
សំស្ក្រឹតជាដំបូង ដែលចូលមកជាមួយលទ្ធិសាសនាព្រាហ្មណ៍
នឹងពុទ្ធសាសនាមហាយាន កាលមុនសម័យអង្គរ នឹងពាក់
កណ្ដាលខាងដើម នៃសម័យអង្គរ ។ លុះចាប់តាំងពីពាក់
កណ្ដាលខាងចុងសម័យអង្គរ រហូតមកដល់សព្វថ្ងៃ យើងបាន
ទទួលភាសាបាលីមួយ បញ្ចូលមកក្នុងភាសាខ្មែរទៀត ៗ ភាសា

ាងក្រោយនេះហូរចូលដោយសារលទ្ធិពុទ្ធសាសនាហីនយាន
ដលជាបែបសាសនាដ៏ប្រសើរមួយដែលយើងនាំគ្នាគោរព
ដល់បច្ចុប្បន្នកាលនេះ ។





## ជំពូកទីពីរ

# អានុភាពអក្សរសាស្ត្រ

ហេតុអ្វីហ្ន៎! ក៏អក្សរសាស្ត្រយើងនៅមានរឿងក៉ែរច្រើ
ម្ល៉េះ ? ត្រង់នេះយើងសូមបញ្ជាក់ថា ៖ តាំងពីយូរយារម
ហើយ ពាក្យថាអក្សរសាស្ត្រ ៗ នេះ បីដូចជាឮល់ល
អាកាសបក់បណ្តែតមករើយ ៗ ប៉ុណ្ណោះ មិនសូវមានអ្នកបា
ឲ្យជាប់រូបអក្សរសាស្ត្រនេះមកពិនិត្យសង្កេតឲ្យបានហ្មត់ចត់
ជាក់ប្រាកដ ឲ្យឃើញជាភិនភាគថាយ៉ាងនេះ ឬ យ៉ាងនោ
ឡើយ ៗ មានបុព្វបុរសយើងពីព្រេងនាយច្រើនរូបណា
ដែលបានខំពិនិត្យសង្កេតអំពីរឿងនេះ តែជនជាតិយើងហា
ដូចជាភ្លេចភ្លាំងទៅវិញ នៅគ្រាដែលវប្បធម៌បស្ចឹមប្រទេ

ូលមកគ្របដណ្ដប់ ។ ទោះជាយ៉ាងនេះក៏ដោយ យើងតែង ប្រទះឃើញវីរជនច្រើនរូបណាស់ដែរ ដែលប្រឹងទទៀល ជាមួយបញ្ហាអក្សរសាស្ត្រ តែយើងសូមអភ័យទោសដោយ នបានស្រង់នាមមករៀបរាប់ក្នុងពេលនេះ ។

អក្សរសាស្ត្រយើងពីព្រេងនាយបានបោះឫសយ៉ាងស៊ប់ ួនណាស់នៅក្នុងសន្ដានចិត្តនៃប្រជាជនជាតិយើង ដោយ ានផ្ដិតជាប់នៅក្នុងសន្ដានចិត្តបណ្ដាជនខ្មែរ តាមបែបផ្សេង ៗ ាដូចតទៅ ៖ អក្សរសាស្ត្រផ្ដិតក្នុងលទ្ធិសាសនា, រឿង ប្រលោមលោក, រឿងព្រេង និង កំណាព្យកាព្យឃ្លោង ទំនង ចម្រៀងផ្សេង ៗ ឥឡូវនេះយើងសូមលើកយកមួយវគ្គ ៗ មក ពិនិត្យសង្កេតនិងធ្វើអត្ថាធិប្បាយឲ្យអស់សង្ស័យដូចតទៅ ៖

## ក_ អក្សរសាស្ត្រលទ្ធិសាសនា

ដូចម្ដេចបានជាយើងពោលថាអក្សរសាស្ត្រស្ថិតនៅក្នុង លទ្ធិសាសនា ? ចំពោះសំនួរនេះ យើងមិនបាច់ឆ្ងល់ទេ

ព្រោះយើងឃើញស្រាប់ហើយ ៗ ព្រះធម៌ទាំងឡាយដែល
ជាគ្រឿងដំណែលទុករហូតយើងរាល់គ្នានេះ តើមានអ្វីជាគោល
ចារឹក ? គឺមានគម្ពីរផ្សេង ៗ មានព្រះត្រៃបិដកជាមូលដ្ឋាន ៗ
បំណែកនៅក្នុងគម្ពីរនោះទៀត ក៏យើងឃើញសុទ្ធតែចារជា
អក្សរយ៉ាងច្បាស់ក្រឡៅជាវគ្គជាឃ្លា តាមគោលសេចក្ដីរៀង
ដកបទៅ ៗ ទោះបីជាអក្សរទាំងនោះជាភាសាបាលីក៏ដោយ
ក៏ខ្មែរយើង សរសេរច្បាស់ជាតួអក្សរខ្មែរ យ៉ាងជាក់ប្រាកដ
ដែរ ៗ ដូចនេះ បើយើងអានភាសាបាលីនោះបាន ក៏ឈ្មោះថា
យើងជាអ្នកគ្រប់រសជាតិអក្សរសាស្ត្រដែរ ៗ យើងសង្កេត
ទៅទៀតថា មានគម្ពីរជាច្រើនទៀត ដែលមានបរិយាយជា
ភាសាខ្មែរសុទ្ធ ហើយគម្ពីរទាំងនោះមានលក្ខណៈជាក់លាក់
ជាភាសាខ្មែរ ដែលតុបតែងឡើងជាច្រើនសតវត្សមកហើយ
ផង ៗ គម្ពីរប្រភេទនេះ ប្រកដោយពាក្យពេចន៍ល្អស្រស
បមជាស្នាដៃខ្មែររៀបរៀងមែន ៗ គ្រាន់តែអធិប្បាយជារឿង
ក៏ផ្អែកទៅតាមទ្រឹស្ដីនៃព្រះពុទ្ធសាសនា គឺច្រើនតែដកស្រង់

នដែលមានស្រាប់នៅក្នុងគម្ពីរជាភាសាបាលី មកបក
ាយជាភាសាខ្មែរ នឹងរៀបដំណើរទំនងពាក្យឲ្យសមជា
ក្យខ្មែរគ្រប់លក្ខណៈប៉ុណ្ណោះ ៗ គម្ពីរសំរាយដែលយើង
ាយមកនេះហើយ ដែលខ្មែរយើងនិយមស្តាប់ និយមអាន
ងអ៊ីទាំងអស់ ព្រោះសន្តានចិត្តគេពឹងផ្អែកទាំងស្រុងទៅលើ
ពុទ្ធសាសនារួចស្រេចទៅហើយ ៗ ហើយមួយទៀត
ាយពិបាកអានគម្ពីរជាភាសាបាលីផង ៗ ទើបនាំគ្នានិយម
បយកគម្ពីរភាសាខ្មែរនេះ មកហាត់ហ្វឹកហ្វឺនសិក្សារៀន ៗ
ន ៗ ចំពោះរឿងនេះ នាំឲ្យយើងនឹកដល់សម័យដែល
ទេសយើងត្រូវធ្លាក់បរាជ័យនៅក្រោមឱវាទប្រទេសដទៃ ៗ
លនោះខ្មែរភាគច្រើន អស់សង្ឃឹមថានឹងបានរួចចាកពីការ
ទឹកបង្ហាត់របស់បច្ចាមិត្រវិញហើយ ក៏នាំគ្នាផ្ញើរសនាសន្តិ-
ពទៅលើលទ្ធិសាសនាតែសព្វ ៗ ខ្លួន ៗ រាល់ ៗ ថ្ងៃគេតែង
ង្ហាយរកសន្តិភាព ដោយពឹងលើធម៌ព្រះពុទ្ធពុមានលោះ
ន ទោះបើជាយល់ថា ៖ មិនដឹងជាដល់ថ្ងៃណានឹងបាន

សម្រេចក៏ដោយ ៗ សេចក្ដីផុតសង្ឃឹមនេះ យើងឃើញ
ពោះជាមុខវិជ្ជាអ្វីផ្សេង ៗ ក៏ត្រូវផុនជាបផុតដល់ខ្សែ ឬ សូន្យ
ធន់ក៏សឹងមាន ៗ ឯអក្សរសាស្ត្រយើង ក៏ពួនខ្លួនស្ងាត់ឈឹ
សូន្យកណ្ដាលបរាជ័យរបស់ជាតិនោះទៅដែរ តែការស៊ូ
អានុភាពរបស់អក្សរនោះ មិនទាន់ដាច់សូន្យផុតរូបទេ ៗ
កាលណាគេពិនិត្យសង្កេតទៅ ឃើញមួយរំពេចថា អក្ស
សាស្ត្រកំពុងតាក់ស្រេះសរសៃជាប់ នៅក្នុងលទ្ធិពុទ្ធសាស
ដែលបណ្ដាជនយើងកំពុងពឹងផ្អែក ឬ កំពុងប្រសិទ្ធិសុំសេច
សុខសាន្តរាល់ពេល ៗ អានុភាពព្រះធម៌នេះឯង មិនចេះស្ង
ស្ងាត់ទេ តែងតែបានផ្សាយទៅជានិច្ច បន្តកូនចៅជៅសន្ត
រហូតទៅដល់អនាគតវែងឆ្ងាយ ៗ ឯអក្សរសាស្ត្រយើ
ដែលកប់នៅក្នុងនោះក៏ចេះតែបានបន្តសកម្មភាពជាហូរហែ
ជាមួយគេដែរ ៗ ការដេញដោលខាងលើនេះហើយដែល
កស្តុតាង បញ្ជាក់ចំពោះពាក្យថាអក្សរសាស្ត្រផ្តិតជាប់
ក្នុងលទ្ធិពុទ្ធសាសនា ៗ បានសេចក្តីថា សូម្បីតែអ្នកណ

បានរៀនធម៌ឬសូត្រធម៌មួយមាត់ ក៏ទុកដូចជាបានក្រេបរសជាតិអក្សរសាស្ត្រមួយដំណក់ដែរ ហើយរសជាតិនេះមានសភាពត្រជាក់ត្រជំណាស់ផង ។ ព្រះសង្ឃជាធម្មកថិកទាំងឡាយ បានទេសនាណែនាំពុទ្ធបរិស័ទឲ្យដក់ចិត្តតាមឱវាទរបស់ព្រះពុទ្ធ គឺបានប្រើពាក្យផ្សាយនូវស្នាដៃដែលជាគម្ពីរសេចក្តីសំរាយនេះដែរ ។ ចំណែកអ្នកស្រុកអ្នកភូមិក៏ត្រងត្រាប់ស្តាប់យកនូវសេចក្តីទាំងនេះ គ្មានហ៊ានប្រហែសឡើយ ។ ត្រង់នេះឯងក៏បង្ហាញយើងឲ្យឃើញថាអក្សរសាស្ត្រ ចេះតែមានមធ្យោបាយហូរចូលទៅកាន់សន្តានចិត្តរបស់ប្រជាពលរដ្ឋជានិច្ច ។

ក្រៅពីនេះ ព្រះពុទ្ធសាសនាជាទីប្រជុំអក្សរសាស្ត្រយើងមួយផ្នែកយ៉ាងធំទៀត គឺត្រង់ការសិក្សារបស់កុមារខ្មែរក៏សម័យមុន ។ យើងឃើញហើយថា កាលពីពេលដែលយើងត្រូវស្ថិតនៅក្នុងបរាជ័យយ៉ាងស្ងប់ស្ងាត់ សាលារៀនទាំងឡាយមិនទាន់កើតមាននៅឡើយ ។ ដូច្នេះការសិក្សាខាង

អក្សរសាស្ត្រសុទ្ធតែត្រូវផ្សាយចេញពីសំណាក់ព្រះសង្ឃ នៅគ្រប់វត្តគ្រប់អារាមទាំងអស់ ។ កូនអ្នកស្រុកអ្នកភូមិ កាលណាមានអាយុល្មមឲ្យរៀនសូត្រហើយ ឪពុក-ម្ដាយ បាននាំយកទៅផ្ញើឲ្យសិក្សានៅឯវត្ត ដែលមានព្រះសង្ឃជាអ្ន បង្ហាត់បង្រៀនប្រកបដោយមេត្តាធម៌យ៉ាងក្រៃលែង ។

ហេតុការណ៍ដែលបង្ហាញមកខាងលើនេះ នាំឲ្យយើ យល់ច្បាស់លាស់ អំពីការជ្រកបំពួនអាត្មារបស់អក្សរសាស្ត្រ ជាតិយើង នៅក្នុងលទ្ធិពុទ្ធសាសនាដែលជាពិធីផ្សាយមួយ យ៉ាងទូទៅបំផុត ។ ដូច្នេះហើយបានជាសម័យមុននោះ គេនិយាយថា អក្សរសាស្ត្រខ្មែរនៅជ្រកតាមវត្តអារាម ។

## ១_ អក្សរសាស្ត្ររឿងព្រេង

ហេតុម្ដេចបានជាយើងពោលដូច្នេះ ? បើរឿងព្រេងសុ តែជារឿងនិទានដោយមាត់មនុស្សបន្ត ៗ គ្នាទេតើ ? ពិតមែ ហើយរឿងព្រេងជារឿងនិយាយត ៗ គ្នាមែន តែសំដី, ពាក្

ពេចន៍, រឿងកំរ, សំនួនវោហារ, ល្បិចកល ក្នុងរឿងទាំងនោះសុទ្ធតែមានលក្ខណៈជាអក្សរសាស្ត្រជាក់ប្រាកដ ៗ ហើយអក្សរសាស្ត្រប្រភេទនេះ ផ្សាយទូទៅបានរហ័សក្រៃលែង ព្រោះគេផ្សាយទៅដោយពិធីស្តាប់មិនមែនដោយពិធីអានទេ ។ បើយើងអានសៀវភៅរឿងកំរអ្វីមួយ គឺយើងដឹងបានត្រឹមតែរូបយើងមួយប៉ុណ្ណោះ ចំណែកអ្នកដែលមិនបានអានជាមួយយើងទេ មិនអាចដឹងរឿងកំរទាំងនោះដូចយើងឡើយ លុះត្រាតែប្រឹងអានខ្លួនឯងម្តងទៀតទើបបានដឹង ។ ឯរឿងព្រេងដែលនិយាយដោយមាត់មនុស្សវិញ តែមានជនម្នាក់នៅអង្គុយនិយាយហើយ ច្បាស់ជាមានជនអ្នកស្តាប់មិនតិចទេ ហើយអ្នកស្តាប់ទាំងនោះ អាចនិយាយបន្តទៅអ្នកដទៃ ៗ ទៅទៀតជាច្រើនគ្នា ៗ មួយទៀតរឿងព្រេងទាំងនោះ សុទ្ធតែជារឿងសាមញ្ញងាយស្តាប់ងាយយល់ ប្រកបដោយតុក្កកំប្លែងគួរជាគ្រឿងកែកំសាន្ត សំរួលអារម្មណ៍របស់ប្រជាពលរដ្ឋទូទៅ ៗ ពេលគេធ្វើការហត់នឿយ មាន

ការធ្វើស្រែចម្ការច្បារដំណាំជាដើម គ្មានអ្វីមកធ្វើឲ្យគេបំភ្លេ
នូវការនឿយហត់ទាំងនេះបានទេ មានតែរឿងព្រេងប៉ុណ្ណោ
ដែលអាចប្រលោមចិត្តគេឲ្យសោយ ភ្លេចការហត់នឿយលំបា
លំបាកខ្លះ ។ ពេលគេជួបជុំក្រុមញាតិ ឬ មានការប្រជុំ
មួយរវាងអ្នកស្រុកដែលនៅភូមិជិត ៗ គ្នា គេច្រើនតែនាំគ្
និទានរឿងព្រេងជាគ្រឿងកែកំសាន្ត ហើយនឹងបញ្ចោតពេល
វេលា ឲ្យហោះហើរទៅ ដោយឥតស្អុះស្អាប់ក្នុងចិត្ត ។ រឿ
ព្រេងទាំងនេះ មានឯកភាពល្អណាស់ គឺភូមិណាក៏និទានដូ
ជាភូមិណាដែរ ទោះបីជានៅឆ្ងាយពីគ្នាយ៉ាងណាក៏ដោយ ។
បើយើងសង្កេតទៅ ដំបូងឡើងរឿងព្រេង មិនមែនប្រឌិ
កើតដោយមាត់មនុស្សទេ គឺពិតជាមានចារឹកជាក្រាំងឬជា
សាស្ត្រា ប៉ុន្តែក្រាំងឬសាស្ត្រាទាំងនោះអន្តរាយទៅតាមកាល
វេលាដែលកន្លងមកដ៏យូរលង់ ហើយម្យ៉ាងទៀតដោយរឿ
ទាំងនេះបានចាំស្ទាត់ក្នុងមាត់ជនខ្លះទៅ ទៅហើយផង ទើប
ក្រាំងឬសាស្ត្រា ទាំងនេះមិនមែនជាការចាំបាច់របស់ជនសម័យ

នោះឡើយ ៗ ឯការចាំតៗគ្នា បាត់បង់គោលដើមដូច្នេះ
គួរណាស់តែខ្វាត់ខ្វាយព៉ាត់ព៉ាយអស់ហើយ តែនេះមិនដូច
នោះទេ បែរជារឹតតែណាតសន្ធឹងអានុភាពលើសដើមទៅទៀត
ដូចជារឿងធនញ្ជ័យ, រឿងអាឡេវ, រឿងមាយាស្រី, រឿង
ចៅចាក់ស្មុគ, រឿងអាខ្វាក់អាខ្វិន និង រឿងពស់កេងកង
ជាដើម ៗ យើងមិននិយាយទៅពីឧត្តមគតិរបស់រឿងទាំងនេះ
យើងគ្រាន់តែលើកមកបង្ហាញពីអានុភាពអក្សរសាស្ត្រ ដែល
ផ្ដិតជាប់ក្នុងរឿងប៉ុណ្ណោះ ៗ ព្រោះអីអានុភាពនេះ ផ្សាយ
មុតជាប់ទៅក្នុងសន្ដានចិត្តរបស់ជនជាតិយើង ជាជាងគេទាំង
អស់ ៗ សូម្បីតែជនណាមួយ ប្រុសក្ដី ស្រីក្ដី អ្នកចេះដឹងក្ដី
អ្នកល្ងង់ខ្លៅក្ដី សុទ្ធតែបានក្រេបរសជាតិរឿងទាំងអម្បាលនេះ
គ្រប់ ៗ គ្នា បើមិនច្រើនក៏តិចតួចដែរ ៗ នៅគ្រាបច្ចុប្បន្ននេះ
មានអស់លោកអ្នកប្រាជ្ញខាងអក្សរសាស្ត្រជាច្រើនរូប ប្រឹង
ស្រាវជ្រាវប្រមូលឯកសារផ្សេង ៗ ដែលស្ដីពីរឿងព្រេងទាំង-
នេះមកបង្គ្រងឲ្យកើតបានជាសៀវភៅ ដើម្បីទុកតពេល

វេលាទៅមុខឲ្យបានយូរអង្វែង សំរាប់បំពេញបំណងនៃប្រជាពលរដ្ឋយើងទៅគ្រាអនាគតកាល ។

## គ_ អក្សរសាស្ត្ររឿងប្រលោមលោក

ដូចម្ដេចហៅថាអក្សរសាស្ត្រ ជាប់នឹងប្រលោមលោក?

ប្រលោមលោក ឬ រឿងល្ខោន ជាវណ្ណកម្មមួយយ៉ាងល្បីល្បាញរបស់បុព្វបុរសខ្មែរ សម័យអង្គរ នឹង សម័យឧត្តុង្គ ។ អ្នកប្រាជ្ញបណ្ឌិតទាំងឡាយ បានយកចិត្តទុកដាក់ចំពោះកិច្ចការប្រភេទនេះយ៉ាងហ្មត់ចត់ ទោះបីជាប្រទេសជាតិមានចលាចល ឬ មួយជារហូតដល់ធ្លាក់ខ្លួនបរាជ័យទាំងស្រុងក៏ដោយ, ព្រឹទ្ធាចារ្យយើងនៅតែមិនព្រមលះបង់ឧត្តមគតិខាងអក្សរសាស្ត្រនេះឡើយ ។ មួយទៀតយើងក៏អាចជឿបានដែរថា៖ បំណេះវិជ្ជា ឬ គោលគំនិតខាងអក្សរសាស្ត្រជាទ្រព្យផ្ទាល់ខ្លួនជានិច្ច ទោះបីជាជួបនឹងសត្រូវយាយីយ៉ាងណាក្ដី ទ្រព្យធននេះមិនមានអន្តរាយ ឬ សូន្យរូបបាត់បង់ទៅណា

ហើយ គ្រាន់តែត្រូវសម្ងំមួយលើកមួយគ្រាឲ្យផុតពីកលយុគប៉ុណ្ណោះ ៗ ពេលដែលសម្ងំនេះមិនមែនជាពេលសាបសូន្យទេ បែរជាពេលចំរើនដុះដាលទៅវិញ, ដ្បិតពេលសម្ងំ ជាឱកាសបណ្តុះបណ្តាលចិត្តគំនិត សម្រិតសម្រាំង ប្រាជ្ញាស្មារតី បង្កើតឧត្តមគតិខាងអក្សរសាស្ត្រ ឲ្យកាន់តែបានទូលំទូលាយថែមទៀត ៗ លុះដល់ពេលផុតកលយុគវិកវរទៅ ព្រឹទ្ធាចារ្យយើងកាន់តែបានកើតគំនិតប្រាជ្ញា ចេះតែរចនាអក្សរសាស្ត្រឲ្យរឹងរឹតតែបានមាំទាំ និងមានរស្មីពណ្ណរាយ កាន់តែច្បាស់ឡើងៗ ជាលំដាប់ ៗ ម្យ៉ាងទៀត ដោយជំនាន់នោះមានការឧបត្ថម្ភ និងការនិយមវណ្ណគតិនេះគ្រប់តែមជ្ឈដ្ឋានផង គឺប្រជារាស្ត្រទាំងប្រុស - ស្រីសុទ្ធតែនិយមគ្រងគ្រាប់ដូចៗ គ្នា, នាម៉ឺនសព្វមុខមន្ត្រីក៏តែងយកចិត្តទុកដាក់ និងទុកជាគោលសិក្សាខាងអក្សរសាស្ត្រផង ៗ ព្រះមហាក្សត្រទាំងឡាយទ្រង់តែងសព្វព្រះរាជហឫទ័យនឹងវណ្ណកម្មនេះណាស់ ហេតុនេះហើយបានជាគេតែងប្រទះឃើញក្នុងប្រវត្តិសាស្ត្រជាហូរ

ថែហថា ព្រះអង្គទ្រង់បានឧបត្ថម្ភខាងផ្នែកនេះ មិនដែលឈប់ខាន ព្រោះក្នុងពង្សណាក៏ដោយ យើងតែងប្រទះឃើញមានកវីបណ្ឌិត នឹង កវីជាច្រើននៅជិតខាងព្រះអង្គជាធម្មតា ។ ពេលដែលទ្រង់យាងទៅណាមកណា ឬ យាងក្រសាលទីណាមួយ កវីបណ្ឌិតតែងតែតាមដង្ហែផ្ទាល់ព្រះរាជាជានិច្ច ។ ដូច្នេះឯង ទើបយើងនៅសល់គ្រឿងតំណាលជាស្នាដៃកវីបុរាណជាច្រើន ដែលមានការម្កកថាប្រាប់យើងថា៖ កាលគ្រាដែលលោករៀបរៀងរឿងនេះឡើងនៅក្នុងព្រះរាជូបត្ថម្ភ នៃព្រះមហាក្សត្រ ។ សរុបសេចក្ដីដែលយើងអធិប្បាយខាងលើនេះ បញ្ជាក់ឲ្យយើងឃើញប្រភពនៃការបង្កើតវណ្ណកម្មសម័យនោះ ។

បន្ទាប់ទៅទៀតយើងស្រាវជ្រាវពីអានុភាពរបស់វណ្ណកម្មនេះមុន ។ ប្រជាជាតិខ្មែរយើងមានមតិកមួយយ៉ាងសំខាន់ខាងផ្នែកអក្សរសាស្ត្រ គឺសាស្ត្រារឿងទាំងឡាយ, បើយើងហៅតាមភាសាធម្មតាគឺជារឿងប្រលោមលោក, ដែលសុទ្ធសឹងតុប

តែងទៀនដោយសារស្នាដៃកវីខ្មែរយើងពីព្រេងនាយ ៗ ហេតុដែលនាំឲ្យមានអានុភាព រឿងក្នុងសាស្ត្រាទាំងនេះបានបាចសាចចូលជោគជាំក្នុងសន្តានចិត្តប្រជាពលរដ្ឋយើង គ្មានបន្លោះជនណាមួយនោះ ព្រោះរឿងទាំងនេះ សុទ្ធសឹងជាគ្រឿងបំពេញចិត្ត, បំពេអារម្មណ៍របស់ជនទូទៅ សូម្បីតែជននោះមិនចេះអក្សរមួយតួសោះ ក៏ចេះចូលចិត្តជាប់សិតក្នុងរឿងទាំងនោះដែរ ៗ ឯលំនាំគំនិតក្នុងរឿងនោះសោតទៀត អ្នកនិពន្ធច្រើនទាញយកគោលការណ៍ នៃទ្រឹស្តីលទ្ធិសាសនាមកលាតត្រដាងផង ដែលជាគំនិតមួយដែលបណ្ដាជនខ្មែរនិយមគោរពកប់អានមកហើយស្រាប់ ៗ

ត្រង់នេះនាំឲ្យយើងធ្លុះមើលឃើញថា កវីបុរាណទាំងនេះ សុទ្ធតែជាអ្នកគោរពព្រះពុទ្ធសាសនា, ដោយលើកទ្រឹស្តីព្រះពុទ្ធមកធ្វើជាគោលក្នុងរឿង គឺកម្មផលដែលនឹងតាមជួយជ្រោមជ្រែង ឬ តាមផ្ដន្ទាដល់អ្នកដែលបានប្រព្រឹត្តរួចមកហើយ ៗ សរុបគោលគំនិតទៅ ឃើញថាកវីពុទ្ធសាសនា

ទាំងនោះបញ្ជាក់ឲ្យច្បាស់លាស់ថា "អធម៌" តែងតាញ "ធម៌" ជាដរាប ។ ប៉ុន្តែមុននឹងតាញ "អធម៌" បានធ្វើខ្ទួបុកម្ទេញ "ធម៌" ឲ្យលិចមិនលំបាក តោកយ៉ាកជាយូរ យូរថ្ងៃណាស់ដែរ ។ ត្រង់ដែលការត្រដាងបង្ហាញអំពើអាក្រក់ បីដូចជាចង់ទាញសតិអារម្មណ៍អ្នកអានឲ្យជួយស្អប់, ជួយខឹង ជួយប្ដឹងគេខុសត្រូវលើរូបតួសុចរិត នឹងទុច្ចរិតនេះហើយ ដែលធ្វើឲ្យផ្ទៃរឿងបានវែង នឹងបានជាគ្រឿងលួងលោម ជនានុជនឲ្យអណ្ដែតសោតទៅតាមខ្លួន ។ ប៉ុន្តែបើយើង សង្កេតឲ្យល្អិតល្អន់ទៅឃើញថា ផ្ទៃរឿងទាំងនោះមិនសុទ្ធតែ ត្រូវហើយល្អវិសេសទេ គឺគេអាចរិះគន់បានជាច្រើនណាស់ ដែរ ដូចជាការប្រើវត្ថុហួសវិស័យឬខានបច្ចេកទេស នៃការ សរសេរជាដើម ។ តែទោះជាយ៉ាងណាក៏ដោយ យើងត្រូវ តែទទួលស្គាល់ថា សាស្ត្រាទាំងនេះពិតជាវណ្ណកម្មគ្រាកាល មួយ ដែលបានសាបព្រោះពូជជាអក្សរសាស្ត្រ ឲ្យដុះដាល

ពេញពលពេញកាលក្នុងប្រទេសយើង ត្រាតែបានមកដល់យើងកល់គ្នាក្នុងសម័យនេះ ។

បើយើងពោលពី លក្ខណៈអក្សរសាស្ត្រ របស់រឿងទាំងនេះវិញ យើងមិនសូវមានការរិះគន់ទេ ព្រោះកវីបុរាណលោកច្រើនសរសេរ សុទ្ធតែជាពាក្យដែលមានចុងជួនរណ្ដំគ្នាយ៉ាងល្អងល្អយប្លែកពីអក្សរសាស្ត្ររបស់ជាតិនានា ។ ក្នុងផ្ទៃរឿងទៀត ក៏សុទ្ធតែលេងសំនួនពេហារយ៉ាងណែនណាន គួរឲ្យសរសើរ គឺមានការដាក់ស្ពង់, ការប្រៀបធៀប, ការស្រមៃរវើរវាយ សមទៅតាមផ្ទៃរឿងគ្មានខ្ចោះ ។

ចំពោះពាក្យពេចន៍ដែលប្រើក្នុងរឿងទាំងនេះ សុទ្ធតែជាពាក្យមានគុណភាពខ្ពស់ គឺច្រើនជាពាក្យចេញមកពីបាលី-សំស្រ្កឹតមិនសូវមានពាក្យសាមញ្ញទេ ។ បានជាសរសេរយ៉ាងនេះ ប្រហែលជាបុព្វបុរសយើងនឹកឃើញថា ស្នាដៃទាំងនេះ គាត់បំរុងទុកឲ្យមានដម្លៃរហូតរាប់ពាន់ឆ្នាំដូចការពិតដែលយើងប្រទះសព្វថ្ងៃនេះដែរ ឬ អ្វី ? ៖ ព្រោះពាក្យ ថ្លៃថ្នូរ

បែបនេះមិនឆ្ងាយ សាបរលាបទេ ឯពាក្យសាមញ្ញវិញ តែងធាប់អស់អាយុ ព្រោះក័ន្តែប្រែទៅតាមកាលៈទេសៈជាញឹកញាប់ ៗ

រឿងទាំងនេះ មិនត្រឹមតែជារឿងប្រលោមលោកមានចារទុកក្នុងសាស្ត្រាប៉ុណ្ណោះទេ អ្នកប្រាជ្ញសម័យដើមបានប្រឌិតយកទៅធ្វើជារឿងល្ខោនបានទៀត ឥតប្រកាន់ថារឿងណាជារឿងណាឡើយបានដូច ៗ គ្នា ៗ ព្រោះខ្មែរយើងជាជាតិមួយមានសិល្បៈរបាំមុនគេបំផុតនៅជ្រោយសុវណ្ណភូមិ ៗ ជាកស្តុតាង គឺរឿងរាមកេរ្តិ៍ ដែលសរសេរឡើងជាបទល្ខោនសុទ្ធ ៗ លាយចំរុះទាំងក្បាច់រាំរែកក្នុងនោះផង ៗ រឿងរាមកេរ្តិ៍ គេអាចស្មានបានថារឿងនេះមិនមែនមានកំណើតក្រោយសម័យអង្គរទេ ពិតជាកើតឡើងមុនពេលកសាងអង្គរទៅទៀត ព្រោះពាក្យពេចន៍ក្នុងនោះសុទ្ធតែជាពាក្យខ្មែរបុរាណវែងឆ្ងាយ នឹងប្របូកដោយពាក្យសំស្ក្រឹតផង ព្រោះសម័យមុនអង្គរជាសម័យស៊ីវិល័យសំស្ក្រិត គឺគ្រាដែលលទ្ធិ

ព្រហ្មសាសនា នឹងពុទ្ធសាសនាមហាយាន នៅមានឫទ្ធិលើដែនខ្មែរនៅឡើយ ។ ក្រោយពីនេះ មានចំឡាក់នៅជញ្ជាំងថែវអង្គរវត្តជាកស្តុតាងទៀត ព្រោះលក្ខណៈរបស់រឿងក្នុងចំឡាក់នោះពិតជាដូចរឿងក្នុងសាស្ត្រាដែរ ហើយរឿងរាមកេរ្តិ៍ខ្មែរនេះ មិនមែនដូចសុទ្ធសាធនឹងរឿងរាមាយណៈនៃឥណ្ឌាទេ គ្រាន់តែមានការប្រឌិត ១ ប៉ុណ្ណោះ ឯសាច់រឿងគឺគុបតែងជាបែបស្មាដៃខ្មែរពិតប្រាកដ ។ ដូចយើងបានពោលមកហើយថា មិនត្រឹមតែរឿងរាមកេរ្តិ៍ដែលសរសេរជាបែបល្ខោនប៉ុណ្ណោះទេ សូម្បីរឿងដទៃ ១ ទៀត ដូចរឿងសង្ខសិល្បជ័យជាដើម ក៏ខ្មែរប្រឌិតយកទៅលេងជាល្ខោនបានដែរ ។ គឺវង់ល្ខោនទាំងនោះហើយ ដែលនាំយកអក្សរសាស្ត្រខ្មែរដែលផ្តិតជាប់ក្នុងរឿងទាំងនោះ ទៅផ្សាយនៅគ្រប់ទិសទីក្នុងអាណាចក្រខ្មែរ ។

សរុបសេចក្តីទៅ គឺរឿងប្រលោមលោកខ្មែរនេះហើយដែលជាប្រែកពូផ្សាយនូវអក្សរសាស្ត្រ. របស់ជាតិឲ្យបានសុស

សាយខ្ញុំទៅក្នុងចិត្តបណ្ដាជនខ្មែរយើង ។ ដោយមានសេចក្ដី
ពិស្ដារដូចពោលមកខាងលើនេះឯង ទើបយើងពោលថាអក្សរ
សាស្ត្រខ្មែរ ផ្ដិតជាប់ក្នុងរឿងប្រលោមលោកនិងរឿងល្ខោន ។

## ឃ- អក្សរសាស្ត្រសិលាចារឹក

យើងឃើញហើយ សិលាចារឹកមិនត្រឹមតែជាគោល ចារឹកកត់ត្រាពត៌មាន ទុកឲ្យយើងដឹងជានពីប្រវត្តិសាស្ត្ររបស់ ជាតជាអន្លើងមកហើយប៉ុណ្ណោះទេ ។ សិលាចារឹកជាប្រភព អក្សរសាស្ត្រមួយយ៉ាងសំខាន់បំផុត ។ សម័យដែលខ្មែរ កសាងអារ្យធម៌ជាដំបូង តាំងពីសតវត្សទី ១ នៃគ្រិស្តសករាជ គេអាចដឹងបានដោយសារសិលាចារឹកជាអក្សរខ្មែរ ដែលនៅ សល់ពាសពេញក្នុងអាណាចក្រខ្មែរបុរាណ តែឥឡូវត្រូវបែក ខ្ញែកទៅឯបរទេសជិតខាងខ្លះទៅហើយ ដូចជាសិលាចារឹក ខ្មែរនៅលពបុរី (ប្រទេសថៃ) និងនៅ មីសឺន-ញ៉ាត្រាំង (ប្រទេសវៀតណាម) ជាដើម ។ លក្ខណ៍គោលតាំងនេះ

ខ្វែតសរសេរជាអក្សរខ្មែរបុរាណពិត ៗ មិនដែលទៅខ្ចី ឬ
ចអក្សររបស់ជាតិណាមកចារភ្ជាប់នឹងថ្មទាំងនោះឡើយ ។
សិលាចារឹក ជាឃ្លាំងមួយផ្ទុកនូវកំណប់អក្សរសាស្ត្រខ្មែរ
ងពីកើតមានអារ្យធម៌មក ហើយកំណប់នេះជាកំណប់
ទ្ធសាធឥតមាននរណាកាឡៃបានឡើយ ។ នៅក្នុងផ្ទាំង
មួយ ៗ សុទ្ធសឹងវិចិត្រទៅដោយពាក្យពេចន៍ស្រស់ចំណាន
ដែលកើតឡើងដោយស្នាដៃកវីខ្មែរពីព្រេងនាយ ៗ ប៉ុន្តែពាក្យ
ាំងនោះ ច្រើនតែជាពាក្យសំស្ក្រឹតសុទ្ធ ៗ ព្រោះសម័យនោះ
ាសម័យស៊ីវិល័យសំស្ក្រឹត គេប្រើភាសាសំស្ក្រឹតជាផ្លូវការ
ប់កប់ប្រទេស ។ មួយទៀត ភាសាសំស្ក្រឹតនេះជាភាសា
ប់កប់អ្នកប្រាជ្ញឬអ្នកមានយសសក្តិខ្ពស់ បានសេចក្តីថា ជា
ាសារុងរឿងរបស់ជាតិយើងកាលយុគនោះ ។ ពិតមែន
ហើយតែអក្សរសាស្ត្រ ដែលផ្តិតជាប់ក្នុងសិលាចារឹកនេះ
មិនសូវមានអានុភាពជ្រួតជ្រាបចូលទៅជ្រៀមសព្វសាយក្នុង
ឋានចិត្តបណ្តាជនខ្មែរ ដូចសាស្ត្រារឿងប្រលោមលោក ឬ

រឿងព្រេងមែន តែក៏បានជាគ្រឿងដំណែល ធៀបដូចជាកញ្ច
មួយទុកសំរាប់ឲ្យជនជាតិយើង ជាន់ក្រោយឆ្លុះមើលពតិមា
ប្រព្រឹត្តិការណ៍ផ្សេង ៗ ដែលកើតមានឡើងក្នុងគ្រាអតីតកា
ដ៏យូរអង្វែង ៗ ក្រៅពីនេះទៀត សិលាចារឹកជាគ្រាំងវិសេ
មួយ ដែលដូនតាយើងបេះរិះរកឃើញពិធីផ្លាញ់ពេលវេ
គឺធ្វើឲ្យបានគង់វង្សរូបភាពអក្ខរៈសម័យ បន្តគ្នា ជាលំដាប់ហូ
ហែ ទុកសំរាប់ឲ្យយើងដឹងស្គាល់ពីរបៀបសរសេរអក្សរខ្
តាំងពីសតវត្សទី ៣ មក ជាប្រយោជន៍យ៉ាងសំខាន់ដល់យើ
ដែលត្រូវការសិក្សាពីកំណើតអក្សរសាស្ត្រ និងពីវិធីស្រាវជ្រា
ខាងវេយ្យាករណ៍ ។ បើយើងពិនិត្យឃើញមួយភ្លែត អក្ស
ដែលចារលើថ្មតាំងនេះហាក់ដូចជាតិចតួចមិនសំខាន់ប៉ុន្មាន
តែបើសង្កេតឲ្យវែងឆ្ងាយទៅ ទើបយល់ថា៖ ពាក្យតិចតួ
នេះឯង «ជាខ្លឹម» ដ៏សំខាន់ អាចឲ្យអ្នកផងបកស្រាយបា
ជាសេចក្តីវែងទូលំទូលាយក្រៃលែង គឺអាស្រ័យការទទួល
ជោគជ័យ ឈ្នះពេលវេលារបស់ដុំថ្មតាំងនេះហើយ ដែល

ស្រាវជ្រាវក្នុងគ្រាបច្ចុប្បន្ន អាចបកស្រាយបរិយាយបាន
វហាពីអក្សរសាស្ត្រ, ប្រវត្តិសាស្ត្រ និងអារ្យធម៌នរឿង
ស់ជាតិយើងពីព្រេងនាយ ។ អាស្រ័យៈលើហេតុផល
ពេលមកនេះឯង ទើបយើងហ៊ានឲ្យឈ្មោះថា «អក្សរ-
សាស្ត្រផ្ទិតជាប់នឹងសិលាចារឹក» ។

## ង_ អក្សរសាស្ត្រខាងបច្ចេកទេស

ពាក្យថាបច្ចេកទេសក្នុងទីនេះ ពោលសំដៅស្នាដៃណា
លស្ដីពីវិជ្ជាឯកទេសដោយឡែកពីគេ ។ យើងនឹងបក
ាយពន្យល់សេចក្ដីខ្លួតទៅ៖ ច្បាប់ទំលាប់ទាំងឡាយជា
បញ្ញត្តិផ្សេងៗ សំរាប់របៀបគ្រប់គ្រងរដ្ឋ ជាអក្សរសាស្ត្រ
គេពាក្យរាយ ហើយជាផ្នែកបច្ចេកទេសផង ដែលជា
ណ្ណកម្មជាន់ខ្ពស់ តែមិនសូវបានផ្សាយទូទៅគ្រប់ទិសដែន
បរឿងប្រលោមលោក, រឿងល្ខោន ឬ រឿងព្រេងទេ ។
ក្នុងផ្នែកនៃវណ្ណកម្មនេះ ច្រើនពោរពេញទៅដោយពាក្យ

បច្ចេកទេសខាងច្បាប់សំរាប់ស្រុក ដែលយោលទៅតាមទម្
របស់គាសាអ្នកស្រុក បាននិយាយបន្ត ៗ តាំងពីអង្វែងកា
មក ៗ អក្សរសាស្ត្របុរាណនេះ មិនមែនមានមកតាំងពីប
យាយហើយទេ ព្រោះគេមិនប្រទះឃើញមានក្រាំង ឬ ចារឹក
គោលសំខាន់នៅក្នុងសិលាចារឹក ឬ គម្ពីរសាស្ត្រាឯណាតាំ
មុនសម័យអង្គរ ឬ ត្រឹមអង្គរទេ គឺគេឃើញមានតែច្បាប់ដ
សរសេរលើក្រដាស ដែលរៀបចំក្រងត្រឹមពេលមុនសម័
ឧត្តុង្គ ឬ ត្រឹមសម័យឧត្តុង្គប៉ុណ្ណោះ ៗ ច្បាប់ដើមទាំងនេ
មាននៅគង់ទ្រង់រហូតសព្វថ្ងៃ ដែលក្រុមពុទ្ធសាសនបណ្ឌិ
បានថែទាំទុកយ៉ាងមធ្យ័ត ដែលគេឲ្យឈ្មោះថា « ព្រះរា
ក្រិត្យក្រមផ្សេង ៗ » មានទាំងអស់ ២៤ ក្រម គឺមានក្រមឧទ្
ក្រមចែកពល, ក្រមទសករិយា ជាដើម ៗ ឯសេចក្ដីបរិយា
របស់ក្រិត្យក្រមទាំងនេះ ចែកដោយខ្សែក ៗ ពីគ្នា គឺមា
និយាយពីច្បាប់ទម្លាប់របស់គង់យោធា, ពីច្បាប់កាត់ក្ដីផ្សេង
នឹងរបៀបទារពន្ធដារដាក់ឃ្លាំងពជការជាដើម ៗ ស្នាដៃទាំ

ះ ប្រឌិតឡើងដោយអ្នកប្រាជ្ញខាងច្បាប់បុរាណជាច្រើនរូប
ាយមានព្រះមហាក្សត្រនៅសម័យនោះទ្រង់ជាមគ្គុទ្ទេសក៍
៍ការរៀបរៀងនេះផង គឺចាប់តាំងពីរជ្ជកាលព្រះបាទជ័យ-
ដ្ឋាមក ។ យើងគួរសរសើរម្យ៉ាងទៀតចំពោះស្នាដៃទាំងនេះ
ោះបុព្វបុរសយើងសម័យនោះនឹកឃើញគំនិតម៉ាំទាំ បាន
ងប្រែងរៀបចំច្បាប់ទម្លាប់ សំរាប់ស្រុកទេស ចារឹកទុកជា
ក្ខណ៍គោល កុំឲ្យនាម៉ឺនសព្វមុខមន្ត្រីទាំងឡាយព្រួយពិបាក
ះរិះដោយមតិខ្លួនឯងផង ទាំងឲ្យមានឯកភាពក្នុងការអនុវត្តន៍
ាប់សំរាប់រដ្ឋផង ។ សេចក្តីពិនិត្យសង្កេតទាំងនេះឯងហើយ
ែលយើងសំគាល់ថា៖ ជាអក្សរសាស្ត្របច្ចេកទេស ។

## ច-អក្សរសាស្ត្រខាងចម្រៀង

នៅវគ្គចុងបំផុត យើងត្រូវបរិយាយពីអក្សរសាស្ត្រជាប់
ងចម្រៀង ។

ចំរៀងខ្មែរបុរាណ សុទ្ធសឹងប្លែក ៗ ពីគ្នាជាច្រើនបែប

ច្រើនយ៉ាង គឺមានចម្រៀងបំពេកូន, ចម្រៀងការ
ចម្រៀងលួងលោម និងចម្រៀងបន់ស្រន់ ។ល។ តទៅនេះ
សូមលើកយកមួយផ្នែកៗ មកធ្វើអត្ថាធិប្បាយជាបន្តៗគ្នា

១- ចម្រៀងបំពេក្មេង.– ចំរៀងនេះច្រើនប្រ
ដោយបទបែបយ៉ាងស្រងូតស្រងាត់ និងពាក្យពេចន៍ទន់
ជំណាន់សំដីថ្នាក់ថ្នមរបស់មាតាដែលពោរពេញទៅដោយ
សប្បុរសយ៉ាងក្រៃលែង ។ គេសង្កេតឃើញ ចម្រៀងប្រ
នេះមោះមុតជាងចម្រៀងនានា ព្រោះវាធ្វើឲ្យនារីខ្មែរដែ
ស្រគត់ស្រគំតាមការឃុំគ្រងរបស់ប្រពៃណីជាតិ ដាច់ចិ
អាចកាត់សេចក្ដីខ្មាសអៀន ហាមាត់ស្រែកច្រៀងបំពេកា
ឬ កុមារតូច ពត់សំឡេងទៅតាមបទយ៉ាងពិរោះល
លន្ទោច ។ ឯការហាមាត់ច្រៀងនេះ នាងនារីពុំដែលបា
ហាត់ពីមុនមកម្ដងសោះ ប៉ុន្តែហាក់ដូចចម្រៀងនោះ ជាទេ
កោសល្យដុះដាលជាស្រេចក្នុងសន្ដានចិត្តរបស់នាង ជាយ
មកហើយ ។ ឯទំនុកសោតក៏ជិតជាប់នូវលក្ខណៈអក្សរសា

នលំអៀង  គឺត្រូវតាមគន្លងបង្អាក់កាព្យឃ្លោងខ្មែរ  ទំនង
បស់បំព្រងដោយសំនួនវោហារពាក្យពេចន៍គគ្លោះផង ៗ
ក្សរសាស្ត្រប្រភេទនេះឯង  បានជ្រាបចូលក្នុងសន្តានចិត្តនៃ
នខ្លួនទៅមុនគេបំផុត  គឺតាំងពីពេលនៅជាទារកនៅឡើយ ៗ
នសេចក្តីថា  កាលនោះទារកបេះបាត់មាត់ស្ងៀមប្រុងស្តាប់
រឡើង  ទំនងសំដីរបស់មាតាច្រៀងបំពេរ  គឺទារកបានក្រេប
ញ្ចក់ខួរសជាតិឆ្ញាញ់ពិសា      នៃអក្សរសាស្ត្រក្នុងចម្រៀង
ក៏ងពិរោះក្រវេបស់មាតា ៗ

២- ចម្រៀងការងារ .— ចម្រៀងប្រភេទនេះជា
ណានជីវភាពរបស់អ្នកស្រុកពិត ៗ ៗ គេច្រៀងចម្រៀងនេះ
នៅក្នុងពេលធ្វើការដូចជាពេលស្ទូងស្រូវ,  ពេលបែនស្រូវ
ពេលសំពកក្នុងការងារអ្វីមួយ  ៗ  ក្នុងពេលដែលប្រកបការ
ញាក់ច្បាំងហាលកំដៅព្រះអាទិត្យ,    ហាលខ្យល់ព្យុះ  ឬ
ណ្តាលធាតុត្រជាក់  គ្មានអ្វីក្រៅពីចម្រៀងនេះទេ  ដែល
ចមកជួយបំពេ ឬ មកក៏ប្រោសបេះដូងកសិករយើង  ឲ្យបាន

ធូរស្រាលលំហែកាយខូលាយចិត្តបានមួយជនមួយកាល ឯសេចក្តីទំនុកសោក យើងតែងប្រទះឃើញ ស្ទ... ជាពាក្យប្រកបការដូចជាថ្លែងពីការស្ទូងដក, ការបោកបែ... ដើម្បីយកផលសំរាប់គ្រួសារជាដើម ។ ឯពាក្យពេចន៍ទាំងនេ... មានក៏លក្ខណៈជាអក្សរសាស្ត្រស្រស់បំព្រងដែរ ។

៣– ចម្រៀងលួងលោម.– ចម្រៀងនេះច្រើនជ... ពាក្យផ្តាះផ្គងគ្នាវែងកំឡោះក្រមុំ ប៉ុន្តែពាក្យផ្តាះផ្តងនេះសុ... តែប្រកបដោយកិរិយាថ្លៃថ្នូរ មានចម្រៀងប្រៃកទឹងចម្រៀ... ពោលលួងជាដើម ។ គេនិយមចម្រៀងនេះនៅពេលណា... ដែលផុតពីការងារ ដូចជាពេលផុតរដូវច្រូតកាត់ដែលគេបា... ផលស្រូវដាក់ជង្រុកហើយ, គេក៏នាំគ្នាធ្វើបុណ្យធ្វើទានផ្កា... ការងារ ។ ពុំនោះទេ នៅឱកាសបុណ្យចូលឆ្នាំ ឬ បុណ្យ... ភ្ជុំបិណ្ឌជាដើម ។ គ្រាណាគេបើកឱកាសលេងចម្រៀងនេ... យុវក-យុវតីទាំងឡាយបានសប្បាយលើសលែង ព្រោះគេបើ... សេរីភាព ឲ្យផុតពីប្រពៃណីតឹងតែងបានមួយពេល ...

ប់ណែកមាតា-បិតាវិញ ក៏បានសប្បាយរីករាយជាមួយកូន
នោះទៅដែរ ។ ចំរៀងផ្ដោះផ្ដងនេះ មានសេចក្ដីលែបខាយ
តាមលក្ខណៈអក្សរសាស្ត្រដែរ ព្រោះមានល្បិចកល និង
សំនួនពាក្យពេចន៍យ៉ាងថ្ងៃថ្នូរ ។

៤-ចម្រៀងបន់ស្រន់ . ចម្រៀងប្រភេទនេះ
សម្ដែងឡើងជាដំណាងចិត្តអស់សង្ឃឹម ដែលផុតវិស័យ
នឹងទុកចិត្តបាន ក៏ដាច់ចិត្តពោលពាក្យទន់ខ្សោយអង្វរគេ ឬ
អំពាវនាវរកវត្ថុស័ក្ដិសិទ្ធទាំងឡាយ ឲ្យជួយរំលែកទុក្ខ . ឲ្យ
ធ្វើជាសាក្សី នៃសេចក្ដីអស់សង្ឃឹម នឹងឲ្យជួយសំរាលសេចក្ដី
ឈឺចាប់ដោយប្រការណាមួយ ។ ចម្រៀងនេះមិនសូវបាន
ទទួលសេចក្ដីនិយមពីជនគ្រប់មជ្ឈដ្ឋានទេ គឺមានតែអ្នកកាន់
គំនិតទន់ខ្សោយប៉ុណ្ណោះដែលចូលចិត្តកាន់ជាងគេ ប៉ុន្តែ
សេចក្ដីបន់ស្រន់នោះក៏ផ្អែមល្ហែម ផ្ដេកទៅលើលក្ខណៈអក្សរ-
សាស្ត្រប្រភេទទន់ភ្លន់ គួរអោយណោចអធ័មណាស់ដែរ ។

៥-ចម្រៀងប្រពៃណី .- ចម្រៀងប្រពៃណីគេ

និយមតាមពេលតាមវេលា គឺនៅគ្រាណាដែលគេរៀបធ្វើពិធី អ្វីតាមទំនៀមទំលាប់ ដូចជាពេលរៀបអាពាហ៍ពិពាហ៍, ពេល បុណ្យអុំទូកនឹងពេលបុណ្យឡើងអ្នកតាជាដើម ។ ចម្រៀង ប្រភេទនេះ ជាចម្រៀងពិសេសដែលត្រូវតាមគន្លប្រពៃណី សំរាប់ស្រុក ហើយច្រើនមានគ្រាំងចងទុកជាក្បួនខ្នាតតកូនចៅ ថែមទៀតផង បង្ហាញឲ្យឃើញថា៖ ចម្រៀងបែបនេះគេអាច ទុកជាចម្រៀងផ្លូវការ ។ ការចារឹកទុកជាក្បួនយ៉ាងនេះ រឹតតែ នាំឲ្យយើងឃើញច្បាស់លាស់ ថាពិតជាមានលក្ខណៈអក្សរ-សាស្ត្រមាំទាំបរិបូណ៌លើសចម្រៀងមុនៗ ទៅទៀត ។

សេចក្តីអធិប្បាយរបស់យើង យ៉ាងហូរហែខាងលើនេះ ជាគ្រឿងបញ្ជាក់បង្ហាញលោកអ្នកអាន ពីជម្រៅអក្សរសាស្ត្រ យើង ដែលមានប្រភពជាច្រើនបានផ្សាយឲ្យហៀរហូរ ពេញ ទិសដំបន់តាំងពីបុរាណមក ។



## ជំពូកទីបី

# ចលនាអក្សរសាស្ត្រខ្មែរ

ក្នុងអក្សរសាស្ត្ររបស់ជាតិនីមួយ ៗ តែងតែមានចលនាពិសេស ៗ ពីគ្នា អាស្រ័យទៅតាមពេលវេលា ដែលជំនឿ ឬការចូលចិត្តរបស់អ្នកស្រុកផ្តេកទៅលើទ្រឹស្តី ឬ គោលគំនិតណាមួយ ៗ អក្សរសាស្ត្រខ្មែរក៏មានចលនាប្លែក ៗ គ្នាដែរ ព្រោះខ្មែរជាជនជាតិមួយ មានជំនឿនិងការប្រគល់នូវគោលគំនិតទៅលើទ្រឹស្តីអ្វី ៗ ដែលយល់ឃើញថាមានប្រយោជន៍សំខាន់ ឬ ដែលខ្លួនចូលចិត្ត ។ យើងល្បងសង្កេតរកប្រភេទនៃចលនាទាំងនោះដូចតទៅ ៖

- ចលនាព្រហ្មនិយម ,
- ចលនាពុទ្ធិនិយម

ចលនាខេមរនិយម ,

ចលនាបរទេសនិយម ,

ដើម្បីឲ្យស្គាល់ច្បាស់អំពីចលនា នៃអក្សរសាស្ត្រយើង ទាំង៤ប្រភេទដែលកប់មកខាងលើនេះ យើងធ្វើការអធិប្បាយ វែកញែកឲ្យច្បាស់លាស់នៅខាងក្រោម ព្រោះចលនានិមួយៗ រមែងមាននិន្នាការអំពីអ្វីប្លែកៗ គួរឲ្យអ្នកសិក្សាកត់សំគាល់៖

## ១_ ចលនាអក្សរសាស្ត្រ ព្រហ្មនិយម

ដែលហៅថាអក្សរសាស្ត្រព្រហ្មនិយម ក្នុងទីនេះ គឺ សំដៅដល់វណ្ណកម្មទាំងឡាយណា ដែលផ្តោតគោលគំនិត ទាំងស្រុងទៅលើលទ្ធិព្រហ្មញ្ញសាសនា ។ លទ្ធិនេះ បាន សន្មតយកតួអង្គព្រះព្រហ្ម, ព្រះឥសូរ និង ព្រះនារាយណ៍ ធ្វើជាវត្ថុសក្តិសិទ្ធ, ជាទីគោរពសក្ការៈ ។

ក្រោយដែលជនជាតិឥណ្ឌាបានចូលមកយកជោគជ័យ នៅលើដែនដីខ្មែរ (សម័យហ្វូណន) ហើយអ្នកអន្តោប្រវេសន៍

ពាំងនោះ បានពាំងនាំយកលទ្ធិសាសនាដែលជាមេគំនិតមកជាមួយផង ហើយបាននាំគ្នាសាងព្រះជំនឿសាសនានេះពេញលើផែនដីកម្ពុជាយើង ។ ហេតុនេះហើយបានជាយើងឃើញអត្ថបទនៅក្នុងសិលាចារឹកក្តី នៅក្នុងរឿងបុរាណក្តី រមែងតែសរសេរជាភាសាសំស្ក្រឹត ដែលជាភាសាផ្លូវការសំរាប់សាសនាព្រាហ្ម ព្រមទាំងពោលពីឫទ្ធិបារមីទេវតារបស់អង្គអវតារនៃសាសនានេះផង ។ ដើម្បីឲ្យមានភស្តុតាងច្បាស់លាស់ យើងលើកយកន័យរបស់សិលាចារឹកខ្លះមកធ្វើជាគំរូយ៉ាងនៅខាងក្រោម សំរាប់ឲ្យអ្នកសិក្សាស្គាល់ជំរៅនៃទិន្នាការរបស់ជំនឿនិមួយ ៗ ដែលជ្រាបចូលក្នុងអក្សរ-សាស្ត្រយើង៖

« ...ទ្រង់យានឆ្លងកាត់សមុទ្រនៃគុណ មានចិន្តារីកកាយ ទឹង
« ទ្រទ្រង់ផែនដី ព្រះអង្គបីបមលក្ស្មីជានិច្ច ដូចជាព្រះវិស្ណុ
« មានព្រះហស្ត ៤ ។

(សិលាចារឹកប្រាសាទករណោលដើម)

«... សូមព្រះសិវៈ ដ៏មានជតាធំ ហើយដែលមានបាទា
« ធ្ងន់លើសលែង, អាចជាន់ករណាទសមុទ្រឲ្យប៊ូរំពងអាកាស
« បាន, មកជួយព្យាបាលនូវសម្បត្តិរបស់អ្នក ។

(សិលាចារឹកភ្នំបាយ័ន)

«... កាលយល់ព្រះអង្គទ្រង់ធ្បឹតយ៉ាងតឹង បីដូចព្រះសិវៈ
« នៅត្រីបុរន្ត, ពួកបច្ចាមិត្រ ក៏ដឹងជាក់នូវសេចក្ដីវិនាសរបស់
« ខ្លួន ។

(សិលាចារឹកប្រាសាទខ្នា)

អត្ថបទខាងលើនេះ យើងឃើញអ្នកនិពន្ធបានលើក យកព្រះនាមព្រះវិស្ណុ ព្រះសិវៈដ៏ជាទីគោរពរបស់គេមកធ្វើ ជាត្រីមុខ ។ ក្រៅពីនេះ យើងប្រទះគុណវណ្ណកម្មជារឿងក៏រ ផ្សេងទៀត ដូចជារឿងមហាភារតៈដែលមានពួកអសុរនឹង ពពួកទេវតា នាំគ្នាយកនាគធ្វើព្រ័ត្រទាញល្បែងកំឡាំងក្នាល់ យកសមុទ្រទឹកដោះ ។ កាលនោះ ពួកយក្សយកបានខាង ក្បាលនាគ ដែលនាំឲ្យមានកំឡាំងកាន់តែខ្លាំងឡើងទៀត ។

យល់ច្បាស់ថាពួកទេវតាចាញ់កលយក្សហើយ ព្រះនារាយណ៍
ក៏បានបែងភាគ ចុះមកជួយយកអាសារពពួកទេវតាដែលជា
និមិត្តរូបនៃសេចក្តីសប្បុរស ។

នៅក្នុងរឿងរាមកេរ្តិ៍និទានពី ព្រះរាមជាអង្គអវតារនៃព្រះ
នារាយណ៍ ដែលបែងភាគចុះមកជួយរកយុត្តិធម៌ របស់សត្វ
ក្នុងភពទាំងបី គឺឋានសួគ៌, ឋានមនុស្ស និងឋាននរក ។
ដូចនេះឯង ទើបគេឃើញក្នុងរឿងរាមកេរ្តិ៍ មានតួសម្តែងរឿង
តំណាងភពទាំងបីចូលគ្នា ដូចជាទេវតា, ព្រះឥន្ទ្រ ព្រះព្រហ្ម
លងរឿងចូលគ្នាជាមួយមនុស្សនិងសត្វតិរច្ឆានផ្សេងៗមានស្វា
និងត្រីជាដើម, ឯតួអង្គព្រះរាមសោតទៀត ក៏ពុំមានពៀរវេរា
អ្វីឡើយ ទោះបីជាបានប្រហារជីវិតយក្សរាប់ម៉ឺនសែនឬកកទំក
ពាសពេញផែនដីយ៉ាងណាក៏ដោយ ព្រោះលោកជាម្ចាស់នៃអំពើ
បាបបុណ្យទាំងអស់ ។ នេះឯងជាលទ្ធិសាសនាព្រាហ្មណ៍ ។

គេប្រទះឃើញអក្សរសាស្ត្រខ្មែរ ផ្តេកទៅតាមទ្រឹស្តី
ព្រហ្មនិយម ចាប់មានកំណើតពីការផ្តើមដំបូងបង្អស់នៃអក្សរ-

សាស្ត្រយើង រហូតដល់សតវត្សទី ១២ នៃគ្រិស្តសករាជ ជា
គ្រាដែលខ្មែរបានលះបង់ទ្រឹស្ដី ឬ លទ្ធិសាសនានេះ ហើយ
នាំគ្នាត្រឡប់បែរទៅគោរពព្រះពុទ្ធសាសនាវិញ ។

## ២_ ចលនាអក្សរសាស្ត្រពុទ្ធនិយម

អក្សរសាស្ត្រក្នុងចលនាពុទ្ធនិយម ចាប់ផ្ដើមមានឡើង
ក្នុងសម័យដែលខ្មែរនាំគ្នា គោរពពុទ្ធសាសនា តាំងពីសត-
វត្ស ទី ១២ គឺនៅភាគខាងចុងនៃសម័យអង្គរ ។ កាលនោះ
បណ្ដាជនខ្មែរ តាំងព្រះមហាក្សត្រ តាំងរាស្ត្រ មន្ត្រីគ្រប់ជាន់
ថ្នាក់បានហ្វឹកហ្វឺនកាយវាចាចិត្ត ទៅតាមគន្លងទ្រឹស្ដី នៃពាក្យ
ប្រៀនប្រដៅរបស់ព្រះពុទ្ធគ្រប់ ៗ គ្នា ។ ក្នុងទ្រឹស្ដីនេះ មាន
លើកយកកម្ម និង ផលធ្វើជាធំ ។ បានសេចក្ដីថា បើនរណា
ប្រព្រឹត្តអំពើល្អ ពិតជានឹងបានសោយផលល្អទៅខាងក្រោយ
តែបើនរណាប្រព្រឹត្តទុរកម្មអាក្រក់ ក៏ប្រាកដជានឹងទទួល

ម្នអកុសលគាត្រកវិញជាក្រោយពុំខានឡើយ ។ និន្ទាការ
ទ្ធនិយមនេះ ជ្រាបចូលទៅក្នុងសន្តានចិត្តបណ្ដាជនខ្មែរយ៉ាង
ប់រហ័សណាស់ ព្រោះកាលនោះ ខ្មែរកំពុងកើតសង្គ្រាម
លិយុគក្នុងប្រទេស រហូតដល់មានការបរាជ័យដកខ្លួនថយ
កតោលទីក្រុងអង្គរ ដែលជាទីនឹករលឹកក្រៃលែងថែមទៀតៗ
ា៎ះហើយសេចក្ដីគោកយ៉ាក ក៏ចូលមកទន្ទ្រានក្នុងសតិអា-
ណ៍របស់អ្នកស្រុក ៗ ទទួលទ្រឹស្ដីពុទ្ធនិយម ជាទ្រឹស្ដី
ទ្ធិភាពមិនបៀតបៀនយាយីគ្នាផង ក៏រឹតតែគាប់ចិត្តអ្នកស្រុក
ណាស់ទៅទៀត ទើបនាំគ្នាប្រសិទ្ធិ បន់ស្រន់ពល់ៗ ថ្វៃ
ល់គុណបុណ្យព្រះរតនត្រ័យ សុំសេចក្ដីសុខសប្បាយរីករាយ
ឿងវិញ ៗ

រឿងរ៉ាវក្នុងទ្រឹស្ដីនេះ សុទ្ធតែនិយាយអំពីអង្គពោធិសត្វ
វលតែងត្រេចរង្គាត់ក្នុងកលវដ្ដសង្សារ ដើម្បីសន្សំយកពោធិ-
ម្ការទឹងប្រាជ្ញាបារមីទៅអនាគត ។ វណ្ណកម្មខ្មែរដែលមាន
ន្ទាការពុទ្ធនិយមតាំងប៉ុន្មាន កវីឬអ្នកនិពន្ធតែងប្រារព្ធថា ជា

សេចក្ដីប្រែចេញពីគម្ពីរពុទ្ធសាសនា (១) ដែលអ្នកប្រាជ្ញពុទ្ធ
សាសនាបានតែងឡើងជាមធ្យោបាយឲ្យអ្នកផងនិយមតាម
ស្នាដៃផ្នែកពុទ្ធនិយមនេះ មាននៅសល់កេរ្ដិ៍ដំណែលហូ
ដល់យើងសព្វថ្ងៃច្រើនណាស់ ដូចជារឿង ក្រុងសុភមិត្រ
សព្វសិទ្ធ, គោតកុលកុមារ, ស័ង្ខសិល្បជ័យ, ចៅស្រទ
ចេក ខឹង មរណមាតា ជាដើម ។

យើងល្បងយកឧទាហរណ៍ក្នុងរឿងទាំងនេះ មកលា
ត្រដាងជាសក្ខីភាព ចំពោះសំដីដែលបង្ហាញថា ពិតជាផ្ដេក
លើពុទ្ធនិយមមែន៖

« ...ស្ដេចលោមព្រះប្អូន ហឫទ័យសោះសូន្យ ថា
« ប្អូនអើយ វេកតៀវរេច្រាង កម្ចងដល់ហើយ ព្រល
« អូនអើយ កុំសោយសោកា ។

(ក្រុងសុភមិត្រ)

១– គម្ពីរនេះយើងនឹងបរិយាយក្នុងជំពូកទី ៨ ។

« ...ហេតុបុណ្យបារមីពន្សពោធិ បានសាងអំពីអតីតា
ដល់ថ្ងៃនោះឯងជាអស្ចារ្យ សារិកាក្យណាក្ស័យ
ប្រល័យផង ។ (សព្វសិទ្ធ)

« ...ហេតុតែបុណ្យបារមី ពន្សពោធិសត្វច្បាស់ច្បង
អស់ចាំងទេវតាផង ចុះមកផ្គងម្រេគ្រា ។
(ស័ង្ខសិល្បជ័យ)

«...បងសូមលានាង ចេញទៅកសាង សន្សំសីលទាន
តទៀតទៅមុខ ទៀងទុកជាយាន នាំសត្វលងស្ពាន
ដ្តសង្សារ ។ (ស្រទបចេក)

យើងសំគាល់បានដោយងាយថា រឿងក៏វេផ្តុកទៅលើ ស្តីនេះ អ្នកនិពន្ធសុទ្ធតែវិនិច្ឆ័យទោសលើតួអង្គក្នុងរឿងទៅ មដំណើរកម្មផលជាត្រីមុខ ទឹងមានការអះខ្ទួលជាតិថែម តផង ។ ឧត្តមគតិនៃអ្នកនិពន្ធប្រភេទនេះ គឺចង់យក ាងបណ្តាជនខ្មែរ ឲ្យលុះទៅដោយសេចក្តីស្រោចស្រង់នៃ ទ្ទាក់ទ ។

## ៣- ចលនាអក្សរសាស្ត្រខេមរនិយម

ចលនាអក្សរសាស្ត្រខេមរនិយម មានលក្ខណៈពិសេ
ប្លែកពីចលនាព្រហ្មនិយម និង ពុទ្ធនិយម ដែលតែងលើកយ
អត្ថអវតារនិងអត្ថព្រះពោធិសត្វធ្វើតួអង្គសំខាន់នៃរឿង ។ ចល
នាទី៣ នេះ ផុសចេញមកពីការរស់នៅរបស់ខ្មែរពិតប្រាកដ
បានសេចក្តីថា ចលនានេះឯងពុំមានផ្តេកគោលគំនិតពឹងព្រ
ស្រ័យទៅលើព្រះអាទិទេព ឬ ឫទ្ធិសក្តិសិទ្ធិនានា ឬ កម្មផល
ឡើយ ប្រាកដជាផ្តិតលំនាំតាមជីវភាពបណ្តាជនក្នុងសង្គម
យើងក្នុងសម័យនិមួយៗ ។ ប្រសិនណាជារឿងនោះកើតឡើ
ក្នុងសម័យណា, ស្រុកទេសមានព្រឹត្តិការណ៍ដូចម្តេច ៗ,
រឿងក៏មានបែបផែនទាំងស្រុងទៅតាមព្រឹត្តិការណ៍ ឬ របៀ
របបរស់នៅរបស់ជនជាតិយើង ដូចក្នុងគ្រានោះដែរ ។

ប្រលោមលោក ឬ រឿងប្រឌិតរបស់ខ្មែរដែលកប់បញ្ចូ
បានក្នុងចលនាអក្សរសាស្ត្រចំពូកនេះគឺ ៖

រឿងទុំទាវ, គាវៀវ, ធនញ្ជ័យ, កុឡាបប៉ៃលិន, ស្រពោន, សូផាត, . . . ។ល។

យើងសូមសិក្សាល្បងអំពីគោលគំនិត ក្នុងរឿងខ្លះដែលនកប់ឈ្មោះខាងលើនេះ សំរាប់ជាការបញ្ជាក់ឲ្យឃើញភាពជាក់លាក់របស់ចលនានិមួយៗ ក្នុងអក្សរសាស្ត្រខ្មែរ ។

រឿងទុំទាវអ្នកនិពន្ធប្រឌិតតាមបែបរឿងជាក់ស្តែង ក្នុងតវត្សទី ១៥ គ្រាដែលខ្មែរមានរាជធានីនៅលង្វែក ។ តួអង្គខាន់ៗ ក្នុងរឿងនេះមានទុំ នឹង ទាវ ជាដើម មិនមែនជាអង្គតារដែលព្រះនារាយណ៍បែងភាគឲ្យមកកើតនោះទេ ហើយមិនមែនជាអង្គព្រះពោធិសត្វ ឬ ព្រះនាងកន្សែស្រពេជ ដែលាប់ផ្តាស់ផ្តូងគម្ពីរផលស័យ ពោលគឺការកើតស្លាប់ក្នុងវដ្ត-ង្សារ ដើម្បីប្រមូលគបបារមី ឬ សាងសន្សំពោធិសម្ភាររឿយ ៗ ហេតុនេះហើយ បានជាទុំនឹងទាវមែងបានទទួលក្ខសោក ក្នុងជីវភាពខ្លួនដូចមនុស្សធម្មតា ពុំមានព្រះព្រហ្មះឥសូរ, ព្រះឥន្ទ ឬ ទេវតាណាតាមជួយគាំពារឡើយ ។

កស្តុតានដាក់ស្ពែន ដូចត្រង់គេនាំខ្ញុំទៅសំឡាប់ ៗ ប្រសិនខ្ញុំ
អវគារ ឬ ជាពោធិសត្វ ប្រាកដជាមានព្រះឥន្ទ ព្រះព្រ
តាមជួយយកអាសាមិនខាន ៗ តែនេះ ខ្ញុំត្រូវស្លាប់ស្លូកត
អំពើរលោករបស់អរជូននៅក្រោមដើមពោធិ ៗ មួយទៀ
ដំណើរគួរអង្គតាំងនេះ ក៏សុទ្ធតែជាគូនរបស់អ្នកស្រែអ្នកចំក
កុងស្រុកខ្មែរ ដែលមាននាមស្រុកតាំងនោះប្រាកដរហូតដ
សព្វថ្ងៃ ៗ

មួយចំណែកទៀតក្នុងរឿងផ្កាស្រពោន ត្រង់នាងវិជ
កើតទុក្ខជ្បិតព្រាត់គូគំណាន់ចិត្ត ហើយអង្គុយបន់ព្រះ
ប្រសិននាងជាកន្ទ្យសពេជ្ជ ជាក់ជាវត្តសក្តិសិទ្ធណាមួយ
ផ្កាលទឹងបំណន់នាងមិនខាន ៗ ហើយចុងបំផុត ប្រា
ជានាងមិនស្លាប់ខ្លួន ទុកឲ្យ ប៊ុនធឿន សោកសង្រេងដ
មនុស្សធម្មតាឡើយ ពោះបីជាសោកខ្លះក៏តង់ដល់ទីបំផុត ប្រ
តែបានជួបជុំគ្នាវិញជាពុំខានឡើយ ៗ

## ៤_ចលនាអក្សរសាស្ត្របរទេសនិយម

ចលនាទីបួននេះ ជាចលនាចំឡែកដែលយើងពុំដែល
ឃើញមានក្នុងអក្សរសាស្ត្របូរាណទេ ទើបតែនៅគ្រាដែល
ប្រទេសយើងធ្លាក់ខ្លួននៅក្នុងឥរាំទពួកបស្ចិមប្រទេស ចំនួន
កមួយសតវត្សរ៍ ទើបមានចលនានេះ ជ្រាបចូលមកក្នុង
នានចិត្តបណ្ណាជនខ្មែរ ដែលពុំទាន់មានមូលដ្ឋានសឺប់ក្នុង
ប្បធម៌ជាតិដែលធ្លាប់មានដម្លៃតាំងពីដើមមក ។ ចំពោះខ្មែរ
កមានសតិអារម្មណ៍ល្អ មានគំនិតជាខ្មែរពិតប្រាកដ ពុំមាន
ក្ដីតក្ដើនចិត្ត ទៅតាមចលនាចំណូលថ្មីនេះឡើយ ។

ចលនានេះ ស្ថិតនៅក្នុងសៀវភៅរឿងទាំងឡាយណា
ដែលសរសេរហួសពីទំលាប់របស់ជាតិ ដែលធ្លាប់មានមក
កំពុងតែបោះជំហានជឿនលឿនទៅមុខ រៀងរាល់ពេល ។
នសេចក្ដីថាជា ចលនាអក្សរសាស្ត្រសម័យថ្មីម្យ៉ាង ដែល
ពាលតែពីសេចក្ដីសប្បាយក្បួខ្លួន គឺសប្បាយក្នុងការកំរែក,

ស៊ីផឹកតាមទំនៀមសុក, ល្អក់វក់វីដោយតាមកិលេសគ្រប់បែ
គ្រប់យ៉ាង ហើយក្នុងនោះពុំមាននិយាយពីសេចក្ដីរំលឹកជា
ជឿនវិញឡើយ គិតធ្វើយ៉ាងណាឲ្យតែឃើញថាការសប្បា
នោះសប្បាយមែន គ្មានបញ្ហាគ្រោះថ្នាក់សោះ ។

ចលនាអាក្រក់នេះ ចូលមករកានក្នុងអក្សរសាស្រ
យើងអស់រយៈកាលដ៏ខ្លីមួយដែរ ប៉ុន្តែត្រូវមតិអ្នកអាន មា
សតិសម្បជញ្ញៈទប់ទល់យ៉ាងខ្លាំងក្លា ទល់តែអន្តរធានទៅវិ
ក្នុងឆ្នាំ ១៩៥៨ ។

យើងសូមបញ្ជាក់ថា បានជាដាក់ថា ចលនាបរទេ
និយម ព្រោះការនិយមគំនិតកខ្វក់នេះ ពិតជាផុះឡើងដោ
សារអ្នកបរទេសសាបព្រោះពូជក្នុងស្រុកយើង គឺយើងនិយាយ
សំដៅតែខាងគំនិត អាក្រក់ល្អក់ក្នុងកាមកិលេស ឥតហេ
ផលប៉ុណ្ណោះ ពុំមែននិយាយដល់បច្ចេកទេសទំនើបយ៉ា
ល្អ ៗ ដែលបរទេសផ្ដល់មកឲ្យយើងនោះឡើយ ។

## ចំពូកទីមួយ

# សោភ័ណនៃអក្សរសាស្ត្រខ្មែរ

ដែលនឹងរាប់បាន ថាជាអក្សរសាស្ត្រមួយប្រកបដោយលក្ខណៈគ្រប់គ្រាន់ លុះត្រាតែក្នុងអក្សរសាស្ត្រនោះមានលំអ គួរជាការពិនិត្យយ៉ាងជាប់ចិត្តផង ។ អក្សរសាស្ត្រខ្មែរយើង មានសោភ័ណច្រើនយ៉ាងណាស់ ដែលបន្ទាប់ទៅនេះយើងគ្រាន់តែលើកយកគោលសោភ័ណខ្លះ ៗ ជាគំរូមកបញ្ជាក់ បង្ហាញអ្នកសិក្សារបស់យើងឲ្យបានយល់ ហើយបង្កើតបានជាសេចក្តីពេញចិត្តនឹងអក្សរសាស្ត្រខ្លួនគេទៅ ។

## ១– សោភ័ណខាងសូរសំឡេង

វិធីអានរបស់ខ្មែរយើង មានលក្ខណៈប្លែកជាងវិធីអាន

របស់ជនជាតិនានា ។ ក្រៅពីពាក្យកាយដែលខ្មែរបានយក លំនាំតាមការសន្ទនាគ្នាជាធម្មតា បុព្វបុរសយើងបានបង្កើតជា បទបែបផ្សេង ៗ គ្នា សំរាប់ឲ្យយើងអានគុណវណ្ណកម្មរបស់ លោក បានត្រាប់ដូចកាយវិការនៃតួតាំងឡាយ ដែលកំពុងតែ មានសកម្មភាពនោះថែមទៀត ។ ដូចនេះ កំណាព្យខ្មែរ យើងមិនត្រឹមតែប្លែកត្រង់ការចាប់ចួន ច្រើនម៉ាត់ប៉ុណ្ណោះទេ ថែមតាំងពត់សំឡេងសូរសំនៀង ឲ្យត្រូតដូលទៅស្របនឹង កាយវិការផង ។ ឧបមាថា បើយើងអានគុណពេលដែលតួរឿង កំពុងកើតទុក្ខ យើងក៏ត្រូវធ្វើបទដំអូញដំណាំងសោកទុក្ខ នោះ ។ បើយើងអានគុណរឿងសប្បាយ សំឡេងយើង ក៏ពត់បែរទៅតាមភាពសប្បាយនោះដែរ ។ ត្រង់ហ្នឹងហើយ ដែលចិត្តកវីខ្មែរ បានកសាងបទបែបច្រើនឲ្យមានលក្ខណៈ ប្លែក ៗ ពីគ្នាដូចការសិក្សាតទៅនេះ ៖

ក– បទពំនោល.– បទពំនោលជាបទចាស់បូរាណ ជាងគេ ។ យើងប្រទះឃើញបទនេះមានមកតាំងពីសម័យ

អន្តរ ពាក្យឈ្មោះបទនេះសោក ក៏ជាពាក្យខ្មែរសុទ្ធ បាន ន័យថាជាសេចក្ដីពោល គឺជាសេចក្ដីបើកបទ ដែលយើង ធ្លាប់ឃើញមានពោលក្នុងការសម្ដែងរបាំព្រះរាជទ្រព្យ ឬ ក្នុង ល្ខោនខោល ។ ចំណោរតមក អ្នកប្រាជ្ញបានទុកជាក់មក នេះ សំរាប់ប្រើក្នុងគ្រាមានកលិយុគ គឺមានការចលាចល រញ្ជីបរញ្ជួយ ដូចជាការជេរប្រទេច, ចំបាំងកំងជល់, ព្យុះ ខ្យល់បោកបក់ ឬ ពាក្យតំហាកកំហែងជាដើម ព្រោះបទនេះ មានសូរសន្ធាប់ខ្លាំង ៗ ។

១– បទព្រហ្មគីតិ.– ព្រហ្មគីតិជាភាសាបាលី ប្រែថា ព្រះព្រហ្មច្រៀង ឬ ចម្រៀងព្រះព្រហ្ម ។ បទនេះមានសូរ សំនៀងលន្ទន់លន្ទោចណាស់ ព្រោះជាបទដំណាងសេចក្ដី ទុក្ខសោក, ការព្រាត់ប្រាសនិរាសគ្នា ឬ ការថ្ងូរទុក្ខតាម-ខន្សអ្វីមួយ ។ ដូនកាលយើងឃើញបទនេះក្នុងសាស្ត្រា ច្បាប់ទូន្មានខ្លះដែរ នេះប្រហែលជាអ្នកនិពន្ធ ចង់ឲ្យអ្នក

អានធ្វើបទដំណូញ ដំណាលនូវសំដីចុងបំផុតរបស់លោកដែលផ្តាំទូន្មានដល់កូនចៅ មុនគ្រាដែលអស់ជីវិតទៅ ។

ក– បទកាកគតិ.– កាកគតិ ប្រែថា ដំណើរក្អែក ឬក្អែកដើរ ។ សូរសំនៀងនៃបទនេះ មានចង្វាក់ស្មើ ៗ សំ-ឡេងមិនលើកមិនដាក់ តែរនើន ៗ មានទំនងដូចក្អែកដើរ ។ បុរាណប្រើបទនេះ ក្នុងការសូននាគ្គាធម្មតា, ក្នុងសេចក្តីក៏យក៏បតិមានផ្សេង ៗ ឬ ក្នុងសេចក្តីផ្តើមរឿងនិមួយ ៗ ។ យើងប្រទះច្បាប់ទូន្មានជាច្រើនដែលសរសេរជាបទកាកគតិ ។

ឃ– បទកុជង្គលីលា.– កុជង្គលីលា បានសេចក្តីថា នាគដើរ ឬ នាគលូន ។ បើយើងសង្កេតចំពោះសូរសំនៀងនៃបទនេះ មិនខុសពីឈ្មោះខាងលើនេះទេ ព្រោះសំឡេងបទកុជង្គទន់ក្ងន់អែនអន ផ្អែមល្ហែមណាស់ ទំនងដូចជាពស់លូន ឬ នាគដើរមែន ។ បុរាណច្រើនប្រើបទនេះ ក្នុងការសប្បាយរីករាយ ដូចជាក្នុងការពប់រៀបព្រៃព្រឹក្សាលតាវល្លិ, សរសើរពីសំរស់នៃសួនច្បារ. ទឹកសមុទ្រ ឬ ធម្មជាតិដទៃៗ ទៀត ។

៨- បទបន្ទោលកាក.-ពាក្យបន្ទោលកាកនេះក្លាយមកពីពាក្យ មណ្ឌុកគតិ ដែលប្រែថា ដំណើរកន្ដែប ឬកន្ដែបលោត ។ សំនៀងនៃបទនេះ យាវវែងៗ ហើយកញ្ឆក់ម្ដងៗ មានទំនងដូចកន្ដែបលោត ហើយឈប់, ឈប់ហើយលោតយ៉ាងនោះដែរ ។ បទនេះ សំរាប់ប្រើក្នុងសេចក្ដីធ្ងើយធ្ងន់ធ្ងុកកំប្លែងរកគ្រួមាប់ក្រមើមទាំងឡាយ ។ យើងសង្កេតឃើញច្រើនជាគួសត្វ ។

ច- បទពាក្យ ៧, ពាក្យ ៨, ពាក្យ ៩ -បទទាំងនេះ មិនឃើញមានក្នុងវណ្ណកម្មបុរាណ តាំងពីសម័យអង្គរ ឬ ខាងដើមសម័យកណ្ដាលឡើយ គេទើបតែឃើញមាននៅចុងបំផុតនៃសម័យកណ្ដាល គឺគ្រាដែលរាជធានីយើងនៅឧដុង្គ និងគ្រាលើកទីក្រុង ពីឧដុង្គមកភ្នំពេញ ។ សូរសំនៀងបទទាំងនេះ មិនមានឯកភាពតែមួយទេ ច្រើនដេកជួលទៅតាមអ្នកអានដែលទំបំពត់សំឡេងឲ្យពិរោះក្រអៅប្លែកៗពីគ្នា ។ ដំបូងយើងឃើញកំណាព្យពាក្យ ៧, ពាក្យ ៨ និង ពាក្យ ៩ នេះ

ច្រើនមាននៅក្នុងបទចម្រៀង មានបទសេកកាំទិជាដើម ។ ប៉ុន្តែក្រោយមក ដោយចិត្តកវីយើងប្រាថ្នាឲ្យវណ្ណកម្មនៃលោកពិភពពិសាជួចជាចំរៀងដែរ ទើបលោកយកបទតាំងនេះមកប្រើក្នុងស្នាដៃជារឿងរ៉ាវផ្សេង ៗ ។

## ២_សោភ័ណខាងសំនួនវោហារ

របៀបលេងសំនួនពោហារវិញ ក៏ឃុញឃុសោយើងប្រសប់ខាងធ្វើឲ្យអ្នកអានជក់ចិត្តណាស់ ដោយប្រើល្បិចផ្សេង ៗ ច្រើនបែបច្រើនយ៉ាងក្នុងសេចក្តីពប់រៀបពិពិដ្ឋភាព ឬ សេចក្តីសន្ទនារវាងតួមួយនឹងតួមួយក្នុងអក្សរសាស្រ្ត ដែលយើងនឹងលើកយកលំអរខ្លះ មកធ្វើជាឧទាហរណ៍ខាងក្រោមនេះ ៖

១ – ការរាប់រៀបពិដ្ឋភាពមានកាយវិការ

– រមាំងរមាំងមៀង - មើលកាល់កៀងគូត្រកាល
ធីស្ទៅនៅកណ្តាល - វាលក្រោមម្លប់ ១ គោមួយ ៗ

(ព្រះឃ្លាំង.៩៦)

- គជសារដើរដល់ មៀនមើលទៅយល់
ព្រះពន្សព្រុក្ខា ផ្កាខ្ចប់ជន្គជួញ
កន្ទួញហង្គា ក្រោមទ្រុឌសិរសា
ជញ្ជាបឥតអាក់ ។

(កោសាធិបតី-កៅ)

- ស្តេចក្រាយកៅទណ្ឌសរសេក្តិ រូមណ្ឌលចក្រ
រំកាយព្រះករសោភា ។

(ភមរកើ្ត)

- សន្ទឹកផ្គរគ្រាំ ទាញដៃមកផ្ទាំ ក្រោមកេនរទេះ
បង្ផ្ទាំរួចហើយ បង្ខៀងផាយសេះ ចាកកេនរទេះ
សេះលុនលឿនលន់ ។

(បំរៀនខ្មែរ)

២- លំអក្នុងការប្រៀបធៀប

- ខ្លួនប្អូនដូចឈើជាបន្គន
ខ្លួនអ្នកប្រុសឈ្មួនដូចឃ្មុំផន
មកទំលើសាំហើរជាមួន

ឈើសោកសៅហ្មងអសារនៅ
ខ្ញុំជាខ្លួនបងដូចដំរី
ខ្លួនប្អូនស្រស់ស្រីដូចអំពៅ
ដំរីបានផ្អែមមិនដែលទៅ
ឆ្ងាយពីអំពៅទេខ្លួនណា ៗ

(ព្រះភិក្ខុសោម)

— ទុក្ខខ្ញុំទុក្ខរស់ទុក្ខរងកម្ម
កប់ខែកប់ឆ្នាំតែងវិតក្ក
រស់នៅជាមនុស្សមិនពេញមុខ
នេះទើបហៅទុក្ខជាងកង្រី ៗ
កង្រីកើតទុក្ខទុក្ខសល់សែន
ទុក្ខមែនប៉ុន្តែទុក្ខនោះខ្វី
ទុក្ខខ្ញុំដល់អស់ផុតផែនដី
ដល់លាលោកក្ដីមិនអស់ទុក្ខ ៗ

(ព្រះអង្គម្ចាស់ក្សត្រី ល.ន.)

៣- លំអក្នុងស្គរសំនៀងរណ្តំគ្នា

- ពពេបពងនៅពពាលខែ

ហើយហិចហើរហែគ្នាគ្រសង

ពាំផ្កាពពាយកយរុះល្អង

ពពួលយំកងប៉ុកដី ៗ

ដូចកលកាយបានប្រាណមូលមិត្ត

ខែបនិត្យពកៅនាប្រឹមប្រិយ

ស្រីស្រស់ស្រួចស្រេចជាប់លោកិយ

បានបង់ចមប៊ីហើយបែកបែរ ៗ

ម៉ុនភក្តីអក្សរ-គន់

- ចរបូលតតាំង ខល់ខំពកក់ង យក្សយង់មោហា

ខ័នខែងកយកត់ កាប់កាត់យក្សា យក្សសោតមរណា

ឃ្លាតខ្លួនខ្លាត់ខ្លាយ ៗ

(សន្ធរម៉ុក)

## ៤- លំអក្នុងការបង្ហាញតួអង្គ.-

លំអក្នុងការបង្ហាញតួអង្គ ក្នុងអក្សរសាស្ត្រខ្មែរយើ
ឃើញមានរបៀប ៣ យ៉ាងប្លែកពីគ្នាគឺ ៖

### ក- អ្នកនិពន្ធជាអ្នកបង្ហាញ:

“.... ស្ដេចមានមហេសី នាមកែវកាកី ល្អ

“ឥតហ្មង ឥតមានស្រីណា សោភាដូចផង សមសព្វកន្ទ

“កន្ទ្រានអស់ស្រី ។

(ព្រះបាទអង្គឌួង)

### ខ- តួអង្គមួយជាអ្នកបង្ហាញ:

“.... ចាំទៅដល់ផ្ទះប្រាប់តាគ្រប់

តានៅក្នុងម្លប់សមស្រណោះ

នាងជាម្ដាយតាមានរបស់

កូនស្រស់រូបស្រេចដាច់ស្រីផង ។

(ព្រះភិក្ខុសោម)

គ- តួអង្គបង្ហាញខ្លួនឯង:

- ខ្ញុំនេះជាក្សត្រសោយរាជ្យរដ្ឋ
នាមព្រះព្រហ្មទត្តមានឫទ្ធិផង
មានតាំងប្រាសាទស្អាតកន្ទុំ
ជាច្បងលើសលប់កតមនុស្ស ។

( អ្នកស្រី សំទ្ធិ )

- លំអក្នុងពាក្យកំប្លែង.-

“ . . . – ហើយនែអាបិតតាមយកគាត់
អាចិតតក្រោកបានសាច់ខ្ញុំ
តាញៃឆ្កាតគាប់ឆ្ងាប់សាប់ញោប់ដៃ
ហើយលៃឲ្យតាប់ប្រញាប់ណាន់ ។

(សន្ធរ ម៉ុក)

“ . . . – ខ្ញុះពោះម៉ាយស្តាយមិត្តគិតខ្មោចនាង
ឯមេម៉ាយស្តាយកោរ៉ូបខ្មោចអ្នក

តាអាណោចខ្មោចយោយកយមាយភ្ញាក់

យាយញ័រញាក់ទ័ក ខ្លាចដល់ខ្មោចតា ។

(ឧកញ៉ា នូ - កន)

-- កំពក់កំពីងធោ៎ ខាំចំបន្ទោះកន្ទៀតក្តៅ

ខាំហើយហែលគ្នាទៅ បេះស្លឹកអំពៅធ្វើជាថ្នាំ ។

(អាលក្ខណ៍–ប៉ែន)

## ៣–សោភ័ណខាងគំនិត –

ក្រៅពីសោភ័ណខាងសូរសំនៀង និង សោភ័ណខា
សំនួនវោហារមក យើងឃើញមានក្នុងអក្សរសាស្ត្រខ្មែរមា
សោភ័ណខាងគំនិតទៀត ។

យើងលើកយកគោលខ្លះ ៗ មកបញ្ជាក់ក្នុងទីនេះដូច
ត្រង់និក្ខេបបទរបស់អ្នកនិពន្ធនិមួយ ៗ ដែលខ្លួនប្រកាន់យ
ត្រង់ណាហើយ លោកប្រើលាតត្រដាងយោបល់នោះ ព
គ្រាន់តែអ្នកអានបានយល់ច្បាស់ទើបលោកសុខចិត្ត ។ ។

ណ៍ដូចជារឿងក្នុងពុទ្ធនិយម ដែលលោកលើកយកកម្ម
រធ្វើជាធំ ។ លោកមិនភ្លេចសោះទេត្រង់កម្មពៀរនៃអកុ-
ល ដែលតែងតាមផ្ដាន់ឲ្យលំបាកវេទនានៅទីបំផុត ឯផល
អំពើល្អវិញ លោកតែងលាតត្រដាងពីផលដ៏ល្អត្រកាល
ៅទីបំផុតដែរ ។

មានតួដែលប្រកបដោយលក្ខណៈប្លែកពីគ្នា តាមចរិយា
ស់ខ្លួន ដូចជាតួស្ដេចមនុស្ស, ទេវតា តែងជំណាន
ភាវៈល្អ ។ ឯតួយក្ស សត្វសាហាវ ឬ ចោរកំណាច ជា
ណានសភាវៈអាក្រក់ កាចឃោរឃៅគ្មានធម៌មេត្តាក្នុងខ្លួន
ឡើយ ។ ដូចនេះ យើងឃើញជាក់ថា ការដែលអ្នកនិពន្ធ
មសរសេរមានយក្សក្នុងតួអង្គអក្សរសាស្ត្រនោះ គ្រាន់តែ
ជំណានសភាវៈកាច, អាក្រក់, អ្នកគ្មានមេត្តាធម៌ប៉ុណ្ណោះ
មិនជារូបមានមែនជាក់ប្រាកដឡើយ ។ ដូចនេះហើយ
បអ្នកនិពន្ធរាប់រៀបពីរូបរាងយក្សនោះអាក្រក់ក្រៃលែង ទាំង
ងកាយ ទាំងចូកតារសំដីរោហារ ។

លំអមួយផ្នែកទៀត គ្រង់មានការប្រដៅខ្លួនដល់មនុ
មានទ្រព្យច្រើនហើយកាចអធម៌ ច្រើនមើលងាយមនុ
ថោកទាបជាងខ្លួន នឹងប្រើការរំលោភលើជនប្រគេ
ជាដើម ។ លោកបានលាតត្រដាងថ្លៃរឿងគ្រង់កន្លែង
ឲ្យឃើញថា កាលណាមនុស្សប្រកាន់យកបុគ្គល ធ្វើ
មើលងាយគេនេះ ប្រាកដជាត្រូវអំពើសប្បុរស - យុត្តិ
មានជ័យជំនះលើជាមិនខាន ។

ដូចជារឿងសន្ធសិល្បជ័យ គ្រង់កូនស្តេចចិត្តកំណា
ទាំង ៤ នាក់ទៅបោកបញ្ឆោតសន្ធសិល្បជ័យឲ្យស្លាប់បង់ដើ
នឹងយករាជសម្បត្តិ ។ តែដល់ទីបំផុតត្រូវសន្ធសិល្បជ័យល្ប
វិញ ក៏ចាប់យកមនុស្សកំណាចទាំងនោះមកផ្ចាញ់ផ្ចាល ។

រឿងស្រទបចេក គ្រង់សេដ្ឋីធ្វើបាបស្រទបចេកនឹងម្តា
ឲ្យទាល់តែម្តាយនោះស្លាប់ ។ ដល់ទីបំផុតស្រទបចេកបា
គ្រងរាជ្យ បានតាំងកូនសេដ្ឋីធ្វើប្រពន្ធទៀត ក៏ចាប់សេ
មកធ្វើទោសឲ្យរាងចាល ។

រឿងព្រះជិនវង្ស ត្រង់ព្រះបាទសាមលមើលងាយព្រះ
នវង្សដែលក្លែងខ្លួនជាមនុស្សឃ្លង់ ។ លុះដល់ឆ្លើយប្រស្នា
ះឥន្ទមិនរួច ក៏ត្រូវតែពឹងដល់មនុស្សឃ្លង់នោះវិញ ។

ឧទាហរណ៍ទាំងប៉ុន្មានខាងលើនេះ បញ្ជាក់ឲ្យដឹងថា
កអក្សរសាស្ត្រយើង ពិតជាបេះបំពួនៈគោលគំនិតរបស់
លាកក្នុងផ្ទៃរឿងទាំងនោះជាច្រើន ពុំមែនគ្រាន់តែជារឿងបំ
អារម្មណ៍ទេ គឺមានបញ្ហាសំរាប់ជួយដោះស្រាយគតិអាក្រក់
ស់មនុស្សជាច្រើនអន្លើដែរ ។





ជំពូកទីប្រាំ

# អក្សរសាស្ត្រចែកជាសម័យ

ដើម្បីឲ្យងាយសិក្សាពីប្រវត្តិហូរហែដ៏វែងឆ្ងាយ នៃអក្
សាស្ត្រ  តាំងពីពេលកើតបានជារូបរាងរហូតដល់គ្រាបច្ចុប្ប
នេះ  យើងចែកសម័យធំ ៗ ជា ៥ សម័យគឺ ៖

១– សម័យមុនអង្គរ,

២– សម័យអង្គរ,

៣– សម័យកណ្តាល,

៤– សម័យអាណាព្យាបាល,

៥– សម័យបច្ចុប្បន្ន,

## ១_ សម័យមុនអង្គរ

សម័យមុនអង្គរ រាប់តាំងពីប្រទេសខ្មែរ ចាប់កសាងអារ្យធម៌របស់ខ្លួន គឺពេលដែលចាប់ផ្ដើមមានប្រវត្តិសាស្ត្រជាដំបូងតាំងពីសតវត្សទី ១ នៃគ្រិស្តសករាជ រហូតដល់ចុងសតវត្សទី ៨ ។ គ្រានោះព្រះបឋមក្សត្រខ្មែរ គឺព្រះបាទកៅណ្ឌិន្យ ទ្រង់បានដឹកនាំអារ្យធម៌ឥណ្ឌាផ្នែកខាងត្បូង មកសាបព្រោះលើប្រទេសយើង ដែលមានអក្សរសាស្ត្រជាអាទិ ហើយទ្រង់បណ្ដុះបណ្ដាលនូវពូជធារទាំងនោះ ឲ្យកើតកាលផលគុម្ព សាយភាយទៅគ្រប់និគមជនបទ នៅក្នុងដែនដីយើង ។ មិនតែប៉ុណ្ណោះ ទ្រង់បានបន្ដនូវព្រះរាជសន្ដតិវង្ស ដើម្បីពង្រីកនូវអារ្យធម៌ទាំងនេះ មានរស្មីកាន់តែភ្លឺស្វាងឡើង សំរាប់ជនខាងក្រោយទៀត ។ បានសេចក្ដីថា៖ កាលនោះ អក្សរសាស្ត្រខ្មែរ ស្ថិតនៅក្នុងពេលកសាងនៅឡើយ តែតែងបានជួបប្រទះនឹងភ័ព្វវាសនាល្អ គឺសេចក្ដីចំរើនជាលំដាប់ ។ ប៉ុន្តែអក្សរសាស្ត្រខ្មែរជំនាន់នោះ មាននិន្នាការសំស្ក្រឹតគ្រប

ជណ្ដាប់ជានិច្ច ព្រោះលទ្ធិព្រហ្មញ្ញសាសនានិងពុទ្ធសាសនាបែប
មហាយានកំពុងលាតសន្ធឹងអានុភាពនៅក្នុងប្រទេសយើង ។
លទ្ធិទាំងនោះ សុទ្ធតែមានសំស្រ្កឹតជាមូលដ្ឋាន ។

## ២_ សម័យអង្គរ

ដែលហៅថាសម័យអង្គរក្នុងទីនេះ គឺកប់តាំងពីសត
វត្សទី ៩ ដែលព្រះបាទជ័យវរ្ម័នទី ២ បានចាប់កសាងទីក្រុង
ថ្មីនៅអង្គរ ក្នុងភូមិភាគខាងជើងបឹងទន្លេសាប រហូតដល់ចុង
សតវត្សទី ១៤ គ្រាដែលព្រះបាទស្រីសុរិយោពណ៌ទី ២ ទៅ
ពញាយ៉ាត លើកទីក្រុងពីអង្គរមកកសាងនៅទន្លេបួនមុខវិញ ។
សម័យនេះ អក្សរសាស្ត្រខ្មែរក៏បានចំរើនលូតលាស់ទទួលការ
រុងរឿងយ៉ាងខ្ពស់បំផុត ព្រោះឫទ្ធិបារមីរបស់ប្រទេសកំពុងស្ថិត
ក្នុងជោគជ័យដ៏ថ្កុំថ្កើង ។ អាណាចក្របានរីកទូលាយ ជា
គ្រឿងបើកអំណាច ឲ្យអក្សរសាស្ត្របានហូរហៀរពេញពោ
ផ្សាយគ្រប់ទិសទីក្នុងបូរីនិងស្រុកតូចតាច ព្រមទាំងប្រទេស
ចំណុះខ្លះផង ។ ឯអ្នកប្រាជ្ញរាជបណ្ឌិត ក៏កើតមានឡើង

ជាច្រើន ព្រោះតែបានទទួលការនិយម រាប់អានពីគ្រប់មជ្ឈដ្ឋាន ហេតុតាំងពីក្សត្រប្រជា ដល់នាម៉ឺនសព្វមុខមន្ត្រីដែលមានឋានៈខ្ពស់ៗ ជាពិសេសគឺព្រះមហាក្សត្រដែលព្រះអង្គតែងសព្វព្រះរាជហឫទ័យ សន្តោសប្រោសប្រាណរាប់រកអ្នកប្រាជ្ញសព្វមុខវិជ្ជា មានវិជ្ជាអក្សរសាស្ត្រជាដើម ។ ហើយព្រះអង្គតែងប្រោសមេត្តា តែងតាំងអ្នកប្រាជ្ញអក្សរសាស្ត្រទាំងនោះ ឲ្យមានគោរមងារ ឬឋានៈខ្ពង់ខ្ពស់ សំរាប់ចេញចូលគាល់ហ្វៅព្រះអង្គ គ្រប់ពេលដែលទ្រង់ត្រូវការផងៗ

នៅខាងដើមនៃសម័យនេះ អក្សរសាស្ត្រខ្មែរ ត្រូវនៅក្នុងឥទ្ធិពលនៃភាសាសំស្រ្កឹតដូចសម័យមុនអង្គរដែរ ប៉ុន្តែមកដល់ផ្នែកខាងចុង បែរជាភាសាបាលីមានអានុភាពលាតសន្ធឹងក្នុងអក្សរសាស្ត្រយើងទៅវិញ ដ្បិតសម័យនេះ ព្រះមហាក្សត្រនឹងបណ្តាជនទាំងឡាយបានវិលមកគោរព លទ្ធិពុទ្ធសាសនាបែបហីនយានវិញហើយ ហើយលទ្ធិពុទ្ធសាសនាបែបហីនយាននេះ សុទ្ធតែមានគោលចារឹកជាភាសាបាលីទាំងអស់

ដូចយើងឃើញគ្រឿងដំណែល ទៅសល់រហូតដល់សព្វថ្ងៃនេះ ។

## ៣_ សម័យកណ្ដាល

សម័យនេះមានរយៈកាលវែងឆ្ងាយណាស់ រាប់តាំងពីសត-
វត្សទី១៥គឺបន្ទាប់ពីពេលបាក់បោលក្រុងអង្គរ រហូតដល់សតវត្ស
ទី១៩ នៅគ្រាដែលហៀបនឹងបាក់បោលក្រុងឧត្តុង្គ ។ មានព្រះ
មហាក្សត្រជាច្រើនអង្គ បានគ្រប់គ្រងរាជសម្បត្តិនៅរាជធានី
ជាច្រើនកន្លែង ដូចជានៅ ស្រីសឈរ, ល្វាឯម, កោះឃ្លោក,
ឧត្តុង្គមានជ័យ ទឹងលង្វែកជាដើម ដែលមានកវីបណ្ឌិតជាច្រើន
កើតឡើងបន្ទាប់គ្នា តាមលំដាប់រាជ្យជាហូរហែ គឺលើកពីក្រុង
មួយទៅក្រុងមួយនាំយកទាំងពូជជាទីមូលដ្ឋានអក្សរសាស្ត្រ
ទៅផ្សាយតាមទីកន្លែងទាំងនោះ ឲ្យប្រជាពលរដ្ឋជក់ចិត្តជក់
គំនិតក្នុងរស្មីពណ្ណរាយ នៃអក្សរសាស្ត្រតាំងពីគ្រានោះមក ។
ភស្តុតាងជាក់ស្ដែងជាស្នាដៃអក្សរសាស្ត្រក្នុងសម័យនេះ ទុក
កេរ្តិ៍ឲ្យយើងជាច្រើនអនេកគឺសាស្ត្រារឿងរ៉ាវ ឬ ច្បាប់ទំលាប់

ផ្សេង ៗ សុទ្ធតែកើតឡើងក្នុងពេលនេះ ដោយសារកវីបណ្ឌិត
ច្រើនរូប ហើយជាសំខាន់បំផុត មានព្រះរាជាច្រើនព្រះអង្គ
បានយកព្រះរាជហឫទ័យទុកដាក់ជួយឧបត្ថម្ភពេញព្រះកាយ-
ពលទើងមានស្នាព្រះហស្តទុកកេរ្តិ៍ឲ្យយើង ដូចជាព្រះបាទ
ជ័យជេដ្ឋា, ព្រះស្រីធម្មរាជាព្រះរាជសម្ភារ, ព្រះបាទអង្គចន្ទ
និងព្រះបាទសម្តេចហរិរក្សរាមាធិបតីព្រះអង្គឌួងជាដើម ៗ ក្នុង
ពេលនោះប្រទេសយើង បានចាក់ឫស លទ្ធិពុទ្ធសាសនាបែប
ហីនយានយ៉ាងមាំមួនហើយ ៗ បណ្តាជនគ្រប់ប្រភេទសឹង
គោរពលទ្ធិនេះតែមួយគ្រប់ ៗ គ្នា ៗ ព្រះរាជាគ្រប់ព្រះអង្គទ្រង់
គោរពលទ្ធិសាសនាព្រះពុទ្ធតាមបែបតែមួយ ហើយទ្រង់តែង
ជួយឧបត្ថម្ភដល់ព្រះសង្ឃនិងវត្តអារាមទាំងឡាយ ឲ្យកាន់តែ
មានច្រើនឡើង ៗ ៗ សមបើព្រះសង្ឃទាំងនោះ ជាអ្នករក្សា
ឃាំងវិជ្ជាអក្សរសាស្ត្រយ៉ាងជិតដល់ណាស់ផង វណ្ណកម្ម
របស់បុព្វបុរសយើងក៏កាន់តែមានស្ថិរភាពមាំទាំ សំរាប់បំពេញ
កិច្ចត្រូវការ របស់ជនទូទៅក្នុងប្រទេស ៗ បើយើងសង្កេតឲ្យ

ច្បាស់លាស់ទៅ គ្រានោះមានតែវត្តអារាមនេះឯង ជាសាលាទិសាបាមោក្ខ គឺជាទីប្រជុំនៃជំរេះវិជ្ជា គ្រប់បែបគ្រប់យ៉ាង ។ អ្នកណាចង់មានចំណេះជាក់ខ្លួន ឬ ចង់កសាងខ្លួនឲ្យទៅជាមនុស្សចេះដឹង ត្រូវតែទៅនៅជ្រករៀនសូត្រជាមួយព្រះសង្ឃតាមវត្តអារាមទាំងនោះជានិច្ច ។ ព្រោះគម្ពីរសាស្ត្រទាំងឡាយដែលជាមូលដ្ឋានរបស់វិជ្ជា សុទ្ធតែមានដំកល់ទុកនៅវត្តអារាមនោះឯង ។ ដោយហេតុសម័យនោះមានការសិក្សាជាឯកភាពដូច ៗ គ្នាពាសពេញប្រទេស ព្រោះមានគោលចារឹកតែមួយឥ្យាយចេញទូពេន្ទីរស្មើជាយូរអង្វែងឆ្នាំ ដូចពោលមកខាងលើនេះហើយ ទើបប្រទេសយើងបានចំរើនលូតលាស់ខាងអក្សរសាស្ត្រលើសសម័យមុន ៗ ព្រោះអក្សរសាស្ត្រ គេត្រូវរៀនជាបឋម គឺជាគាតព្វកិច្ចមួយសំរាប់ឲ្យគេមានមូលដ្ឋានខាងចំណេះប្រាជ្ញា ដើម្បីនឹងបន្តវិជ្ជាទៅកាន់ទីខ្ពង់ខ្ពស់ថែមទៀត ។

## ៤_ សម័យអាណាព្យាបាល

សម័យនេះជាសម័យទីបំផុត គឺរវាងជាង ៨០ ឆ្នាំប៉ុណ្ណោះ ។

គ្នានោះប្រទេសយើង ស្ថិតនៅក្នុងអាណាព្យាបាលរបស់ពួក
ស្ចិមប្រទេស ។ អក្សរសាស្ត្រនិងវប្បធម៌យើងសម័យ
នះ មិនសូវបានរីកសាយតាមចំណាន់ដូចពីមុនមកទេ ព្រោះ
ណាចវប្បធម៌របស់បស្ចិមប្រទេសមានឥទ្ធានុភាពជាង បាន
លមកគ្របដណ្តប់វប្បធម៌យើងឲ្យនៅស្ងប់ស្ងាត់មួយពេល ។
តែការស្ងប់ស្ងាត់នេះ មិនមែននៅឈឹងសូន្យទេ មានកវី
បណ្ឌិតជាច្រើនរូប បានប្រឹងប្រែងធ្វៀតពេលតុបតែងរឿងរ៉ាវ
ជាស្នាដៃដ៏ល្អ ៗ ទុកឲ្យយើង បានន័យថា លោកបានចិញ្ចឹម
ទ្ធិអក្សរសាស្ត្រ ដែលធ្លាប់មានមកតាំងពីព្រេងនាយឲ្យនៅ
ង់វង់ជីវិតតទៅទៀត កុំឲ្យសាបសូន្យតាមការដែលគេគ្រ-
ឡុកមើលដោយឥតពិចារណានោះឡើយ ។ បំណែកព្រះ
បន្សដែលជាមេឃ្លាំងវិជ្ជានេះ ក៏ប្រឹងរក្សាម៉ឺងម៉ាត់មិនព្រម
ឲ្យក្បួនខ្នាតទាំងនោះខ្ចាត់ខ្ចាត់ទៅណាបានឡើយ ទោះបីជា
បានទទួលការនិយមក្តី ឬមិនបានទទួលក្តី ក៏លោកនៅតែ
ប្រឹងរក្សាដដែល បានសេចក្តីថា ទោះបីជាអក្សរសាស្ត្រនេះ

មិនបានលេចឡើងក្នុងមជ្ឈដ្ឋានជាផ្លូវការក៏ដោយ ព្រះស
នៅតែថែទាំ និងផ្សាយបានខ្លះៗ តាមដោយអ្នកស្រុកជិតខា
ដែលជាសិស្សគណរបស់លោក ៗ ចាប់តាំងពីពាក់កណ្ដា
សម័យនេះយើងប្រទះឃើញ មានការបោះពុម្ពផ្សាយសៀ
កៅផ្នែកពុទ្ធសាសនាជាច្រើនក្បាល និងផ្នែកស្រាវជ្រាវអក្ស
សាស្ត្រជាច្រើនណាស់ដែរ ព្រោះសម័យនេះគេបង្កើតឲ្យមាន
ជាអក្សរពុម្ពសំរាប់ប្រើប្រាស់តាមបែបសម័យនិយម ៗ ដ
ពោះបីជាមានពុម្ពអក្សរនិងការប្រមូលប្រជុំអ្នកប្រាជ្ញកវីបណ្ឌិត
ខ្លះហើយ ប៉ុន្តែលក្ខណសម្បត្តិរបស់អក្សរយើង នៅតែ
មិនបានស្ថិតនៅក្នុងមជ្ឈដ្ឋានផ្លូវការនៅឡើយ ដូច្នេះក៏មិន
បានជាកាតព្វកិច្ចម៉ឺងម៉ាត់ឡើយ ៗ នៅចុងសម័យនេះ
យើងបានទទួលជោគល្អមួយយ៉ាងសំខាន់ គឺយើងកើតបាន
“វចនានុក្រម” ដែលជាមេពាក្យធ្វើជាគោលចារឹកនៃពាក្យ
ទាំងឡាយ សំរាប់ឲ្យយើងចេះសរសេរ ឬ ដឹងរបៀបសរសេរ
ឲ្យត្រឹមត្រូវតាមអក្ខរាវិរុទ្ធ ជៀសវាងពីការភ្ញាំងភ្ញាត់ដែលធ្លាប់

នមកពីមុន ៗ ក្រៅពីនេះមានការប្រជុំបណ្ដាអ្នកប្រាជ្ញ
ងអក្សរទើងខាងពុទ្ធសាសនា ធ្វើជាក្រុមមួយសំរាប់តាក់តែង
ស្រាវជ្រាវទីងផ្ទៀងផ្ទាត់ក្បួនច្បាប់ ព្រមទាំងបោះពុម្ព
យខ្លះផង ៗ

## ៥_ សម័យបច្ចុប្បន្ន

ដែលហៅថាសម័យបច្ចុប្បន្នក្នុងគ្រានេះ គឺសម័យដែល
ទេសយើងបានដកខ្លួនចេញពីអាណាព្យាបាល នៃបស្ចិម
ទេស ៗ តាំងពីពេលនោះរហូតមកដល់សព្វថ្ងៃនេះ ប្រទេស
រីងបានលូតលាស់ខាងការផ្សាយសៀវភៅគ្រប់ជំពូក តែ
រីនជាងគេបំផុត គឺសៀវភៅប្រលោមលោក ៗ មានអ្នក
ានជាច្រើនឈ្មោះ ប្រឹងចំណាយពេលរៀបចំចងក្រងនូវ
ងការថ្មី ៗ ដែលប្រឌិតឡើងដោយផ្ទាល់ខ្លួនសំរាប់បំពេញ
អ្នកអាន ៗ ទោះបីជាមិនសូវបានបរិបូណ៌ខាងផ្នែកគំនិត
ខាងរបៀបសរសេរក៏ដោយ អ្នកនិពន្ធនិមួយ ៗ សុទ្ធតែ

បានសរសេរគន្ថអារម្ភកថា សម្ដែងនូវគោលបំណងរបស់ខ្លួន «ចង់ជួយលើកដំកើងអក្សរសាស្ត្រជាតិ» ដូច ៗ គ្នា ។

ណែកសាស្ត្រាបុរាណជាច្រើនឈ្មោះ ក៏បានលេចខ្លួនឡើង អក្សរពុម្ពប្រណាំងប្រជែងជាមួយរឿងទំនើប ៗ តាំងនេះដែរ





## ជំពូកទីប្រាំមួយ

# អក្សរសាស្ត្រសម័យមុនអង្គរ

សម័យមុនអង្គរ ជាសម័យដំបូងបំផុតដែលជនជាតិខ្មែរ
ប់កសាងឥស្សរភាពនឹងការរៀបចំនៅលើដែនដីគោកធ្លក ។
លនោះព្រះបឋមក្សត្រខ្មែរ គឺព្រះបាទកៅណ្ឌិន្យ ក្រោយ
លបានមកកាន់អំណាចលើដែនគោកធ្លកបានហើយ ទ្រង់
ចាប់កសាងវប្បធម៌ជាបណ្តើរ ៗ គឺតាំងពីសតវត្សទី ១ នៃ
ស្តសករាជ ។ អក្សរខ្មែរក៏ចាប់ផ្តើមមានរូបរាងឡើង
ាំងពីកាលសម័យនោះមក តែអក្សរយើងជាន់នោះមាន
ណ្ឋានរូបរាងស្រដៀងគ្នានឹងអក្សរឥណ្ឌាភាគខាងត្បូង ។
បណ្ឌិតបុរាណខ្មែរយើង មិនព្រមប្រើអក្សរដែលដូចរបស់

គេស្មោះនោះទេ លោកបាននាំគ្នាប្រឹងការខ្សែបន្តិចម្តងៗ
មានសណ្ឋានមួយប្លែកជាពិសេសសំរាប់ជាតិរបស់ខ្លួនៗ គឺ
មានលក្ខណៈជាពិសេស អាចឲ្យជនទូទៅស្គាល់បានថា
ពិតជារបស់ខ្មែរមែនៗ **តាំងពីអង្គរកាលចំនួនជិតពីរពាន់ឆ្នាំ**
មកហើយៗ គេដំណែលសម័យនោះ យើងយល់
ស្គាល់បានដោយសារមានចារឹកនៅលើផ្ទាំងសិលា ដែលជា
ឋាវរៈមួយគង់វង្សនៅបានយ៉ាងយូរៗ ពាក្យពេចន៍ គឺសំ
ប្រើប្រាស់របស់ជនជាតិយើងសម័យនោះ ច្រើនលំអន
តាមទំនាការភាសាសំស្ក្រឹត ព្រោះកាលនោះភាសាសំស្ក្រឹ
បានលាតសន្ធឹងអំណាចពាសពេញដែនដីយើង ដ្បិតភាសា
នេះផ្តិតជាប់នៅក្នុងលទ្ធិសាសនាព្រាហ្មណ៍ និងពុទ្ធសាសនា
បែបមហាយានៗ ខ្មែរយើងកាលនោះ សុទ្ធសឹងតែគោរ
លទ្ធិសាសនាព្រាហ្មណ៍ជាភាគច្រើន និងពុទ្ធសាសនាមហា
យានខ្លះៗ ព្រោះជនជាតិឥណ្ឌៀត្រកូលកោណ្ឌញ្ញ ដែលបា
មកបោះដំរុំយ៉ាងស៊ប់សួនលើដែនដីគោកធ្លកនោះ សុទ្ធតែ

កគោរពទំនៀមនិយមសាសនាទាំងពីរខាងលើនេះទាំងអស់គ្នា ។

គទៅនេះ យើងសូមជូនសេចក្តីដកស្រង់ពីសិលាចារឹកពណាមួយជាភាសាសំស្រ្កឹតតែប្រែជាភាសាខ្មែរ សំរាប់ជាការប្រៀបធៀបកំពស់អក្សរសាស្រ្តសម័យមុនអង្គរនឹងសម័យយើងក្នុងបច្ចុប្បន្ន ។ សេចក្តីដកស្រង់នោះយើងបានស្រង់ចេញពីសៀវភៅ «ពុទ្ធសាសនា ២៥០០» ជាសេចក្តីប្រែរបស់ព្រះភិក្ខុប៉ាង-ខាត់ ដែលបោះពុម្ពផ្សាយក្នុងឱកាសបុណ្យព.ស. ២៥០០ មានសេចក្តីដូចខាងក្រោម ៖

«... ព្រះវររាជាទ្រង់បានប្រកាសក្នុងរាជសភាថា បុរប្រ-ជាជនក្រេបផឹកនូវទឹកអម្រឹត ពោលគឺព្រះបន្ទូលព្រះបាទជាវង្សនៃព្រះបាទស្រីមារៈ ទ្រង់បានជាកិត្តិយសនៃរាជវង្សស្រីមារៈ ទ្រង់បានប្រកាសក្នុងកណ្តាលជំនុំជននូវព្រះរាជបន្ទូលសួរសីហនាទ ជាប្រយោជន៍ដល់ប្រជាជនទាំងឡាយទ្រង់ជាករុណាទាំងពីរដ៏ប្រសើរ ទ្រង់ប្រចាប់លើសិង្ហាសនៈហើយទ្រង់ឈ្វេងយល់នូវគតាគតិ គឺការអន្ទោលស្លាប់កើត

« នៃមនុស្សលោក ទើបត្រាស់ថា «កាលបើកូនខ្ញុំ បន់ប្រ

« ខ្ញុំក៏ មិនមែនអ្នកកន្ទៀតទេ បានសម្រេចបំណងអ្នកហើយ

« ខ្ញុំសូមឲ្យយកសម្បត្តិខ្ញុំទាំងអស់ ប្រាក់មាស សង្ហារិម

« អសង្ហារិមក្តី ទៅប្រើជាត្រូវសក់បជាទីរកកយ ទឹង

« ប្រយោជន៍ដល់សត្វលោកទាំងឡាយ ។ នេះជាសេច

« បញ្ជាក់របស់ខ្ញុំ ។ សូមព្រះរាជាទាំងឡាយនៅក្នុងអនាគ

« ប្រតិបត្តិតាមបញ្ជាខ្ញុំនេះកុំបីខាន ។

. . . . . . . . . . . . . . . . . . . .

សេចក្តីដកស្រង់របស់យើងខាងលើនេះ ជាស្នាព្រះហ
របស់ព្រះរាជាខ្មែរមួយអង្គកាលពីក្នុងសតវត្សទី ៣ នៃគ្រិស្ត
សករាជ គឺព្រះបាទ "ស្រីមារៈ" ដូចភស្តុតាងបញ្ជាក់ព្រះនា
ព្រះអង្គក្នុងអត្ថបទខាងលើស្រាប់ ។ សិលាចារឹកនេះគេប្រ
ឃើញនៅឯវ៉ូកាញ់ ក្នុងខេត្តញ៉ាត្រាំង (ប្រទេសវៀតណាម
ដែលពីដើមទីនោះជាអាណាខេត្តខ្មែរមួយដែរ ។ សេច
បរិយាយរបស់សិលាចារឹកនេះ ជាព្រះរាជបន្ទូលរបស់ព្រះបា

ីមារៈ គឺព្រះបាទហ្វាន់ ម័ន ដែលឯកសារចិនបានថ្វាយ
ះនាមព្រះអង្គតាមទំនួលការសារចិនថា «ហ្វាន់-ចេម័ន» ។ ក្នុង
ដែលព្រះអង្គបានឡើងគ្រងរាជ្យហើយ គឺចាត់ចែងរៀប
ហង់សិលាចារឹកនេះ ទុកជាដំណាងព្រះរាជឧត្តមគតិរបស់
ះអង្គ ។ បានសេចក្តីថា៖ ព្រះបាទស្រីមារៈជាបឋមវង្សនៃ
គ្រខ្មែរ មានព្រះរាជហឫទ័យជ្រះថ្លាទ្រង់តែងសន្តោសដល់
ជាពលរដ្ឋខ្ញុំទៅគ្រប់ប្រការ ដោយទ្រង់យល់ច្បាស់នូវជំ-
ភីរ គតាកតិ ការវិលកើតវិលស្លាប់របស់មនុស្សក្នុងកាល
សង្សារ ។ ទ្រង់បានបរិច្ចាគព្រះរាជទ្រព្យធ្វើជាទានដល់
ជារណជន ។ មិនតែប៉ុណ្ណោះ ទ្រង់បានត្រាស់ផ្តាំផ្ញើដល់
ះរាជាជាជំណាក្រោយ ៗ មក សូមឲ្យទ្រង់មានព្រះមេត្តាធម៌
ព្រះអង្គដែរ ។ ដើម្បីទីងទុកជាសក្ខីភាពនូវព្រះរាជបំណង
ថ្លារបស់ព្រះអង្គ ទើបព្រះបាទស្រីមារៈ បានចាត់ចែង
សិលាចារឹកនេះឡើង ទុកជាកេរ្តិ៍ដំណែលរហូតដល់រាប់
ន់ឆ្នាំក្រោយមក គឺយើងនៅស្គាល់បានយ៉ាងច្បាស់ប្រាកដ

នូវព្រះរាជកាយវិការ ដ៏ប្រសើររបស់ព្រះរាជាអង្គនេះ

ប្រយោជន៍សំខាន់ម្យ៉ាងទៀត សិលាចារឹកនេះមិនគ្រ
តែកត់ត្រាទុកនូវព្រះរាជបំណងរបស់ព្រះអតីតមហាក្សត្រ
ប៉ុណ្ណោះទេ អាចរាប់បានជាវណ្ណកម្មមួយសំរាប់ឲ្យយើងឃើ
ជាក់ច្បាស់ពីការប្រើប្រាស់តួអក្សរ និងសំនួនពាក្យពេចន៍
ភាសាខ្មែរសម័យនោះផង ។ គឺថា ពតិមានផ្សេង ៗ ទ
អក្សរសាស្ត្រខ្មែរដែលយើងស្គាល់បាន អំពីស្នាដៃសម័យដ៏
គឺសម័យមុនអង្គរនោះ ក៏ដោយសារតែផ្ទាំងសិលាចារឹក
នោះឯង ។ ប៉ុន្តែយើងស្តាយជាបំផុត ព្រោះពេលវេ
ពុំអាចបើកឱកាសឲ្យយើងដកស្រង់ស្នាដៃឯទៀត ៗ ដែល
ក្នុងសម័យជាមួយ ៗ គ្នា មកបញ្ជាក់ឲ្យបានសព្វគ្រប់ សមគ
បំណងឡើយ ព្រោះឯកសារទាំងនោះនៅស្ងួចស្តើងពិត
ពេក ។ ដូចនេះហើយ បានជាយើងព្យាយាមសំរាំងយ
តែស្នាដៃណាដែលងាយស្តាប់ងាយយល់ និងប្រកបដោ
លក្ខណៈអក្សរសាស្ត្រ ពិត ៗ មកធ្វើការពិភាក្សាជាមួយអ

លោកអ្នកឲ្យបានឃើញជាក់ច្បាស់ល្អិតអំពីបញ្ហាទាំងនេះ គឺពិតជាបញ្ហានៅក្នុងសភាពស្មុគស្មាញនៅឡើយ ។

សរុបសេចក្តីទៅ សម័យទីមួយនៃអក្សរសាស្ត្រយើង គឺជាសម័យដែលបុព្វបុរសខ្មែរខិតខំប្រឹងបង្កើត បានជារូបជាអង្គនៃតួអក្សរនិងប្រឹងរកមធ្យោបាយផ្សាយនូវអក្សរនេះ ឲ្យជនគ្រប់គ្នាបានចេះបានយល់សំរាប់ជាប្រទីបមួយ ជួយបំភ្លឺផ្លូវឲ្យយើងដើរត្រេចទៅកាន់ត្រើយវិឌ្ឍនធម៌ ។ ប៉ុន្តែ សម័យមុនអង្គរនេះ ទីក្រុងខ្មែរ មិនបានតាំងទីនៅកន្លែងមួយជាប់លាប់ទេ គឺចេះតែមានការប្តូរផ្លាស់ជាញឹកញយ ដូចជាប្តូរពីវ្យាធបុរៈ ទៅឥសាណបុរៈ រួចទៅ មហិន្ទ្របុរៈ ជាដើម ។ អ្នកប្រវត្តិសាស្ត្របានសន្និដ្ឋានសម័យដំបូងនេះ ហៅថាសម័យ «នគរភ្នំ» ត្រូវនឹងអ្នកកត់ត្រាជាតិចិនហៅថា ហ្វូណាម ដែលក្លាយមកដល់យើងថា «ហ្វូណន» ។ ព្រោះហេតុតែមានការ តាំងទីក្រុងមិនស្ថិតស្ថេរដូចនេះហើយ ទើបសិលាចារឹកខ្មែរចេះតែលេចឃើញមានឯនេះមួយ ឯនោះមួយ សឹងតែពាស

ពេញអាណាចក្រ ។ ក្រោយពីសិលាចារឹកទាំងនេះ យើង
ពុំមានប្រទះឃើញស្នាដៃអ្វី ជាដុំកំភួនល្មមយកជាការបានទេ
ទៀត ពេលវេលាពីនោះមកដល់ឥឡូវនេះ ជាយូរអង្វែងណាស់
ផង ក្រោយពីដុំថ្មមិនអាចមានអ្វីនៅគង់វង្សបានយូរឡើយ ។

សម័យមុនអង្គរ របស់អក្សរសាស្ត្រយើងបានចប់ត្រឹមចុង
បំផុតនៃសតវត្សទី ៨ នៃគ្រិស្តសករាជ គឺនៅគ្រាដែលព្រះបាទ
ជ័យវរ្ម័នទី ២ បានលើកទីក្រុងទៅតាំងនៅអង្គរ ។



## ជំពូកទីប្រាំពីរ

# អក្សរសាស្ត្រសម័យអង្គរ

សម័យអង្គរ រាប់តាំងពី គ.ស. ៨០២ គឺគ្រាដែលព្រះបាទជ័យវរ្ម័នទី ២ បានចាប់កសាងទីក្រុងជាដំបូងនៅឯអង្គរ មានកំពុបាខែងជារាជធានី រហូតដល់ គ.ស. ១៤៥២[១] ដែលព្រះបាទស្រីសុរិយោពណ៌ ចៅពញាយ៉ាត បានលើកទីក្រុងចាកចោលអង្គរមកតាំងនៅចតុមុខវិញ ។ រយៈកាលខាងដើមនៃសម័យនេះ ប្រជាជនខ្មែរជាប់ចិត្តជាប់គំនិត យ៉ាងស៊ប់ស្ងួននៅក្នុងលទ្ធិព្រហ្មញ្ញសាសនា នឹង ពុទ្ធសាសនាមហាយាន ។ ហេតុនេះឯង ទើបភាសាសំស្ក្រឹតជាមូលដ្ឋាននៃលទ្ធិទាំងពីរនោះ បានទទួលកិត្តិយសជាភាសាផ្លូវការ សព្វកិច្ចការផាន់

១– តាម M. A. LECLÈRE, Histoire du Cambodge, ប៉ា ១៣៨៨ ។

ខ្ពស់ផ្សេងៗ ក្នុងផ្នែកអាណាចក្រតាំងមូល ។ ពាក្យពេចន៍សំរប
ប្រើប្រាស់ទាំងឡាយ ទោះជាខាងវណ្ណកម្មក្ដី ខាងភាសា
និយាយធម្មតាក្ដី ក៏សុទ្ធតែលាយប្រឡំដោយភាសា
សំស្រ្កឹតទាំងអស់ ។ ដូចនេះហើយ ទើបភាសាយើងក្នុងគ្រា
បច្ចុប្បន្ននេះ ក៏នៅមានលាយប្រឡូកប្រឡំភាសាសំស្រ្កឹត
នៅឡើយ ។ ហេតុដែលនាំឲ្យយើងហ៊ានពោលថា អក្សរ-
សាស្រ្តយើងទោះផ្នែកវណ្ណកម្មក្ដី ផ្នែកភាសាធម្មតាក្ដី សុទ្ធ
តែលាយលុកគ្នានឹងភាសាសំស្រ្កឹតនោះ ព្រោះយើងឃើញ
ពាក្យខ្មែរសព្វថ្ងៃជាច្រើនម៉ាត់, ច្រើនពាក្យ ដែលប្រជាជននាំ
គ្នានិយាយឆ្លងឆ្លើយរៀងរាល់ថ្ងៃ គឺពិតជាពាក្យក្លាយចេញពី
ជាពាក្យសំស្រ្កឹតសុទ្ធៗមែន ដូចជាពាក្យថា: មិត្រ, ពិចិត្រ,
សួស្ដី ធម៌, គតិ, ពណ៌, អារ្យធម៌, ព្រះ, ប្រព្រឹត្ត, គោ,
សក្សី, ក្សោ, សង្គ្រោះ, ឈ្មោះឬគ្រោះ . . . ជាដើម ។ ពាក្យ
ទាំងនេះ ជនជាតិខ្មែរយើងប្រើប្រាស់តែមកតាំងពីមនុស្ស
ចាស់ រហូតដល់ក្មេងតូច ហាក់ដូចជាក្មេងខ្ចីសូម្បីឈឺ

ាពាក្យទាំងនេះ ខ្មែរបានប្រឌិតយកពីភាសាសំស្ក្រឹត តាំង
ីអតីតកាលយូរអង្វែងណាស់មកហើយ ។ ពាក្យទាំងនេះ
ានក្លាយទៅជាពាក្យខ្មែរសុទ្ធ ។ អស់ទៅហើយក្នុងគ្រាឥឡូវ
នេះ ប៉ុន្តែអ្នកស្រាវជ្រាវនៅតែទទួលស្គាល់គ្រប់គ្នាថា: ពាក្យ
ទាំងនោះ ពិតជាខ្មែរប្រឌិតយកពីភាសាសំស្ក្រឹតមែន ។

ចំពោះវណ្ណកម្មវិញ យើងឃើញជាភស្តុតាងហូតដល់
សព្វថ្ងៃនេះនូវរឿងរ៉ាវ ដែលខ្មែរបុរាណសរសេរសម័យនោះ
ព្រមទាំងសិលាចារឹកទាំងឡាយ ដែលស្ថាបនាឡើងនៅគ្រា
ជាមួយគ្នាដែរ មានសុទ្ធតែពាក្យពេចន៍ ឬ សំនួនវោហារល្អ
ឥតខ្ចោះ លាយច្របល់ដោយពាក្យខ្មែរបុរាណនិងសំស្ក្រឹត
ដូចជាសិលាចារឹកនៅបាយ័ន, នៅព្រះខ័ន, នៅបន្ទាយឆ្មារ,
នៅភ្នំជីសូរ និងប្រាសាទនានាដែលកើតដំណាលគ្នា ឬ ជា
នៅក្នុងរឿងរាមកេរ្តិ៍ ជាដើម ។ ដូចជាយើងបានពោល
រួចមកហើយ ថារឿងរាមកេរ្តិ៍ខ្មែរមិនមែនប្រែត្រង់ ។ ពីរឿង
រាមាយណៈ ឥណ្ឌៀសុទ្ធសាធទេ គឺខ្មែរគ្រាន់តែប្រឌិតបែប

តាមម៉ុណ្ណោះ មានវគ្គខ្លះក៏ឃ្លាតចាកពីរឿងដើម មានវគ្គខ្លះ ក៏ដូចប្រយោគប្រហែលគ្នាទៅ ៗ រឿងរាមកេរ្តិ៍ ជារឿងទីមួយ របស់ខ្មែរយើង ព្រោះចំណោមរឿងទាំងអស់ គ្មានរឿង ណាដែលមានអាយុចាស់ជាងរឿងនេះទេ ។ ហេតុដែល ឲ្យគេកស់ចំណាស់រឿងនេះបាន ព្រោះមានអ្នកប្រាជ្ញជាច្រើន រូបបានពិនិត្យស្រង់តែរឿងនេះយ៉ាងហ្មត់ចត់បំផុត ដើម្បីរាវរក ពេលវេលាដែលកសាងរឿងនេះ ប៉ុន្តែមិនបានងាយសោះ ព្រោះនៅខាងដើមនៃរឿងនេះ ពុំមានចារឹកថ្ងៃខែ ឬ នាមអ្នក និពន្ធឲ្យយើងឃើញឡើយ គ្រាន់តែមានពាក្យពេចន៍ទំនងស្ទួន វោហារក្នុងនោះប៉ុណ្ណោះ ដែលសំរាប់ទាញសតិអារម្មណ៍ របស់អ្នកអានឲ្យប្រមាណយ៉ាងច្បាស់ថា រឿងនេះពិតជាកើត នៅក្នុងសម័យអង្គរមែន ព្រោះមានចំឡាក់ថ្ម ទីន ទេពទិតាន ចាស់ៗ បង្ហាញជាភស្តុតាងផង ។

ដើម្បីធ្វើជាសក្ខីភាពបង្ហាញដល់អស់លោក-អ្នក យើង សូមស្រង់សេចក្តីខ្លះ ក្នុងរឿងរាមកេរ្តិ៍យកមកធ្វើការពិភាក្សា

ពិនិត្យបញ្ហាកថា តើរឿងនេះពិតជាលាយភាសាសំស្រ្កឹត ទីនកែផ្ទួររឿងរបៀបខ្មែរឬទេ ។

សេចក្ដីដកស្រង់នេះ យើងស្រង់តាមសៀវភៅបោះពុម្ព ដែលផ្សាយចេញពីក្រុមពុទ្ធសាសនបណ្ឌិត្យ ក្នុងសៀវភៅ ភាគទី ១ មានសេចក្ដីដូចតទៅ ៖

. . . . . . . . . . . . . .

« . . . ព្រះរាមស្ដេចមើលអស់កូ-ធរលើកបុទ្ធិធនូ ក៏ព្រើស
« ព្រះកក្រ្កប្រឹមប្រើយ៍ ៗ ស្ដេចចូលលង់បុទ្ធិដ៏ពិធី អស់ទេព
« ដឹតសី ក្យគ្រូវតអានុភាពបេស្ដា ៗ ព្រះរាមរើងបុទ្ធិមហិមា
« ស្ដែងស្ដេចចេស្ដា-ធិការនុភាពលើសក្រៃ ៗ ស្ដេចលើកកៅ-
« ទណ្ឌសរជ័យ អស់ទេពមនុស្សញ ដ៏មានកំឡុងលោកធាតុ ៗ
« សឹងថ្វាយសព្ទសាធុការសោទរ ព្រះបរមនាថ បុទ្ធីអំណាច
« យល់ច្រើន ៗ ផ្ទួចថា ឥតកៅ ឲ្យឈើដុះទទឹង កោះសរសេក្ដិ
« ច្រើន សរម្ដងនូវគេជប្រគៀក្ស ៗ ស្ដេចក្រាយកៅទណ្ឌ-
« សរសក្ដិ រួមណ្ឌលចក្រ រំកាយព្រះករសោភា ៗ ជង់នោះ

« ព្រះបាទមិថិលា ស្ដេចយល់ដ៏ឫទ្ធា - នុភាពព្រះរាមលើស
« ក្រៃ ស្ដេចត្រេកអរឲ្យពរជ័យ ជយោជ័យក្រៃ សំរិទ្ធិរាម
« មហិមា ។ ស្ដេចយករ័តន៍ពជសីតា ប្រកបនូវលក្ខណា
« ក៏ថ្វាយព្រះរាមក៏គន្ធង ។ អស់តាំងមុខមន្ត្រីផង ប្រើទូត
« ទៅចង់ មេត្រីព្រះបាទទសរថ ។ ស្ដេចផ្ដាំទូតទៅបីកំណត់
« ថ្កានព្រះទសរថ បីលុះបុរីអយុធ្យា ។

. . . . . . . . . . . . . . . . .

អត្ថបទដែលជាសេចក្ដីដកស្រង់របស់យើង ខាងលើនេះ ពណ៌នាកាលដែលព្រះចៅមិថិលា រើសបាន នាងសីតាពីក្នុងផ្កាឈូក ហើយទ្រង់ប្រកាសអំពាវនាវថា បើជនណាមានរិទ្ធិ គេងដៃ អាចលើកធ្នូរបស់ព្រះអង្គរូប នោះព្រះអង្គនឹងអភិសេក ព្រះនាងសីតាឲ្យជាមហេសី ។ កាលនោះមានព្រះឥន្ទ, ព្រះព្រហ្ម ព្រះឥសូរ, ព្រះនារាយណ៍ និងទេវតាដ៏ច្រើនបានមក ល្បងបុទ្ធ ប៉ុន្តែមិនបានសំរេចប្រាថ្នាសោះ ។ កាលទ្រង់ជ្រាប ពត៌មាននេះ ព្រះរាមក៏ទ្រង់យាងជាមួយព្រះលក្សណ៍ផា

ដរទៅដល់ក្រុងមិថិលា ហើយល្បែងលើកធ្នូបេស្កានោះបាន
រចដូចព្រះបំណង ។ ក្នុងអត្ថបទនេះនិយាយថា៖ ព្រះរាម
ង់លើកធ្នូរឹទ្ធិ ដោយព្រះភក្រ្តប្រឹមប្រិយ សឹងមានទេពតា
ថ្វាយពរគ្រប់គ្នា ។ ត្រង់ឃ្លាមួយចំកណ្ដាលអត្ថបទ
កក់ប្រាប់យើងពីមហិទ្ធិឫទ្ធិនៃព្រះរាម ដែលសឹងស្រស់
ាងដោយពាក្យឥតខ្ចោះគួរចាប់ចិត្ត គឺត្រង់ឃ្លាថា៖ «ស្ដេច
យកៅចំណូសរសក្តិ រូមណ្ឌលចក្រ រំភាយព្រះករ
ាកា ។» ឃ្លានេះបានសេចក្ដីថា៖ ព្រះរាមទ្រង់ចាប់យក
ះហើយត្រវីកាច់កែព្រះកាយរបស់ព្រះអង្គ រឹងចុងធ្នូដែល
ទៅដោយសារកម្លាំងព្រះហស្ដរបស់ព្រះអង្គនោះ ឃើញ
ណ្ឌានប័ដូចជារង្វង់កង់អ៊ីមួយ គួរឲ្យគយគន់គោតក្រៃលែង
យទ្រង់រំសាយចុងព្រះហស្ដ ប្រកបដោយព្រះកាយវិការ
មរម្យឥតខ្ចោះ ។ ទីបំផុត ព្រះចៅនគរមិថិលាក៏សព្វ
រាជហឫទ័យថ្វាយព្រះនាងសីតា ដែលប្រកបដោយរូប
មប្រិមប្រិយទៅព្រះរាមបេស្កា ។ ហើយស្ដេចទ្រង់ចាត់

ឲ្យរាជទូតទៅតាមជង្ហែព្រះបាទទសរថ ជាព្រះវរបិតាព្រះ
មកបានទតព្រះអង្គ ដើម្បីរៀបអភិសេកព្រះរាជបុត្រទាំងគូ
ការសប្រកបដោយសុភមង្គលនេះ ។

រឿងរាមកេរ្តិ៍ អាចចាត់ទុកជាវណ្ណកម្មមួយយ៉ាងវិសេ
ហើយរឿងនេះតែងបានទទួលការនិយមពីសំណាក់បណ្ដា
គ្រប់ប្រភេទ ។ អានុភាពរឿងនេះ បានហូរស្រោចស្រ
ទៅក្នុងដួងចិត្ត, ដួងថ្លើម នៃប្រជាពលរដ្ឋគ្រប់និគមជនប
រៀងរាល់ពេលឥតអាក់ ។ ឯមធ្យោបាយផ្សាយសោភ,
តាមការស្រាវជ្រាវរបស់អ្នកប្រាជ្ញជាច្រើនរូប, គេអាចប្រមូ
បានមកសំខាន់ៗដូចតទៅនេះ ៖

ក- គេផ្សាយដោយចងក្រងជាក្រាំង សំរាប់ទុកអាន ឃ្លានគ
ទៅជាយូរឆ្នាំ គឺទុកជាលក្ខណ៍គោលត្រឹមត្រូវ ។

ខ- គេផ្សាយដោយសារក្រុមល្ខោន ឬ ក្រុមរបាំផ្សេង
ដែលតែងតែលេងរឿងនេះ នៅចំពោះមុខសាធារណជន
ស្រុក, តាមភូមិជិតឆ្ងាយ ។

គ- គេផ្សាយដោយសារអ្នកចាំរឿង ឬ អ្នកនិពន្ធរឿង
ដែលតែងតែនាំយករឿងនេះ ទៅនិពន្ធក្នុងទីប្រជុំជន ទៅ
តាមបុណ្យអ្វីមួយ ។

ឃ- គេផ្សាយតាមរូបចម្លាក់ និងគំនូរតាមជញ្ជាំងសាលា
នៅទីវត្តអារាមនានាក្នុងប្រទេសយើង ។

មធ្យោបាយទាំងនេះ នៅមានអានុភាពពេញទីក្នុងស្រុក
យើងគ្រាបច្ចុប្បន្ននេះនៅឡើយ ព្រោះយើងតែងប្រទះឃើញ
អ្នកចាំរឿងនេះជាច្រើនរូប ទោះបីជាចាំតែបន្តិចបន្តួចក៏គេ
នៅតែបរិយាយប្រាប់គ្នាដើម្បីជាគ្រឿងកែអផ្សុក ឬ ជាពាក្យ
ប្រដៅអប់រំអន់ចិត្តសាន្តចិត្ត ។ ហេតុដែលនាំឲ្យមានការនិយមដល់
រឿងនេះ ព្រោះរឿងកាកីនេះមានលំអពាក្យពេចន៍ និង កិច្ចកល
ក្នុងរឿងបែបចម្បាំងក្តី, បែបស្នេហាក្តី, បែបសោកសង្រេងក្តី
ឬ បែបពិពណ៌នាក្តី សុទ្ធតែល្អស្រស់បំព្រងដូចៗគ្នា គ្រាន់
តែរឿងនេះ មានផ្លូវរឿងផ្តេកទៅតាមលទ្ធិព្រាហ្មណ៍សាសនា
ប៉ុណ្ណោះ ។

នៅក្នុងសម័យអង្គរនេះ ខ្មែរនាំគ្នាលើកស្ទួយភាសាសំ
ស្រ្កឹតឲ្យបានឡើងដល់ឋានៈខ្ពស់បំផុត ។ សិលាចារឹកនា
ដែលកើតឡើងដោយការឧបត្ថម្ភនៃព្រះរាជា ឬ ជនដែលមា
ឋានៈខ្ពង់ខ្ពស់ណាមួយ សុទ្ធតែសរសេរជាភាសាសំស្រ្កឹ
តាំងអស់ ។ ហើយនៅក្នុងនោះ ប្រកបដោយសំនួនពោ
លេបខាយវិចិត្រដោយពាក្យសំស្រ្កឹតសុទ្ធ ៗ ផង ។ យើ
ស្តាយជាបំផុត ព្រោះពុំអាចលើកសិលាចារឹកជាភា
សំស្រ្កឹតសុទ្ធមកលាតត្រដាងបាន ព្រោះហេតុការណ៍មិ
បើកឱកាសឲ្យយើងផង ហើយមួយទៀត ភាសានេះជ
ប្លាក់ជាភាសាស្ទាប់មិនសូវមានអ្នកនិយមផង ។ ហេតុ
យើងត្រៀតស្រង់ សេចក្តីប្រែសំរួលពីសិលាចារឹកក្នុងសម័
អង្គរមកបញ្ជាក់ជាភស្តុតាងខ្លះបង្ហាញឲ្យឃើញថា ពេលនេ
ពិតជាមានហេតុការណ៍ដូចយើងពណ៌នាមែន ។ ប្រយោ
តាំងឡាយខាងក្រោមនេះ ជាសេចក្តីដកស្រង់ចេញពីស្នា
សិលាចារឹកនៅក្នុងសម័យអង្គរ ដែលមាននាមអ្នកនិពន្ធ

គុបខនោះជាប់ជាមួយផង ។ ដើម្បីឲ្យសមរម្យត្រូវតាម
បៀបសិក្សាអក្សរសាស្ត្រ យើងនាំយកនូវនាមនិងជីវប្រវត្តិ
ន្ធេប ៗ របស់អ្នកនិពន្ធសម័យនោះ ព្រមទាំងស្នាដៃមកធ្វើ
សេចក្ដីអត្ថាធិប្បាយក្នុងវេលានេះ ដើម្បីបង្ហាញលោកអ្នក
ការបញ្ជាក់ផង និងជាគ្រឿងជំនួយស្មារតីមួយដល់អ្នក
សិក្សាអក្សរសាស្ត្រខ្មែរយើងផង ។

ក្នុងសម័យអង្គរនេះ គេស្គាល់ឈ្មោះអ្នកនិពន្ធសិលាចា-
ប្រាំមួយរូប ដែលមាននាមជាក់ប្រាកដទុកកេរ្តិ៍ដំណែលដល់
យើងគ្រប់គ្នា គឺបណ្ឌិតទិវាករ, បណ្ឌិតយតិអមរភាវ, បណ្ឌិត
ន្ទ្រៈ, បណ្ឌិតកវីន្ទ្រៈ, បណ្ឌិតសិវសោម និង ព្រះនាង
ទ្រទេវី ។

ស្នាដៃដែលយើងលើកយកមកបង្ហាញខាងក្រោមនេះ
ដែលបានដកស្រង់ធ្វើជាសេចក្ដីប្រែសំរួល[១] និង ធ្វើជា
សេចក្ដីអធិប្បាយបន្ថែមពីជីវប្រវត្តិ តាមលំដាប់មុនក្រោយ

១– សេចក្ដីដកស្រង់នេះយើងសម្រួលពីសៀវភៅ Inscriptions du Cambodge, របស់ G. Cœdès.

សំរាប់ជាឯកសារដល់អ្នកត្រូវការសិក្សាអក្សរសាស្ត្រដូចតទៅ

១- បណ្ឌិតសិរីសោម.- បណ្ឌិតនេះជាអ្នកចេះ
ស្ទាត់នូវក្បួនច្បាប់តាំងឡាយខាងផ្នែកអក្សរសាស្ត្រ និងមន្តវិ
គាថាផ្សេង ៗ ។ លោកបានចងក្រងជារឿងក៏វនិងក្បួនខ្នា
ជាច្រើន មានរឿងមហាការគៈ, ក្បួនវេយ្យាករណ៍ជាដើម
លោកបានទទួលប្រោសប្រាណពីសំណាក់ព្រះមហាក្សត្រ
ខ្មែរសម័យនោះ និងជាពជគ្រូផ្ទាល់របស់ព្រះបាទឥន្ទ្រវរ្ម័ន
ស្នាដៃរបស់លោក បានគង់នៅ និងសិលាចារឹកប្រាសា
កណ្ដាលដើម ដែលយើងស្រង់សេចក្ដីបន្តិចដូចខាងក្រោម

. . . . . . . . . . . . . . . . . .

" . . . . . សូម្បីបើលាក់ខ្លួនពួនអាត្មាក្នុងព្រៃស្ងា
" ដោយ ពជសត្រូវក្ដីស្ងាត់ដោយប្រទីបជ័យជំនះរបស់ព្រះ
" តែចូលមកជ្រកក្រោមព្រះបាទ ហាក់ដូចជាខ្លាចព្រ
" ព្រះអង្គចាប់បានជាថ្មីទៀត ។ . . . . . . "

ពាក្យយ៉ាងខ្លីខាងលើនេះ អ្នកនិពន្ធសិរីសោម សរសេរ
ះបារមីនៃព្រះបាទឥន្ទ្រវរ្ម័ន ដែលមានបុណ្យានុភាពនាំឲ្យ
សត្រូវនៅគ្រប់ទិសទីសុខចិត្តនាំគ្នាមកចុះញ៉មក្រោមព្រះ
ស្តារបស់ព្រះអង្គ ។

២- បណ្ឌិតយតិអមរការៈ ជាអ្នកប្រាជ្ញឯកក្នុង
កាលព្រះបាទយសោវរ្ម័ន ដែលព្រះអង្គទ្រង់ប្រោសព្រះរាជ
នឋានន្តរសក្តិ ជាអធិបតីលើចំណោមបណ្ឌិតទាំងឡាយ
ងសម័យនោះ ព្រមទាំងជាសង្ឃរាជលើវត្តឥន្ទ្រាស្រមដែល
មជ្ឈមណ្ឌលខាងលទ្ធិសាសនាព្រាហ្មណ៍ ។ លោក
កស្នាដៃក្នុងសិលាចារឹកនៅកំបាយ័ក្ខ ដែលយើងស្រង់យក
ចក្តីបន្តិចដូចតទៅ ៖

. . . . . . . . . . . . . . . .

" ... សូមព្រះសិរៈដ៏មានជតាធំ ហើយដែលមានព្រះបាទ
ធ្ងន់ជាន់រាវណទសមុខឲ្យស្រែកថ្ងូរទ្រហឹងពេញអាកាស
ដោយសេចក្តីឈឺចាប់, ថែរក្សានូវសម្បត្តិរបស់អ្នក ។ ... "

ប្រយោគទី២ខាងលើនេះ បណ្ឌិតយតិអមរគោរៈ សុំ
ព្រះឥសូរដែលមានបុទ្ធអំណាច អាចនឹងជាន់លើកយក្សរាវ
ដែលមានមុខដប់ឲ្យស្រែកថ្ងូរដោយចាញ់ប៉ារមីបាននោះ សូ
ឲ្យមកជួយថែរក្សានូវសេចក្ដីសុខរុងរឿងរបស់ប្រជានុក
ទាំងឡាយកុំបីខានឡើយ ។ នេះឯងជាសេចក្ដីអំពាវ
របស់សិលាចារឹក កើតឡើងដោយព្រះរាជបុត្តានៃព្រះប
យសោវរ្ម័ន គឺជាព្រះមហាក្សត្រត្រៀវក្លាមួយអង្គក្នុងសតវត្ស
ដែលបានរៀបចំកសាងប្រាសាទអង្គរធំ ។

៣–បណ្ឌិតធិវាករៈ–(1) ជាកវីនិពន្ធយ៉ាងឯកដ៏ន
រជ្ជកាលនៃព្រះបាទពជិន្ទ្រវរ្ម័ន ។ លោកចេះស្ទាត់
វិជ្ជាត្រ័យវេទ អាចសែកមន្តអាគមធ្វើទំពសត្រូវឲ្យវិនា
ខ្ទាត់ខ្ទាយបាន ។ បណ្ឌិតនេះ បានទទួលសេចក្ដីប្រ
ប្រណពីព្រះរាជាយ៉ាងគាប់ចិត្តក្រៃលែង គឺព្រះអង្គប
ប្រទាននូវបុត្រីមួយអង្គព្រះនាម « ឥន្ទ្រលក្ស្មី » ឲ្យធ្វើជាភរិ

(1) . G. Cœdès Insc. du Cambodge I. p 37.

បណ្ឌិតទិវាករ ។ ស្នាដៃលោកលាតត្រដាងនៅក្នុងផ្ទាំងសិលាចារឹកប្រាសាទកំពីស ដែលយើងដកស្រង់សេចក្ដីខ្លះ ៗ ដូចតទៅ ៖

“. . . . ឆេះរោលរាលដោយព្រួញទិព្យរបស់ព្រះអគ្គិ មហាព្រៃនៃពួកសត្រូវលែងលូតលាស់ឡើងវិញ សូម្បីបើស្រោចស្រប់ដោយទឹកភ្នែកពួកទីប្រឹក្សាក៏ដោយ ។ . . . .”

ក្នុងឃ្លាយ៉ាងខ្លីខាងលើនេះ អ្នកនិពន្ធទិវាករ បានសរសើរឫទ្ធិបារមី នៃព្រះបាទជយវរ្ម័នទី-៥ ដែលជាក្សត្រប្រកបទូវបារមីក្លៀវក្លា បង្ក្រាបអស់ពួកសត្រូវដែលមាននៅគ្រប់ទិសដំបន់ដែលអ្នកនិពន្ធ បានប្រៀបប្រដូចនឹងមហាព្រៃឲ្យស្ងប់ស្ងាត់ឈឹងសូន្យ ទោះបីជាមានពួកទីប្រឹក្សាប្រឹងដាស់តឿនរំលឹកយ៉ាងណាក៏ដោយ ។

៤- បណ្ឌិតគារិន្ទ្រ :- ជាអ្នកនិពន្ធយ៉ាងឆើតមួយរូបក្នុងរជ្ជកាលនៃព្រះបាទសុរ្យវរ្ម័ន ។ លោកបានរៀនចេះស្ទាត់នូវគម្ពីរក្បួនខ្នាតផ្សេង ៗ ហើយជាអ្នកមានប្រាជ្ញាវាងវៃ

បំផុត អាចនឹងដោះស្រាយនូវបញ្ហាអ្វី ៗ យ៉ាងពិបាកបានយ៉ាងឆាប់រហ័ស ។ ហេតុនេះហើយ ទើបព្រះកជាសត្វព្រះទ័យតែងតាំងជាទីប្រឹក្សារបស់ព្រះអង្គ ។ ស្នាដៃលោកមានពិស្ដារក្នុងសិលាចារឹកប្រាសាទខ្នា ដែលយើងស្រង់សេចក្ដីមួយប្រយោគមកដាក់បន្ដទៅនេះ ៖

“. . . ក្នុងសង្គ្រាម គ្រឿងអាវុធដែលបច្ចាមិត្តវាត់មកយ៉ាងធ្ងន់លើព្រះអង្គដោយពេញទំហឹង ហាក់ដូចជាសត្វតូចមួយតិច ឬ ស្រីក្រទៅប៉ុណ្ណោះ ។ . . . .”

ក្នុងប្រយោគនេះ អ្នកនិពន្ធកវីន្ទ្រៈ បានបង្ហាញនូវចេស្ដានៃព្រះបាទសុរ្យវរ្ម័ន ក្នុងគ្រាដែលយាងចេញតយុទ្ធក្នុងរណរង្គ ។ អ្នកនិពន្ធបានពោលថា កាលបើសត្រូវប្រហារនូវសស្ត្រាវុធមកលើព្រះអង្គ ព្រះបាទសុរ្យវរ្ម័នឥតមានទ្រង់ញរញើតឡើយ ព្រោះឥតមានឈឺចាប់ដល់ព្រះកាយបន្តិចសោះ គ្រាន់តែសៅហ្មងបន្តិចទុកដូចជាសត្វតូចមួយតិច ឬ ដូចជាស្រីក្រទៅប៉ុណ្ណោះ ។

៨– បណ្ឌិតកូបទ្រៈ – បណ្ឌិតកូបទ្រៈ ជាអ្នកប្រាជ្ញមួយរូបក្នុងសម័យព្រះបាទជ័យវរ្ម័នទី-៧ ។ លោកជាអធិបតីលើគណៈអ្នកប្រាជ្ញទាំងឡាយ ដែលជាទីប្រឹក្សារបស់ព្រះរាជា ហើយលោកជាចៅក្រមយ៉ាងល្បីល្បាញផង ព្រោះជាអ្នកមានស្មារតីទូលំទូលាយខាងផ្លូវច្បាប់ [1] ។

យើងដកស្រង់ស្នាដៃរបស់លោកពីក្នុងសិលាចារឹកប្រាសាទ១០ ដែលមានសេចក្ដីដូចតទៅ ៖

« ... ទ្រង់ជ្រាបថា ផែនដីព្រះអង្គដែលទ្រង់បានកសាងឲ្យក្លាយទៅជាស្ថានសួគ៌ដោយព្រះប្រាជ្ញាញាណ, ត្រូវមរណៈព្យាបាទហើយ ទ្រង់ដឹកនាំឲ្យយកទឹកអម្រឹតធ្វើជាភេសជ្ជៈ ដើម្បីញ៉ាំងសត្វដែលត្រូវស្លាប់ កុំឲ្យស្លាប់ទៀត ។ . . . »

ប្រយោគខាងលើនេះ បង្ហាញពីសម្រស់ពាក្យពេចន៍ជាស្នាដៃរបស់អ្នកនិពន្ធឈ្មោះកូបទ្រៈ ដែលសរសើរព្រះកិត្តិគុណរបស់ព្រះបាទជ័យវរ្ម័នទី-៧ ដ្បិតព្រះចៅអង្គនេះ ទ្រង់មាន

(1) G. Cœdès, Insc. du Cambodge, I, p. 228,

ព្រះមេត្តាធម៌ក្រៃលែង ទ្រង់បានចាត់ចែងបង្កើតជាពេទ្យ-
បាលរោគសំរាប់ប្រជាជនជាច្រើនកន្លែង ទើបសេចក្ដីផ្ដើមនៃ
សិលាចារឹកនេះនិយាយថាៈ ព្រះអង្គទ្រង់យល់ថា ផែន
ដីដែលព្រះអង្គទ្រង់សាង ឲ្យមានសុខសាន្តសម្បូណ៌សប្បាយ
ដូចជាស្ថានសួគ៌នោះ ឥឡូវត្រូវរោគាព្យាធិមករុករានញាំញី
ហើយ, ទើបព្រះអង្គណែនាំនូវប្រជាជនជាទីសព្វព្រះទ័យ
ឲ្យកសាងនូវតាមផ្លូវល្អ ពោលគឺឲ្យផឹកនូវទឹកអម្រឹតរសជាតិ
សីលធម៌ព្រះពុទ្ធសាសនា និងកែរោគជនទាំងនោះ ដោយ
បង្កើតឲ្យមានក្រុមព្យាបាលជម្ងឺដោយឱសថផ្សេងៗ ។

៦– ព្រះនាងឥន្ទ្រទេវី.– ព្រះនាងឥន្ទ្រទេវីជា
អគ្គមហេសីទី ២ នៃព្រះបាទជ័យវរ្ម័នទី ៧ គឺព្រះនាងទ្រង់បាន
ទទួលរាជាភិសេកជាមួយព្រះចៅផែនដី ក្រោយដែលព្រះ
មហេសីដើមជាព្រះកនិដ្ឋាបង្កើតរបស់ព្រះនាងទទួលទិវង្គត
ហើយ ។ ព្រះនាងឥន្ទ្រទេវីទ្រង់បានណែនាំព្រះរាជាឲ្យ
មានព្រះទ័យជ្រះថ្លាក្នុងពុទ្ធសាសនា និងការកសាងវប្បធម៌

ជាតិ ដូចជាការបង្កើតឲ្យមានសាលាជាន់ខ្ពស់សំរាប់បង្រៀនកូនចៅខ្មែរ និង បង្កើតវង់ល្ខោនសម្រាប់សម្ដែងសិល្បៈខ្មែរជាដើម ។

ស្លាព្រះហស្ដ គង់នៅនេះ យើងស្រង់ចេញពីសិលាចារឹកប្រាសាទតាមានអាកាស (1) ៖

" . . . ដោយមានភក្ដីចំពោះព្រះស្វាមីលុះត្រានិព្វាន, ព្រះនាងទ្រង់ទទួលវង់ចាំឲ្យឃើញថា ព្រះរាជាទ្រង់ថ្វាយព្រះអង្គសិបកង់ពុទ្ធចាក់ទសិន ទើបព្រះនាងចូលកាន់និព្វានជាក្រោយ . . . ។

ប្រយោគខ្លីនេះ ព្រះនាងឥន្ទ្រទេវី ទ្រង់ចារឹកទុកអំពីទឹកព្រះទ័យនៃព្រះនាងជយរាជទេវី ជាព្រះកនិដ្ឋា និង ជាមហេសីដើមនៃស្វាមីព្រះនាង កាលមុននឹងចូលទិវង្គត ។

សរុបសេចក្ដីទៅ សិលាចារឹកទាំងនោះឯង បង្ហាញយើងឲ្យឃើញនូវអារ្យធម៌ខ្មែរបុរាណ ជាពិសេសគឺអក្សរសាស្ត្ររបស់យើងកាលពីសម័យអង្គរ ។ សេចក្ដីបកស្រាយ

និង កិច្ចការស្រាវជ្រាវទាំងប៉ុន្មានខាងលើនេះសុទ្ធសឹងតែហូរ
ចេញមកពីស៊ីវិល័យសំស្រ្កឹត ព្រោះដូចយើងពោលមកខាង
ដើមរួចហើយថា សម័យនោះសំស្រ្កឹតជាយានភាសារបស់
ជនជាតិអាស៊ី ដែលទុកកេរ្តិ៍ដំណែលមកបានជាយូរអង្វែង ។
លុះចំណេរតមកមានភាសាបាលីបានមកផ្សាំវេនម្តងក៏បង្កើត
មូលដ្ឋានអក្សរសាស្រ្ត បន្ថែមលើមូលដ្ឋានសំស្រ្កឹត ពីបុរ
បុរាណមកទៀត ។ សង្ខេបសេចក្តីទៅ យើងស្គាល់បានថា
ភាសាសំស្រ្កឹត និង ភាសាបាលី ជាមូលដ្ឋាននៃអំបូរភាសា
របស់ជនជាតិអាស៊ី ដូចគ្នានឹងភាសាឡាតាំង និងក្រេក ដែល
ជាមូលដ្ឋាននៃភាសាអឺរ៉ុបដែរ ។





## ជំពូកទីប្រាំបី

# អក្សរសាស្ត្រសម័យកណ្ដាល

សម័យកណ្ដាល ជាសម័យមួយយ៉ាងវែងឆ្ងាយក្នុងប្រវត្តិអក្សរសាស្ត្រយើង ។ សតវត្សទី ១៤ បានកន្លងផុតទៅ, ប្រទេសជិតខាងយើង បេះតែមានកើតហេតុរុករានព្រំដែនទៅផ្នែកខាងលិច នាំឲ្យព្រះមហាក្សត្រខ្មែរ ទ្រង់ព្រះតំរិះលើករាជធានីពីក្រុងអង្គរ មកតាំងនៅចំទន្លេចតុមុខវិញ ។ ថ្ងៃមួយជាពេលនក្ខត្តឫក្សជោគជ័យនៅក្នុង គ.ស. ១៤៥២ ព្រះបាទស្រីសុរិយោពណ៌ចៅពញាយ៉ាត បានយាងមួយអន្លើដោយព្រះរាជបរិពារ និងនាហ្មឺនសព្វមុខមន្ត្រីគ្រប់ក្រសួងចាកចេញ

ពីទីក្រុងអង្គរ មកតាំងរាជធានីថ្មី គឺទន្លេចតុមុខដែលជាទីក្រុងភ្នំពេញសព្វថ្ងៃនេះ (១) ។

តាំងពីនោះមក អក្សរសាស្ត្រយើងបានដកមូលដ្ឋានចេញពីក្រុងអង្គរមកតាមរាជធានីថ្មីដែរ ។ អ្នកប្រាជ្ញរាជបណ្ឌិតទាំងឡាយបានតាមដង្ហែព្រះរាជា មកបង្កើតជាមជ្ឈមណ្ឌលនៅទីក្រុងថ្មី ដើម្បីផ្សាយនូវឥទ្ធិពលអក្សរសាស្ត្រតទៅទៀត ។ វេលានេះយើងអាចរកឃើញឈ្មោះនិងស្នាដៃខាងអក្សរសាស្ត្រជាច្រើន ដែលនៅសល់គង់ដល់យើងរហូតសព្វថ្ងៃ ។ ប៉ុន្តែសម័យនេះ អំបូរភាសាខ្មែរបានមកជួបប្រទះនឹងមូលដ្ឋានថ្មីមួយទៀត គឺភាសាបាលី ឬ មគធភាសាដែលចូលមកបោះគោលនៅក្នុងប្រទេសយើង តាមរយៈលទ្ធិពុទ្ធសាសនាហីនយាន ព្រោះខ្មែរគ្រប់គ្នាឆាកបែរចោលបែបមហាយាន និងព្រហ្មញ្ញសាសនាអស់ហើយ នៅសល់ខ្លះ

១– តាម Histoire du Cambodge, A. Leclère ថាក្រុងនោះនៅស្រីសឈរ (ស្រីសន្ធរ) ។

ែកជាចំនៀមទំលាប់ប៉ុណ្ណោះ មិនមែនជាលក្ខណ៍គោល
ាន់សំរាប់គោរពបូជាទូទៅទេ ។ អានុភាពភាសា
លីក្នុងវេលានេះ ក៏ពូកែមោះមុតដូចអានុភាពភាសាសំស្ក្រឹត
បម័យមុនដែរ ។ ហេតុនេះឯងបានជាយើងឃើញគម្ពីរ
ាស្ត្រាផ្សេង ៗ ដែលសរសេរជាភាសាបាលីសុទ្ធនៅគង់ទ្រង់
ូកសព្វថ្ងៃនេះយ៉ាងច្រើនក្រៃលែង ។ មិនតែប៉ុណ្ណោះ គឺ
រជាច្រើន បានកាឡៃភាសាបាលីធ្វើជាពាក្យកាព្យដូចជា
សាខ្មែរដែរ បង្ហាញនូវការប៉ិនប្រសប់ខាងរចនាពាក្យពេចន៍
លី ឲ្យបានជួនរណ្តំគ្នាតាមបង្អាក់កាព្យ ដែលយើងធ្លាប់
ទះឃើញនៅបទដើមនៃសាស្ត្រារឿងផ្សេង ៗ ។ កសនា
ក្យសាស្ត្រាយើងសម័យដ៏វែងឆ្ងាយនេះ គួរណាស់តែបាន
ារឿងបំផុតហើយ ព្រោះមានមជ្ឈដ្ឋាននូវការទទួលជួយ
បត្ថម្ភគ្រប់វិធី រហូតដល់ព្រះមហាក្សត្រក៏ព្រះអង្គតែងយកព្រះ
យទុកដាក់លើវិជ្ជាដំពូកនេះខ្លាំងណាស់ដែរ ។ ដ្បិតវិជ្ជានេះ
ាសិល្បៈមួយយ៉ាងខ្ពង់ខ្ពស់, ប៉ុន្តែបែរជាពុំសូវមានជំហររឹង

ប៉ុនប៉ុន្មាន ព្រោះចាប់តាំងពីសតវត្សទី-១៥ មក ប្រទេសយើ
មានកើតចំបាំងរាំងដល់ជាច្រើន ជួនច្បាំងជាមួយបរទេស
ជួនកាលទៀត ដោយមានវិប្បរិតបះបោរក្នុងស្រុកជាញឹ
ញាប់ណាស់ ។ តោះបើយ៉ាងនេះក៏ដោយ យើងនៅតែ
រកឃើញស្នាដៃជាមតិកដ៏វិសេសជាច្រើនឈ្មោះ បានសរសេ
ទុកបង្ហាញឲ្យឃើញកំពស់វប្បធម៌ខ្មែរសម័យនោះ
មានអ្នកនិពន្ធជាច្រើននាក់ ដែលមានឋានៈគ្រប់ជាន់គ្រប់ថ្នា
បានប្រឹងប្រែង រៀបរៀងជារឿងរ៉ាវទុក សំរាប់ជាហិតប្រ
យោជន៍ដល់ជនានុជនរួមជាតិ មានតាំងព្រះសង្ឃខ្លះ គ្រហស្
ខ្លះ ជាអ្នកធំខ្លះ ជាជនសាមញ្ញខ្លះ ដែលយើងនឹងឃើញ
ឈ្មោះលោកនៅក្នុងបញ្ជីខាងក្រោមនេះ ។ ជាពិសេសបំផុ
យើងសង្កេតឃើញព្រះមហាក្សត្រខ្មែរជាច្រើនអង្គ, ព្រះអង្គ
ក៏ជាមហាបណ្ឌិតខាងអក្សរសាស្ត្រដែរ ដូចជាព្រះបាទស្រី
ធម្មរាជាព្រះរាជសំភារ, ព្រះបាទជ័យជេដ្ឋា, ព្រះបាទសម្ដេ
ព្រះហរិរក្សរាមាធិបតីព្រះអង្គឌួង ជាដើម ។

ជាបន្ទាប់ទៅនេះ យើងសូមធ្វើជាបញ្ជីមួយយកឈ្មោះ
ងជាស្នាដៃ, ឈ្មោះអ្នកនិពន្ធ និង កាលបរិច្ឆេទ ដែលរៀប
ងរឿងនោះ ៖

ក- ប្រភេទពាក្យកាព្យ

១- សិលាចារឹកអង្គរវត្ត រៀបរៀងដោយបណ្ឌិត
ប-ខន្ទ (ភាគខាងចុង) ពីសតវត្សទី ១៦ ។

២- ល្បើកអង្គរ ជាស្នាដៃរបស់អ្នកនិពន្ធនាមអ្នកប៉ាង
បរៀងពីឆ្នាំ ១៥៩៨ ។

៣_ សរសើរហោមន្ត, កាព្យនិរាស, ច្បាប់ព្រះរាជ-
ភារ ជាស្នាព្រះហស្តព្រះបាទស្រីធម្មរាជាព្រះរាជសម្ភារ
ន់និពន្ធ ពី គ.ស. ១៦៣៤ ។

៤_ រឿងខ្យងស័ង្ខ អ្នកនិពន្ធមិនស្គាល់ឈ្មោះ រៀបរៀង
ចុង សតវត្សទី ១៧ ។

៦- រឿងក្រុងសុភមិត្រ ជាស្នាដៃ ទេកញ៉ាកោសាធិបតី
នៅ ពីគ.ស. ១៧៩៨ ។

៧_ ច្បាប់សុភាសិត ជាស្នាដៃ ទេកញ៉ាព្រះឃ្លាំងនង
ពីគ.ស ១៧៩០ ។

៨_ លោកនេយ្យជាតក ព្រះឃ្លាំងនង ពីគ.ស.១៧៩

៩_ រឿងបុញ្ញសារសិរសា " " ១៧៩

១០_ " រឿងភោគ្គកុលកុមារ " " " ១៨០

១១_ " រឿងវិរនេត្រវិរគុជ " " " ១៨០

១២_ " រឿងព្រះសមុទ្ទ " " " ១៨០

១៣ - " រឿងនាងកាកី " ជាស្នាព្រះហស្ត ព្រះបា
អង្គឌួង ទ្រង់និពន្ធ ពីគ.ស. ១៨១៣ ។

១៤_ រឿងចម្ប៉ាថោង (មិនទាន់ជាក់) រៀបរៀ
ពីគ.ស. ១៨១៦ ។

១៥_ រឿងរបាក្សត្រ ស្នាដៃរបស់ព្រះបទុមបារមីពេជ្រ

គ.ស. ១៨១៨ ។

១៦_ ល្បើកជេតពន ស្នាដៃ ឧកញ៉ាសោមសុខ

គ.ស. ១៨១៥ ។

១៧_ រឿងមុជលិន ជាស្នាដៃ បណ្ឌិតសំអាត

គ.ស. ១៨៣៣ ។

១៨. រឿងដាវរឿង ស្នាដៃ ឧកញ៉ាបក្រី-កែវ

គ.ស. ១៧៤១ ។

១៩_ រឿងព្រះជិនវង្ស ស្នាដៃ អារិយគាមុនី-កឹង

គ.ស. ១៨៥៦ ។

២០_ រឿងពេជតា ស្នាដៃរបស់ ធម្មបញ្ញា-ម៉ែន

ខ្ទួ ពី គ.ស. ១៨៥៧ ។

២១_ រឿងវិមានចន្ទ ស្នាដៃ ឧកញ៉ាធិបតី-យ៉ែម

គ.ស. ១៨៥៨ ។

២២_ ល្បើកស្រីវិជ័យ ស្នាដៃ ពញាវិជិត្រ - ប្រ

ពី គ.ស. ១៨៥៨ ។

២៣_ រឿងទេវ័ន្ទ, ល្បើកបបក ស្នាដៃ ចុះកញ៉ាសន្ធរ-មុ

ពី គ.ស. ១៨៥៩ ។

២៤_ រឿងទុំទាវ (ដំបូងជាស្នាដៃសន្ធរម៉ុក) ក្រោយម

រៀបរៀងជាថ្មីដោយព្រះបទុមថេរសោម ពីគ.ស.១៩១

១- ប្រភេទពាក្យរាយ

១_ សិលាចារឹកអង្គរវត្ត (ភាគខាងដើមមិនឃើញឈ្មោ

ពីសតវត្សទី ១៦ ។

២_ ព្រះរាជក្រឹត្យក្រមផ្សេងៗ សារសេរក្នុងរាជព្រះបា

ជ័យជេដ្ឋាទី ២ ពីសតវត្សទី ១៦ ។

៣_ មហាវេស្សន្តរជាតក (ព្រះបាទអង្គឌួង មិនទាន់ជាក

កែសម្រួលបោះពុម្ពដោយលោក ញ៉ុក. ថែម ។

ក្រៅពីនេះយើងគេឃើញរឿងជាច្រើនទៀត ដែលមិន ឃើញមានចារឹកនាមអ្នកនិពន្ធ និងពេលវេលាដែលសរសេរ រឿងនោះ តែយើងអាចសន្និដ្ឋានបានថា រឿងទាំងនេះក៏កើត ក្នុងសម័យជាមួយគ្នានេះដែរ ព្រោះមានលំនាំពាក្យ ពចន៍និងរបៀបតែងកាព្យឃ្លោងស្រដៀងគ្នា និងស្នាដៃទាំង ឡាយដែលយើងរាប់រៀបខាងលើ ៗ រីឯផ្ទៃរឿងសោត ក៏ប្រ- ហលគ្នាណាស់ដែរ ដូចជារឿងលិនថោង, សុវណ្ណវង្ស, សុវណ្ណផលា, រឿងកិនវង្ស, រឿងហង្សយន្ត, រឿងសុ- ណ្ណក្តាមស, រឿងព្រះសង្ខាត, រឿងព្រះចិន្តកុមារ, រឿង ស្ដចក្នុង, រឿងព្រះបាទកងកប, ព្រះបាទវិទា, ព្រះបាទ ទ័ន, រឿងមគ្គលិផល, រឿងទំកក់ផ្កាក់, រឿងក្បួងម៉ាល័យ រឿងព្រះសុភោគជាដើម ៗ មានរឿងខ្លី ៗ ជាច្រើនទៀត ណាហៅថារឿងល្បើក ដែលមិនសូវជាពិរោះពិសាប៉ុន្មាន នដឹងជាអ្នកនិពន្ធសរសេរក្នុងការល្បងនៅឡើយ ព្រោះផ្ទៃរឿង ូ សាច់រឿងក៏មិនសូវច្បាស់ តែប្រកបដោយគោលគំនិត

ជាខ្លឹមសារច្រើនណាស់ដែរ គ្រាន់បានជាគតិសម្រាប់
ដំបូន្មានល្អ ៗ ដល់អ្នកអាន ។ រឿងទាំងនេះយើងអាចសន្និដ្ឋ
បានថា ពិតជាកើតឡើងដំណាលៗគ្នាមែន ព្រោះឈ្មោះតួ
រឿងក្តី នឹងគតិរឿង គឺឧត្តមគតិរបស់អ្នកនិពន្ធក្តី សុទ្ធសឹង
ប្រហាក់ប្រហែលគ្នាមិនឆ្ងាយពីគ្នាឡើយ ។ ហើយរឿងទាំ
នោះ ច្រើនតែមានយក្សកំណាចដ៏សាហាវៗតាមផ្ទាមនុស្ស
ឯមនុស្សច្រើនជាអ្នកយុត្តិធម៌ តែងរងនូវអំពើឃោរឃៅរប
ពពួកទុច្ចរិតជាដរាប ។ ប៉ុន្តែកម្មផលរបស់មនុស្សទុច្ចរិតទាំ
នោះមិនបានយូរឡើយ ព្រោះទ្រឹស្តីនៃព្រះពុទ្ធសាសនា តែ
តែដាក់កំហុសទៅលើមនុស្សអធម៌ សមនឹងច្បាប់ធម្មជាតិដែ
តម្រូវឲ្យមនុស្សប្រព្រឹត្តផ្លូវល្អ ត្រូវចេះយោគយល់ដល់គ្នានិង
ដើម្បីរក្សាសេចក្តីសុខនៅក្នុងជីវភាពរបស់ខ្លួន ៗ ចំពោះរបៀ
សរសេរ ឃើញថាមិនទាន់បានសមរម្យតាមទំនងរឿងក៏វ
ឡើយទេ ព្រោះសម្បូណ៌ដោយពាក្យស្ទួនៗគ្នា ទទ្រឹងច្រំដែ
បន្ទាយនាំឲ្យវែងឥតប្រយោជន៍ ឯសំដីឆ្លើយឆ្លងគ្នារបស់តួរឿ

ទីន សំដីរបស់អ្នកនិពន្ធ ច្រើននៅប្របូកប្របល់គ្នានាំឲ្យពិបាកយល់ ៗ

ចំណែកពាក្យសំដីសោត ច្រើនតែមានពាក្យពិបាក ៗ ដូចជាពាក្យបាលី-សំស្រ្កឹតលាយចំរុះគ្នាជាដើម បណ្តាលឲ្យជនសាមញ្ញ ឬ ជនដែលមានចំណេះតិចមិនអាចឈោងចាប់បាននូវសំដីទាំងនោះដោយងាយ ៗ ឡើយ ៗ មានតែអ្នកបានរៀនសូត្រខ្ពង់ខ្ពស់ ឬ អ្នកស្រឡាញ់ស្តាប់រឿងរ៉ាវញឹកញាប់ប៉ុណ្ណោះ ទើបងាយស្តាប់ងាយយល់បាន ៗ ក្រៅពីនេះទៀត អ្នកនិពន្ធច្រើនបណ្តែតសតិបញ្ញា ឲ្យហោះហើរទៅអាកាស ហួសពីកំរិតធម្មជាតិ ដូចជាធ្វើឲ្យមនុស្សចេះហោះហើរដើរលើអាកាស, ច្បាំងប្រយុទ្ធគ្នាដោយមន្តគាថា ថ្វែនសរបង្កើតបានជាកង់ចក្រ, ជាវត្ថុទិព្វផ្សេងៗ, ក្រុងយក្សមានមុខជប់ដៃម្តៃ ចេះបែងកាយចេះប្រោសពលដែលស្លាប់ឲ្យរស់ឡើងវិញ, ចេះជប់ឲ្យកើតកង់ទ័ពជាដើម ៗ មិនតែប៉ុណ្ណោះ អ្នកនិពន្ធច្រើនទុកតួឯកក្នុងរឿង ជាអ្នកមានភ័ព្វសំណាងបានជាក្សត្រគ្រង

កជ្យ តែមុននឹងដល់កំរិតក័ព្វាសនាយ៉ាងខ្ពស់នេះ តែងត្រូវរងអំពើលំបិនលំបាកតោកយ៉ាកយ៉ាងយូរ ដែលប្រកបដោយអាការទន់ខ្សោយក្រៃលែង គឺតួនោះឯងច្រើនគ្មានបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនឲ្យសមរម្យសោះ បែរជាត្រូវពឹងកំឡាំងអ្នកដទៃមកជួយយកអាសាទៅវិញ ដូចយ៉ាងមានព្រះឥន្ទ្រទេពតាចុះមកជួយ ឬមានមហាឫសីមកជួយសង្គ្រោះជាដើម ។

ទោះបីមានការផ្គាំផ្គងយ៉ាងនេះក៏ដោយ ស្នាដៃបុព្វបុរសយើងគង់មានគុណភាពពិសេសជាច្រើនបែបណាស់ដែរ ជាសំខាន់បំផុត ត្រង់ដែលចេះពត់ចិត្តបណ្ដាជនគ្រប់និគមជនបទ ឲ្យចេះប្រឹងក្រេបជញ្ជក់រសជាតិអក្សរសាស្ត្រឲ្យបានយូរអង្វែងរហូតដល់បច្ចុប្បន្នកាលនេះ ។ ផ្សេងទៅទៀត រឿងទាំងនោះអាចប្រៀបបាននឹងប្រទីបមួយ ដែលជួយព្រាលបំភ្លឺយើងឲ្យស្គាល់របៀបសរសេរ របៀបប្រើពាក្យ និងទំនៀមរបស់ស្រុកយើងខ្លះពីសម័យនោះ ដែលអ្នកសិក្សាទាំងឡាយ

តរការស្វែងរកស្រាវជ្រាវ ទុកជាប្រដាប់ចំរើនសតិបញ្ញា ហ្មារគឺទឹងធ្វើជាក្បួនច្បាប់សំរាប់សិក្សាថែមទៀត ។



ជាយូរមកហើយ មានខ្មែរយើង ភាគខ្លះនៅមិនព្រមទទួលជឿថា៖ រឿងក៉ាវទាំងនោះ ជារឿងប្រឌិតកើតឡើង ដោយគំនិតអ្នកនិពន្ធបុរាណសោះ ៗ គេនៅតែនាំគ្នាជឿថា រឿងទាំងនេះពិតជារឿងជាតក ដែលព្រះពុទ្ធអង្គ បានត្រេចរង្គាត់ក្នុងកាលវដ្តសង្សារ ហើយបានទៅយោនយកកំណើតកើតជាតួរឿងទាំងនោះមែន ។ ហេតុនេះហើយទើបអ្នកស្តាប់រឿងទាំងឡាយ តែងប្រែងប្រិតប្រៀប ប្រុងស្មារតី ផ្ទៀងស្តាប់

នូវរឿងទាំងនោះ មិនឲ្យតក់មួយម៉ាត់ណាឡើយ ព្រមទាំង
ជួយសោកសង្រេង ក្នុងគ្រាណាគូនោះកំសត់គោកយ៉ាក
សប្បាយរីករាយ នៅពេលណាគូនោះបានជួបនឹងភ័ព្វស
ល្អៗ ។ ជំនឿនេះបាននៅចាក់ឫសជាប់លាប់ ក្នុងសន្តានប
បណ្ដាជនខ្មែរនៅតាមនិគមជនបទនៅឡើយ ។ ប៉ុន្តែយើ
អាចបញ្ជាក់យោបល់ទៀងទាត់ក្រៅផ្សេងពីនេះបាន ដោ
ពឹងផ្អែកលើគោលសេចក្ដី ដែលមានចារជាប់នៅខាងដើម
សាស្ត្រារឿងទាំងនោះ ទុកជាការម្ចកថារបស់អ្នកនិពន្ធដែ
ពណ៌នាហូរហែពីមូលហេតុដែលបណ្ដាលឲ្យលោករៀបរៀ
ផ្ទៃរឿងនោះឡើង ។ មិនតែប៉ុណ្ណោះ អ្នកនិពន្ធបានទាំងច
រឹកនូវនាមរបស់ខ្លួនព្រមទាំងកាលបរិច្ឆេទ ដែលតុបតែងរឿ
នោះ ទុកថែមទៀតផង ។ ជាពិសេស លោកបានធ្វើប
នមស្សការ ដល់គុណព្រះរតនត្រ័យ និង ធ្វើជាសេចក្ដីប្រា
ផ្សេង ៗ ដោយសារអានុភាពកុសលដែលកើតឡើងពីផ
កសាងរឿងរ៉ាវទាំងនេះ ។ ត្រង់នេះជាកស្តុតាងមួយបញ្ជា

ផ្ទាល់ចំពោះសំណៅរឿងទាំងនោះ ៗ យើងអាចរកឃើញសេចក្ដីពិតមួយផ្សេងពីនេះទៀត គឺត្រង់ឫសគល់នៃរឿងទាំងនេះដកស្រង់ពីគម្ពីរមួយហៅថា «បញ្ញាសជាតក» ដែលសរសេរឡើងជាភាសាបាលីសុទ្ធ ៗ បើយើងឃើញមានមូលដ្ឋានជាភាសាបាលីដូច្នេះ តើយើងអាចជឿថាពិតប្រាកដជារឿងកើតតាំងពីសម័យពុទ្ធកាលដូចគម្ពីរផ្សេង ៗ ដែរឬអ្វី? យើងត្រូវឆ្លើយថា យើងមិនទាន់ជឿស្លុងភ្លាមទេ ព្រោះការអ្វីផងទាំងពួង មុននឹងជឿត្រូវតែពិចារណាឲ្យហ្មត់ចត់សិន ៗ ដូច្នេះ យើងត្រូវធ្វើការសង្កេតនឹងស្រាវជ្រាវរកហេតុផលបន្តិចសិន ៗ គម្ពីរ «បញ្ញាសជាតក» ប្រែថា «ហាសិបរឿង» បានសេចក្ដីថានៅក្នុងគម្ពីរនេះ មានរឿងនិទានចំនួនហាសិប ៗ យើងអាចពិនិត្យតទៅទៀត ឃើញថាគម្ពីរនេះជាស្នាដៃរបស់អ្នកប្រាជ្ញនៅក្រោយសុវណ្ណភូមិជាពិតប្រាកដ ព្រោះគេឃើញមាននៅតែក្នុងប្រទេសខ្មែរ, ថៃយ៍, លាវ នឹង ប្រទេសភូមាប៉ុណ្ណោះ ចំណែកកោះលង្កាដែលជាមូលដ្ឋានពុទ្ធសាសនា

ធំបំផុត គេពុំដែលប្រទះឃើញគម្ពីរនេះទេ ។ ហេតុនេះឯ
នាំឲ្យអ្នកស្រាវជ្រាវគ្រប់សញ្ជាតិ នាំគ្នាសន្និដ្ឋានថាគម្ពីរនេះពិ
ជាកើតឡើងដោយគំនិតអ្នកប្រាជ្ញខ្មែរ, លាវ និង មន[១] មែ
គ្រាន់តែផ្តកទៅតាមទ្រឹស្តីពុទ្ធនិយមប៉ុណ្ណោះ ។ គេអាចស្មា
បានយ៉ាងជាក់ទៀតថា អ្នកប្រាជ្ញទាំងនេះតុបតែងឡើងនេ
ក្រោយសម័យពុទ្ធកាលជាយូរអង្វែង ដើម្បីជាគ្រឿងណែន
សតិអារម្មណ៍ របស់ជនានុជនឲ្យនាំគ្នាគេចទៅតាមផ្លូវល្អ
សមាទិដ្ឋិ នៃគន្លងពុទ្ធោវាទ ។

កស្តុតាងដែលយើងលើកយកមកលាតត្រដាងខាងលើនេ
សមល្មមឲ្យយើងជឿជាក់ច្បាស់ក្នុងចិត្ត លែងមានការយល់ច្រ
ឡំថា រឿងនេះជារឿងព្រះ, កើតឡើងតាំងពីសម័យពុទ្ធកាល
ដូចមុនទៀតហើយ ។ ព្រោះគេតែងជួបប្រទះគម្ពីរដីកាច្រើន
ណាស់ដែរ ដែលអ្នកប្រាជ្ញពុទ្ធសាសនាបានរៀបរៀងបង្កើ
ឡើងនៅស្រុកអាយយើងនេះដូចជាគម្ពីរមង្គលត្ថទីបនីជាដើម

១– សូមមើលយោបល់ដើមនៃសៀវភៅ "បញ្ញាសជាតកសំរាយ" ភាគ
ផ្សាយពីពុទ្ធសាសនបណ្ឌិត្យ ។

បន្តទៅទៀតនេះ យើងសូមលើកយកស្នាដៃនិងជីវប្រវត្តិរបស់អ្នកនិពន្ធ សម័យកណ្ដាលមករៀបដំរៀងគ្នាតាមលំដាប់សករាជ សំរាប់ជាការសិក្សាយ៉ាងជាក់ច្បាស់ខាងអក្សរសាស្ត្រជាតិយើង ។ ប៉ុន្តែការរៀបរៀងនេះ យើងលើកយកតែស្នាដៃណាល្អសមរម្យ និង មានចារឹកនាមអ្នកនិពន្ធជាក់ប្រាកដប៉ុណ្ណោះមកអធិប្បាយ ។ ចំណែកស្នាដៃណាមិនមានចារឹកនាមជាក់ប្រាកដទេ យើងសូមលើកទុកមួយកន្លែងសិន ព្រោះការជាក់ប្រាកដមិនទាន់ហុចឲ្យយើងនៅឡើយ ។ ហើយយើងសង្ឃឹមថា ការស្រាវជ្រាវជាបន្ត ១ ទៅមុខទៀតនឹងជាបញ្ជាក់ឲ្យយើងជាមិនខាន ។ ជាដំបូង យើងសូមលើកយកស្នាដៃណា ដែលមានអាយុចាស់ជាងគេមកពណ៌នាមុន ដូចមានជាលំដាប់ហូរហែតទៅ ៖

## បណ្ឌិត ជ័យ _ នន្ទ

បណ្ឌិត ជ័យ - នន្ទ ជានាម៉ឺនមួយរូបក្នុងរជ្ជកាលព្រះបាទធម្មរាជា ។ ថ្ងៃមួយលោក បាននាំគ្នីគ្នាជាច្រើនទៅធ្វើបុណ្យ

អ៊ីតចិតនៅឯអង្គរវត្ត ទើបលោករៀបចំធ្វើសិលាចារឹកជាច្រើន
ផ្ទាំង ដែលនិយាយសុទ្ធតែពីពាក្យស្មូត និងបួងសួងប្រាថ្ន
ឲ្យសំរេចដូចបំណងទៅជាគិមុខ ៗ យើងលើកយកស្នាដៃ
របស់លោកបន្តិចមកបញ្ជាក់ជាភស្តុតាងដូចខាងក្រោម ៖

" . . . ខ្ញុំសូមនោះរៀងមក ជាពន្លកសាពេជ្ជថ្ងៃ អង្គខ្ញុំនោះ
" ឯងនៃ ដោយនាមហៅ ជ័យ-ទន្ទ ៗ រីនាងជាកន្សែ
" ឈ្មោះពីនៃនាង ប៉ែន-សន រូបនោមទន់អែនអន យល់សក្តិ
" សមចរិតស្រី ៗ លុះព្រះបាទពាជា ឲ្យសក្តាទីទេខ្ញុំ ជ័យ-ទន្ទ
" សេនាបតី ហើយឲ្យធីព្រក្តី ហានៗដល់ទៅធីត្បូងឃុំ នាម៉ឺន
" ធំឯកឯងហាន លុះជាយមកជផង នេះឯងហានសាង
" ត្រីសួល ៗ ឯមីង ប៉ែន-សនណា យសសក្តាដោយសមគួ
" ឈ្មោះនោះយល់បរិបូណ៌ ជាជំទាវទេពសុពណ៌ (១) . . . "

សេចក្តីដកស្រង់ខាងលើនេះ បណ្ឌិត ជ័យ-ទន្ទ បានពយ
ការណ៍ប្រាប់យើងអំពីប្រវត្តិ និង លំដាប់សក្តិរបស់លោក តី

១– អត្ថបទស្រង់ពីសៀវភៅសិលាចារឹកអង្គរវត្ត ដែលពុទ្ធសាសនបណ្ឌិត
បោះពុម្ពផ្សាយ ។

ាកមានភរិយាឈ្មោះនាងប៉ែន-សន ដែលប្រកបដោយរូប
មប្រិមប្រិយ៍ ។ គ្រានោះលោកមានងារជាសេនាបតី រួច
យលោកបានទៅស្តីទីនៅខេត្តត្បូងឃ្មុំ ជាប់ផុតបានទទួល
ន:ជាឧកញ៉ាយមរាជ ។ ចំណែកភរិយាលោកក៏បានឡើង
សជាជំទាវដោយមាននាមសន្មតថាជំទាវសុពណ៌ ។

## ព្រះបាទស្រីធម្មរាជា

ព្រះបាទស្រីធម្មរាជាឬព្រះរាជសម្ភារ មានព្រះនាមដើម
ចៅពញាគូ" ជារាជបុត្រនៃព្រះបាទជ័យជេដ្ឋាទី-២ ។
លនៅប្រជន្ម ១៦ វស្សា ព្រះអង្គទ្រង់សាងព្រះផ្នួសជា
ាម· វង្គតទៅ ព្រះអង្គបាន
លនៅពីកុមារ ព្រះ
ាបានប្រុងប្រៀបច្បង ងម ព្រ...... ៥៨ ះអង្គរួមព្រះបិតា
តាទីទៃព្រះនាម បុប្ផាវតី ។ ប៉ុន្តែដោយទ្រង់សាងផ្នួសយូរ

ពេក ព្រះក្សត្រីអង្គនេះក៏បានជាអគ្គមហេសីព្រះឧទ័យទៅ
លុះដល់ គ.ស. ១៦២៩ ព្រះអង្គបានលាចាកសិក្ខាប
គ្រប់គ្រងរាជសម្បត្តិ នៅព្រះរាជវាំងកោះឃ្លោក(១) ។ ព្រះ
មិនទាន់ផុតព្រះទ័យ នឹងព្រះនាងបុប្ផាវតីនៅឡើយទេ
គេឃើញមានស្នាព្រះហស្ថ ដែលព្រះអង្គទ្រង់លិខិតជា
អក្ខរា ផ្ញើឆ្លងឆ្លើយជាមួយព្រះក្សត្រីនៅគង់ទ្រង់ហួត
សព្វថ្ងៃនេះ(២) ។ ព្រះអង្គជាយុវក្សត្រមួយ ប្រកបដោយ
ប្រាជ្ញារាងវៃ តែងសព្វព្រះរាជហឫទ័យនឹងអក្សរសាស្ត្រ
ណាស់ ព្រោះព្រះអង្គបានសិក្សា វិជ្ជាភាសាបាលីចេះមុ
នឹងបានទុកស្នាព្រះហស្ថឲ្យយើងជាច្រើន សុទ្ធសឹងប្រ
ដោយពាក្យកាព្យឃ្លោងផ្អែមល្ហែម នឹងជូនរណ្ដំគួរចាប់ចិត្ត

យើងស្រង់អត្ថបទខាងក្រោមនេះ ពីក្នុងសា
«សរសើរហេមន្តមាស» មកធ្វើជាគ្រឿងពិនិត្យសង្កេ
ស្នាព្រះហស្ថព្រះអង្គដូចតទៅ ៖

---

១– គឺកោះឃ្លាប់កណ្ដាលសព្វថ្ងៃ ។ ២– សូមមើលក្នុងសៀវភៅពង្សាវតា
ទេសកម្ពុជា សរសេរដៃ ដែលមានដម្កល់នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិ

« ... ដំណាលដំណើរនា សរសើរគ្រាហេមន្តមាស ត្រសៀកឯអាកាស សែនសាយណ្ហាទេរទៅ ៗ ស្រណោះ បក្សាករ ឯអម្ពរឆ្មៀលឆ្ងាត់ទៅ ស់កុកសំកាំងទៅ សង់សូរ សាំនសត្វយាសយំ ៗ ខ្លះហើរប្រគៀងគូ ទំទៀងទៅ ទ្រង់ព្រាយសម ខ្លះសសិតស្លាបទំ ខ្លះហើរហួសផ្ទេកទៅ ពៅ ៗ ខ្លះរេរកចំណី ដោយនទីគង្គាជ្រៅ ខ្លះចៀងទាប សំដៅ ចុះចាប់ចឹកសង្វាស៊ី ៗ គន់គួរស្រណោះសពរ់ ស្រណោះគលផ្សាបក្សី សង់សូរសត្វសំដី រៀយ ៗ រែង កាសាសត្វ ៗ ...

កំណាព្យខាងលើនេះ ព្រះពជសំការទ្រង់និពន្ធសរសើរ សភាព ទឹងធម្មជាតិទាំងឡាយ ក្នុងហេមន្តរដូវ ឬក្នុងខែ ដលធ្លាក់សន្សើម ៗ ព្រះអង្គទ្រង់បានចុចយកពេលល្ងាច ជាក់ គ្រាដែលព្រះសុរិយាជ្រេទេរទៅខាងលិច គ្រានោះ នបក្សាបក្សីជាច្រើន ស្រែកហើកញ្ច្រៀវទ្រហឹងអឹងកង ល្បយឆ្លងគ្នា ៗ ខ្លះហើរឯកណ្ដាលអាកាសវេហាស៍, ខ្លះទំនៅ

លើមែកព្រឹក្សា សំកាំងស្វាប ឬ សសិតស្វាប ទីងខ្លះទៀ
ទំគៀកគូឈ្មោលញីយ៉ាងសប្បាយរីករាយ ៗ មានបក្ស
ខ្លះហើរត្រសងតាមមាត់ទឹកស្វែងចាប់មច្ឆាធ្វើជាចំណី ហើយ
ស្រែកច្រូងឆ្លើយពីទីមួយទៅទីមួយ ឮគ្រលួចគួរស្រណោះ
លែង ៗ ស្នាព្រះហស្តនេះ ព្រះរាជសម្ភារបានបង្ហា
នូវសម្រស់កាព្យល្អបំព្រង ទីងពាក្យសំដីទន់ភ្លន់គួរចាប់ចិ
មិនខុសគ្នាពីរឿងដទៃទៀត ដែលជាស្នាព្រះហស្តរបស់ព្រះអ
ដែរនោះទេ សម្ដែងឲ្យយើងឃើញថា ព្រះយុវក្សត្រអ
នេះ អាចរាប់បានជាបណ្ឌិតឯក ខាងអក្សរសាស្ត្រយើងក្នុ
សតវត្សទី-១៧ ។ ចំណែកខាងស្នាព្រះហស្តខាងក្បួនច្បា
ប្រដៅវិញ ក៏គួរឲ្យសរសើរណាស់ដែរ ព្រោះឃ្លាតពាក្យមួយ
ម៉ាត់ ៗ សុទ្ធតែមានន័យខ្លីខ្លឹមខ្លាយ អាចលើកយកជ
គតិយ៉ាងល្អ ៗ ផង ។ មិនតែប៉ុណ្ណោះ មានពាក្យក្នុងនោ
ជាច្រើន បានក្លាយទៅជាពាក្យសុភាសិតរបស់យើង សព្វ
ប្រើតមាត់តាំងក្មេងចាស់ទៅហើយ ។ លោកមកនឹងបា

បញ្ចេញពាក្យទាំងនោះ នៅក្នុងអត្ថបទយ៉ាងខ្លីខាងក្រោមនេះ លយើងស្រង់ចេញពីសាស្ត្រាច្បាប់ព្រះរាជសម្ភារ ដូច ទៅ៖

“...ផ្អែមពីរប្រការ ចំណេរទៅដាល កុំអាលឲ្យធំ ផ្អែមមួយពាក្យពាល រែងពលរេគ្គី ផ្អែមមួយពាក្យស្រី ស្រដីមាយា ៗ ពាក្យត្រូវរែងរឹង ស្រាវែងស្រវឹង ពុំផលពិសា ពាក្យពិតរែងស្វែង ពុំពិរោះថា បណ្តាំមេបា រែងថាពុំគាប់ ៗ ខ្ញាំរែងស្អប់ចេះ ខ្សត់ឥតចំណេះ ស្អប់អ្នកមានទ្រព្យ ស្រីស្រាលប្រេចណ្ហ រែងស្អប់ខ្ញុំគាប់ ពាលពិតឥតច្បាប់ រែងស្អប់ប្រដៅ ៗ ចង់បុណ្យបានបាប ប-ចើងចង់លាភ រែងបាត់ធនទៅ មានះបាត់មិត្ត ឥតអ្នកជាផៅ គ្រាំគ្រាធរយាររយៅ រមែងបាត់អគ្គ ៗ ស្វែងគាប់បានយស ចង់ស្វែងរបស់ ប្រើចេះផ្គត់ផ្គង់ ចង់ធំកុំអួត ដើមមានពូជពង្ស ចង់បានខ្លួនត្រង់ ប្រើផ្គាប់អ្នកមុខ ៗ ខ្លួនហើរត្បូតខ្យល់ នាយថ្កើងជ្រៀតពល រក្សាឲ្យសុខ

« ទ្រព្យគង់ផ្សិតស្រី បេះសំបៃទុក ផ្ទះធំស្រណុក ផ្សិ

« ការិយាជា ។ ...

អត្ថបទខាងលើនេះ ជាពាក្យប្រៀនប្រដៅគ្រប់ៗ ចំពោ

ផងទូទៅ ទាំងខាងផ្លូវចរិយា ទាំងខាងអាជីវកម្ម ដែលត្រូ

ប្រកបការចិញ្ចឹមជីវិត ។

## ឧកញ៉ាកោសាធិបតី-កៅ

ឧកញ៉ាកោសាធិបតី កៅ ជាកវីឯកក្នុងរជ្ជកាលព្រះបា

អង្គច័ន្ទ ។ លោកបានរៀនសូត្របេះស្ទាត់វិជ្ជាអក្សរខ្មែរ និ

ភាសាបាលី ជាពិសេស លោកបានចេះចាំខាងច្បាប់ជាកា

គ្រប់សព្វល្អមប្រើការបានទៀត ។ ហេតុនេះហើយ ទើ

ព្រះនរបតី ទ្រង់ប្រោសប្រទាន ឲ្យធ្វើជាចៅហ្វាយឃ្លាំងមណី

រតន៍ក្នុងព្រះបរមរាជវាំង នឹងបានជាទីប្រឹក្សារបស់ព្រះអង្គខា

ច្បាប់ទៀតផង ។ ស្នាដៃរបស់លោក មានតែមួយប៉ុណ្ណោ

គឺរឿង « ក្រុងសុភមិត្រ » ។ ក្នុងអារម្ភកថានៃរឿងនេ

ាកគ្គកទិពន្ធបានប្រាប់យើងថា លោកបានដកស្រង់ចេញ
ពីរឿងក្នុងបញ្ញាសជាតក ត្រង់ជាតកទី ៩ ដែលមានជា
សាបាលី ៗ លោកបានសរសេរបញ្ចូលនូវពាក្យពេចន៍
ជាច្រើន ដើម្បីបានជាសម្រស់នៃរឿង ដែលមានបន្ថែម
កែងជាពាក្យកាព្យឃ្លោងយ៉ាងល្អងល្អាយ ដែលយើងអាច
ន្ធេបបាននូវផ្លែរឿងនោះដូចតទៅ ៖



ព្រះកជាមួយអង្គព្រះនាម
ក្រុងសុភមិត្រ មានអគ្គម-
ហេសី ព្រះនាមនាង កេសនី
ព្រមទាំងបុត្រពីរអង្គ គ្រង
រាជ្យនៅនគរពារាណសី ៗ
ថ្ងៃមួយព្រះអនុជព្រះអង្គ ព្រះ
នាមអសុភមិត្រ បានប៉ងប្រា
ថ្នានឹងធ្វើឃាតព្រះអង្គដើម្បី
ដណ្តើមយករាជសម្បត្តិ ៗ

លុះទ្រង់ជ្រាបហេតុនេះភ្លាម ព្រះបាទក្រុងសុគមិត្រក៏នាំមហេ
សីនឹងបុត្រទាំងគូភៀសព្រះអង្គចេញពីព្រះនិវេសន៍ ជៀ
ពង់កុំឲ្យមានកើតចលាចលក្នុងប្រទេស ។ ទ្រង់យាងក
ព្រៃភ្នំក្រំថ្ម សោយតែផ្លែឈើដែលមានដុះនៅតាមដងព្រៃ
ថ្ងៃមួយបានទៅដល់មាត់ស្ទឹងធំមួយ ព្រះអង្គទ្រង់ទុកបុត្រទាំ
ពីរនៅត្រើយខាងអាយ ហើយពរមហេសីហែលឆ្លងទៅក
ត្រើយនាយ ។ ជួនពេលនោះមានព្រានប្រមង់ប្ដី-ប្រពន្ធ
ទូកមកឃើញកូនក្មេងទាំងពីរនៅត្រមែងត្រមោចដូចនោះ
លើកដាក់លើទូកនាំយកទៅ ។ ឯព្រះរាជាកាលដែលហែ
បានដល់ត្រើយម្ខាងហើយ ក៏ដាក់មហេសីនៅក្រោមដើ
ឈើមួយ ផ្ដាំឲ្យនាងនៅចាំ ហើយហែលត្រឡប់មកយ
បុត្រាទាំងគូវិញ ។ គ្រាដែលហែលឆ្លងផុតមក មានសំពៅ
ជំនួញមួយបើកក្ដោងមកដល់ ឃើញនាងមហេសីនៅតែមួ
អង្គឯង គេក៏នាំគ្នាចាប់នាងដាក់សំពៅយកទៅ ។ ចំណែ
ក្រុងសុគមិត្រហែលឆ្លងទៅដល់ត្រើយម្ខាងហើយ រកមើ

កូនពុំឃើញក៏ដង្ហោយហៅពេញព្រៃព្រឹក្សា ៗ លុះអស់សន្ទឹម ហើយទើបហែលឆ្លងមករកមហេសីវិញ ៗ មកខាងនេះ ក៏ទ្រង់មិនបានយល់មហេសីទៀត ៗ ព្រះអង្គវិតក្កក្រៃលែង ក៏យាងតែមួយអង្គឯងកាត់ព្រៃគ្រោតព្រៃគ្រាញ់ រហូតទៅដល់ទ្វារនគរមួយឈ្មោះនគរតក្កសីលា ៗ នគរនោះឥតមានមហាក្សត្រទេ ដូច្នេះសេវកាមាត្យទាំងឡាយក៏នាំគ្នារៀបក្បួនគជេន្ទ្រផ្សងរកអ្នកមានបុណ្យមកសោយសម្បត្តិ ៗ ក្បួនគជេន្ទ្របានទៅអញ្ជើញក្រុងសុតមិត្រ សុំឲ្យព្រះអង្គឡើងគ្រប់គ្រងនគរតក្កសីលា ៗ ថ្ងៃមួយនាយព្រានប្រមង់បាននាំកុមារពីររូបទៅថ្វាយព្រះអង្គ ធ្វើជាមហាតលិកតែទ្រង់ពុំទាន់ស្គាល់ជាកូនបុត្រនៅឡើយទេ គ្រាតែដល់ពេលមួយនាយសំពៅនាំយកបណ្ណាការមកថ្វាយព្រះអង្គ ហើយព្រះអង្គទ្រង់ឃាត់ឲ្យនាយសំពៅនៅសំណេះសណ្ឋាលលេងសិន ដោយទ្រង់ចាត់ឲ្យមហាតលិកក្មេង ៗ ទាំងពីរទៅនៅចាំសំពៅជំនួស ៗ គ្រានោះចៅកំឡោះទាំងពីរបានសួរដេញដោលគ្នារកដើមដាន

ពីរឿងមាតាបិតាខ្លួន ស្រាប់តែនាងកេសនី ដែលនៅពួន ក្នុងបន្ទប់ក្បែរនោះឮសូរក៏ចេញមកឱបកូនសោយសោក នាំឲ្យពួកសំពៅផ្អើលឆោឡោចាប់អ្នកកម្លោះទាំងពីរយកទៅថ្វាយក្សត្រ សុំឲ្យព្រះអង្គវិនិច្ឆ័យទោសក្មេងនេះ ព្រោះលបចាប់នាងស្រី ៗ ព្រះរាជាទ្រង់ធម៌ ទ្រង់ត្រាស់សួរចៅមហាតលិកទាំងពីរពីដើមចបមក ទើបទ្រង់ជ្រាបថាជារាជបុត្រនឹងជាមហេ-សីរបស់ព្រះអង្គ ៗ ទ្រង់ក៏បានជួបជុំមហេសីនឹងបុត្រនៅគ្រងរាជ្យជាសុខសាន្តរហូតទៅ ៗ

នៅក្នុងវគ្គទីមួយ ៗ ឧកញ៉ាកោសាធិបតី-កៅ ប្រឹតប្រៀបពាក្យពេចន៍ឲ្យបានសមរម្យ ហើយកុំឲ្យមានពាក្យជួនឥតប្រ-យោជន៍ផង ៗ ដូចនេះហើយ ទើបស្នាដៃនេះ បានសេចក្ដីសរសើរជាច្រើន ពីសំណាក់អ្នកសិក្សាទាំងឡាយ ហើយនៅក្នុងរឿងនេះ លោកបានរៀបធ្វើក្បួនកាព្យខ្មែរបុរាណលាយចំរុះជាមួយផង សំរាប់បង្ហាញអ្នកក្រោយ ៗ ឲ្យយល់ថារបៀបប្រើកាព្យខ្មែរយើងដូចម្ដេចខ្លះ ៗ ដើម្បីជាសេចក្ដីបញ្ជាក់

យើងស្រង់យកសេចក្ដីបន្តិចក្នុងរឿងនោះ ត្រង់ដែលនាងកេសនីទួញយំរលឹកស្វាមីនិងបុត្រ ក្នុងគ្រាដែលឈ្មួញសំពៅចាប់នាងយកទៅ ។ អត្ថបទនេះមានដូចតទៅ ៖

«...កាលនោះនាងទេវី អគ្គមហេសីកដធីតា នាងគិត
«ញ័រអង្គា យល់អស់ពាណិជទាំងឡាយ ។ នាងវែងសោយ
«សោកា ខ្ញុំព្រះមហាក្សត្រពណ្ណពយ ផ្កាខ្ចាចឈើសព្វ
«សាយ វែងតានតឹងទុករគ្ឃ ។ ខ្ញុំថាឱព្រះបង ប្អូន
«មករងទុក្ខពេកក្ដាត់ ថាឱព្រះមហាក្សត្រ ស្ដេចវែងទ្រង់
«ព្រះមេត្តា ។ មិនដឹងជាប្អូនស្រី កើតទុក្ខបីដល់ម៉េះណា មក
«នៅទឹងអស់ពា-ណិជគេត្រាយកប្អូនទៅ ។ ឱម៉េះសម
«ព្រះបង វិលមកផ្គងកេប្អូនពៅ ពុំឃើញរត់រកហៅ សព្វ
«កណ្ដាលព្រៃព្រឹក្សា ។ ឱអាសូរបុត្រពៅ ម៉េះយំហៅរក
«មាតា សង្រេងឈើខ្ចាចផ្កា ក្បៀយដីរសូន្យបោះបង់ ។ ...

អត្ថបទខាងលើនេះ ឧកញ៉ាកោសាធិបតី-កៅ ធ្វើជា

បទព្រហ្មគីតិ ដើម្បីដំអូញសំដីដំណាងសេចក្ដីសោកសង្រេង របស់នាងកេសនី ។

## ឧកញ៉ាវង្សសារពេជ្ញ-នង

លោកមានងារមួយទៀតជា ឧកញ៉ាព្រះឃ្លាំង-នង គឺជាអ្នកប្រាជ្ញមួយខាងផ្នែកអក្សរសាស្ត្រយ៉ាងចំណានបំផុត ក្នុងសម័យឧត្ដុង្គ ព្រោះលោកបានរៀនសូត្រភាសាជាតិ, ភាសាសៀម និងភាសាបាលីចេះយ៉ាងស្ទាត់ជំនាញ ។ កាលរាជ្យព្រះបាទអង្គចន្ទ លោកមានងារជាឧកញ៉ាវង្សសារពេជ្ញ ដ្បិតលោកជាអ្នកចេះព្រះត្រៃបិដក និងអក្សរសាស្ត្រពិតប្រាកដ ។ ព្រះមហាក្សត្រទ្រង់ប្រោសប្រាណ តាំងធ្វើជាគ្រូលើសំណាក់ព្រះសង្ឃនិងគ្រហស្ថ ទាំងឡាយនៅក្នុងព្រះនគរ ។ លុះមកដល់រជ្ជកាលព្រះបាទសម្ដេចព្រះហរិរក្សរាមាធិបតី ព្រះអង្គឌួង លោកកវែនងបានឡើងជាទីប្រឹក្សា និងជារាជសហការី

ាល់ព្រះរាជា ហើយព្រះអង្គទ្រង់ប្រោសព្រះរាជទាន
ានន្ទសេក្ដីជាទាំងហ្វាងឃុំងព្រះរាជទ្រព្យ ទំបមានការជា
កញ្ញាព្រះយ៉ាំង ។ លោកទុកស្នាដៃឲ្យយើងជាច្រើនគឺ៖
រឿងគោតកុលកុមារ, លោកនយជាតក, ច្បាប់សុភាសិត,
រឿងបុញ្ញសារ - សិរិសារ, រឿងវរនេត្រវរនុជ និង រឿងព្រះ
បមុខ ។ ឥឡូវយើងលើកស្នាដៃលោកមួយមកពិភាក្សា
រឿងគោតកុលកុមារ ។ រឿងនេះមិនសូវវែងទេ តែ
រិបូណ៌ដោយការរៀបរៀប ។ យើងអាចនិទានសរុបថ្ម
រឿងបានយ៉ាងខ្លីដូចតទៅ៖

គោតកុលកុមារ ជាមាណពកំសត់ប្រកបរបរធ្វើចំការ
ណាំបន្លែ ។ ឪពុកម្ដាយស្លាប់ចោលអស់ ។ ព្រះឥន្ទបាន
ទៅនាំបុត្រីព្រះរាជាមួយអង្គ ឯនគរមួយនៅកណ្ដាលសមុទ្រ
កឲ្យធ្វើជាភរិយាបុរសកំសត់នេះ ។ គូស្វាមីភរិយានេះ
ស្រឡាញ់គ្នាណាស់ តែនាងភរិយារូបឆោមល្អក្រៃលែង នាំ
ឲ្យកើតរន្ធឺឮដំណឹងទៅដល់ព្រះបាទព្រហ្មទត្តជាក្សត្រនគរនេះ

ទ្រង់ក៏ប្រើឲ្យរាជអាមាត្យរកមធ្យោបាយ យកនាងស្រីនេះឲ្យបាន ។ រាជអាជ្ញាទទួលបង្គាប់ហើយ ក៏ប្រើមធ្យោបាយគ្រប់បែបគ្រប់យ៉ាងបោកប្រាស់ចៅកំសត់នេះ តែរកសមាមាន ចៅកំសត់បេះតែមានជោគជ័យលើទៅវិញ ។ ថ្ងៃមួយអាជ្ញាបានចាប់បង្ខាំងរូបបុរសនេះបាន, នាងករិយាដឹងដូច្នោះក៏លួចរត់ចេញពីខ្ទមទៅឯនគររបស់នាងទៅវិញ ដើម្បីឲ្យផុតពីកណ្ដាប់ដៃអាជ្ញា ។ លុះគោតកុលកុមារត្រឡប់មកវិញរកប្រពន្ធពុំឃើញក៏នាំឆ្កែមួយដើរទៅតាម ។ ដល់សមុទ្រក៏នាំគ្នាហែលឆ្លង ។ ពេលនោះឆ្កែក៏ស្លាប់ទៅ នៅតែម្នាក់ឯងប្រឹងហែលឱបខ្មោចឆ្កែគ្រាតែមានត្មាតមួយមកជួយនាំផ្លូវ លុះទៅដល់សួនច្បាររបស់ព្រះចៅជាបិតាក្មេក ។ ពេលនោះមានពួកតាសី មកដងទឹកទៅជម្រះព្រះកាយឲ្យព្រះនាង ។ គោតកុលក៏លួចទំលាក់ព្រះទម្រង់ទៅក្នុងក្អម ដល់នាងនេះយកទៅស្រោចលើកាយព្រះនាង ស្រាប់តែចិញ្ចៀននេះបានចូលទៅសិតជាប់ក្នុងក្រោមក្រចកព្រះនាង ។

បានជាផ្ញើយកគោតកុលកុមារចូលទៅក្នុងនគរ រៀបអភិសេកឡើងគ្រងរាជ្យ ។ រួចដល់ទីបំផុត គឺវិលមកយករាជ្យពីព្រះបាទព្រហ្មទត្តសោយទៀត ។

ក្នុងផ្ទៃរឿងនេះ ឧកញ៉ាព្រះឃ្លាំង-នង រៀបចំក្បួនកាព្យនិងពាក្យពេចន៍ មិនចាញ់ឧកញ៉ាកោសាធិបតី-កៅ ទេ ដែលយើងនឹងឃើញក្នុងអត្ថបទដកស្រង់ពីក្នុងរឿងនេះ ដូចតទៅ ៖

«...ព្រះឥន្ទ្រដៀងជាក់ ទ្រង់បើកទិព្វចក្ខុ ជ្រួតជ្រាបថែថា
« គោតកុលត្រកាល ពិសាលសោភា ពុំមានករិយា ជាគូ
« សម្ពន្ធ ។ ទើបស្ដេចគិតថា នាងទេពធីតា ដែលអញនិមន្ត
« ចុះទៅមនុស្សលោក យោនយកបដិសន្ធិ នៅនាជបទ
« សត្តុជបុរី ។ អាស្រ័យនៅនា ក្នុងឧទរ ព្រះអគ្គមហេសី
« ស្ដេចសត្តុជរាជ អំណាចបុទ្ធី គ្រប់គ្រងបុរី ពលពាល
« សេនា ។ វេនគរនោះ ជាទួលកោះ កណ្ដាលជលសា
« ទំហំនគរ ចរិបចាំ ប្រូនយោជន៍គណនា នា...

" សព្វាយុ ។ ទៀបនឹងបុរី ពាកណាសី គណនាចម្ងាយ
" យោជន៍សាមសិបប្រាំ ពិតពុំឃ្លាតឆ្ងាយ គេគ្រាឈ្មោះ
" ឆ្ងាយ ចូលដូញឥតអាក់ ។ រីឯឯធីតា សោឲ្យស
" ស្រា គាបនូវនរលក្ខណ៍ ដូចទេពអប្សរ បវរសួស្តីសក្តិ
" ព្រះខាត់ព្រះភក្ត្រ ដូចចន្ទបូណ៌មី ។

អត្ថបទនេះ ចុះកញ្ចាំព្រះឃ្លាំង-ឧង ពណ៌នាពីសេចក្តីឈ្មោងយល់របស់ព្រះឥន្ទ ក្នុងការអញ្ជើញនាងទេពធីតាឲ្យចុះទៅចាប់កំណើតនៅនគរសេតកុដបុរី ដើម្បីបានជាគូនឹងកោតកុលកុមារ ។ កវីយើងបានបញ្ជាក់ថា បុរីនេះស្ថិតនៅជាកោះកណ្តាលសមុទ្រមានទំហំបួនយោជន៍ ។ ទើបបំផុតលោកពប់រៀបពីសម្រស់លំអរបស់នាងធីតា ដែលអាយុបាន ១៦ ឆ្នាំ ។ អត្ថបទនេះ អាចបញ្ជាក់បង្ហាញយើងពីការចំរើនលូតលាស់របស់អក្សរសាស្ត្រយើង ដោយសារស្នាដៃរបស់កវីខ្មែរបុរាណ ។

# ព្រះបាទហរិរក្សរាមាធិបតី ព្រះអង្គឌួង

ព្រះបាទអង្គឌួង ទ្រង់ជាព្រះរាជឱរសពៅនៃព្រះបាទ
ង្គអេង ព្រះចៅក្រុងកម្ពុជា សម័យព្រះរាជវាំងក្រុងឧត្តុង្គមាន
យ ។ កាលពីកុមារព្រះអង្គបានយាងទៅសិក្សាវិជ្ជានៅ
ប្រទេសសៀម ដែលនាំឲ្យព្រះអង្គទ្រង់ក្តីស្មានក្នុងព្រះបញ្ញា-
ាណខាងផ្លូវអក្សរសាស្ត្រ ។ ក្នុងឱកាសសិក្សានេះ ព្រះយុវ-
ត្របានធៀតរៀបរៀងជាសៀវភៅនិងបងក្រងច្បាប់ទំលាប់
ន ។ ទុកកេរ្តិ៍រហូតយើងសព្វថ្ងៃ ។ ក្នុងគ្រាដែលព្រះអង្គ
នឡើងគ្រប់គ្រងរាជសម្បត្តិហើយ ផែនដីកម្ពុជាដូចមាន
ល់ព្យុះគ្រប់ទិសបក់បោកបង្កើតជាកោលាហលក្នុងព្រះនគរ
ាលគឺបច្ចាមិត្រទាំងសងខាង បានជ្រៀតជ្រែកទឹកដី រាត
ណាចរបស់គេក្នុងប្រទេសយើង បណ្តាលឲ្យអ្នកស្រុកអ្នក
គរកើតវឹកវរសឹងគ្រប់ដំបន់ ។ ព្រះបាទព្រះហរិរក្សរាមាធិបតី
ប់បានប្រឹងតស៊ូទពេញព្រះកាយពល ដើម្បីបង្កើតសន្តិសុខ

សម្រាប់ប្រជានុរាស្ត្រដែលជាទីសព្វព្រះទ័យរបស់ព្រះអង្គឡើ
វិញ ។ ទោះបីជាស្ថិតនៅក្នុងយុគយ៉ាងវឹកវរយ៉ាងនេះក៏ដោយ
ព្រះករុណាព្រះអង្គខ្ជួន ទ្រង់មិនបោះបង់ ផ្នែកវប្បធម៌ឡើ
ព្រះអង្គតែងប្រមូលអ្នកប្រាជ្ញរាជបណ្ឌិតខាងសាសនា និងខា
អក្សរសាស្ត្រមកនៅជួបជុំគ្នាក្នុងព្រះរាជវាំង ដើម្បីត្រិះរិះព
ក្រងនូវក្បួនច្បាប់ផ្សេង ៗ ផង និងបង្ហាត់បង្រៀនដល់កុលបុ
ណាដែលត្រូវការស្វែងរកវិជ្ជាទៀតផង ។ មានសេចក្តីថ
ណាលថា ព្រះប្រិយមហាក្សត្រអង្គនេះបានធៀតពីកិច្ចក
ផែនដី យកពេលបង្ហាត់បង្រៀនព្រះសង្ឃគ្រហស្ថដែ
ជាសិក្ខាកាមកុលបុត្រទាំងឡាយផ្ទាល់ព្រះអង្គ ព្រមទាំងប
ឲ្យរាជការផែនដីទៅអនុវត្តការផ្សេង ៗ ប្រកបដោយអក្ស
សាស្ត្រត្រឹមត្រូវ ពោលគឺមិនឲ្យជនណាមួយសរសេរពា
ពេចន៍ឬសំបុត្រស្នាមបែបខ្ជីខ្ជាឡើយ ។ សេចក្តីថណា
មួយយ៉ាងទៀតថា ព្រះបណ្ឌិតអង្គនេះ ប្រកបដោយប្រ
សរីរៈរាងកាយមាំមួនល្អណាស់ ព្រះអង្គមិនសូវមានព្រះពេ

ឡើយ  បានជាយើងឃើញព្រះបរមធា យាលក្ខណ៍របស់ព្រះអង្គដ៏មានព្រះភក្ត្រធំទូលាយ ព្រះនេត្រថ្លាស្រឡះ ព្រះនលាដធំទូលាយដ៏មានកមោកោនវែងភ្ជាប់នឹងខ្នងព្រះឃានយ៉ាងមូលហើយស្រួចបន្តិច, ព្រះសុរង់ធំសមជាអ្នកមានវោហារសំខាន់ណាស់ ។ ចូរយើងចាំថា គឺជាព្រះអង្គនេះហើយ ដែលជាបឋមក្សត្រនៃព្រះរាជសន្តតិវង្សព្រះមហាក្សត្រខ្មែរគ្រាបច្ចុប្បន្ននេះ ព្រោះរដ្ឋធម្មនុញ្ញយើងពោលថា "រាជសម្បត្តិនៃប្រទេសកម្ពុជា  ជាកេរ្តិ៍មត៌កពីព្រះបាទសម្តេចព្រះហរិរក្សរាមាធិបតីព្រះអង្គឌួង " ។

ព្រះបាទសម្តេចព្រះអង្គឌួងដែលជាមហាកវីឯករបស់ជាតិយើងបានទុកស្នាព្រះហស្តនូវរឿងក៏រ និង ក្បួនច្បាប់ជាច្រើនដល់សព្វថ្ងៃ ដែលវេលានេះយើងស្រាវជ្រាវឃើញមានតាំងពាក្យកាព្យខ្លះ ពាក្យរាយខ្លះដូចរាប់ឈ្មោះតទៅ៖ ១-រឿងកាកី, ២- រឿងសុគន្ធថោង, ៣- ច្បាប់ស្រីព្រះអង្គឌួង, ៤- បទពាលរឿងល្ខោនផ្សេងៗ ។ គ្រានេះយើងសូមលើកយកស្នា

ប្រហស្ទងករបស់ព្រះអង្គគឺរឿងកាកី មកធ្វើសេចក្ដីសង្កេត
គ្រឿងបញ្ជាក់ ដែលយើងអាចសរុបរឿងនេះបានដូចតទៅ

ព្រះបាទព្រហ្មទត្តមានអគ្គមហេសីប្រកបដោយរូបឆោ
លោមពណ៌ល្អក្រៃលែងព្រះនាមនាងកាកី ។ ព្រះអង្គស
ព្រះទ័យនឹងក្រសាលល្បែងចតុរង្គណាស់ ។ មានក្រុងគ្រ
មួយតែងក្លែងខ្លួនធ្វើជាមាណពមកលេងល្បែងចតុរង្គ ជាមួ
ព្រះអង្គជាពល់ថ្ងៃ ទើបឃើញសម្រស់រូបឆោមព្រះអគ្គម
សី ក៏កើតចិត្តប្រតិព័ទ្ធ ព្រមទាំងលួចបញ្ចេញអាគមប្ញកិ
ខ្លះ ៗ ឲ្យនាងឃើញផង ។ ដោយចិត្តរេរារាយ នាងក
ក៏បានតបទូវតែរិយាបថប្លែក ៗ ទៅគ្រុឌវិញដែរ ។ ពេ
លាចមួយ គ្រុឌនិមិត្តធ្វើព្យុះខ្យល់យ៉ាងខ្លាំងបណ្ដាលឲ្យ
ពដកំង កើតចលាចល ទើបគ្រុឌលបចូលទៅក្នុងបន្ទប់ប
នាងកាកី ហើយលួងលោមពយកនាងកាកី ទៅកាន់ស្ទ
សិម្ពលីទៅ ។ ក្រោយនោះព្រះបាទព្រហ្មទត្តទ្រង់រិតក្កជាខ្
ក៏ឲ្យគេស៊ើបរកតែពុំឃើញសោះ ។ ឯគ្រុឌតែងនិមិត្តខ្លួន

បង់ប្រាសាទជាមួយព្រះរាជាដូចធម្មតា ជូនជាដក់ជាប់តាំងកុំទ
ាង៍នាគីមកជាមួយផង នាំឲ្យព្រះអង្គកើតមន្ទិលសង្ស័យក
ាស់ប្រើកន្ទីនជាសេនាជំនិត ក្រែងខ្ទនជាសត្វចូលលបគោង
ខុតៅកាន់ស្ថានសម្ពលី ៗ លុះទៅដល់ហើយ, គន្ធីន
ានប្រែក្លាយជារូបធម្មតា តែបង់នាងនាគីគ្រាន់តែបានសំរេច
ប្រាថ្នា ៗ មួយថ្ងៃមកទៀត គន្ធីនលបគោងគ្រុឌគ្រ-
ប់មកនគរវិញ នាំពតិមានទៅក្រាបទូលព្រះរាជា ៗ លុះ
ពេលគ្រុឌមកលេងប្រាសាទទៀត គន្ធីនក៏ដេញពិណាច្រៀង
ាន់សំឡេងផ្តោះផ្តងឲ្យគ្រុឌ ទាល់តែគ្រុឌដឹងថា៖ នាងនាគី
ចិត្តមិនស្មោះត្រង់នឹងខ្លួនទេ ទើបម្ចាស់គ្រឡប់ទៅដេរស្តី
ងនាគី ហើយចាប់កញ្ចក់ នាងហោះយកមកដាក់ក្នុងព្រះរាជ-
ង៍ព្រះបាទព្រហ្មទត្តវិញ ៗ នាងនាគីចូលទៅសុំអង្វរខមា
ាសតែព្រះបាទព្រហ្មទត្តទ្រង់ពុំព្រម ក៏ត្រាស់បង្គាប់ធ្វើពោន
យបណ្តែតនាងនេះចោលទៅ ៗ

ដើម្បីបញ្ជាក់លើសេចក្ដីសង្ខេបនេះទៀត  យើងសូម
ស្រង់អត្ថបទបន្តិចពីក្នុងរឿងនោះយកមកធ្វើជាគំរូ  គឺយើងជ
ស្រង់ត្រង់បទចម្រៀងរបស់គន្ធប្រៀនឪជនឲ្យត្រុង  ដូចសេចក្ដ
ខាងក្រោមនេះ ៖

« ...ប្រាប់ក្មានធ្វើក្មេង  ចំអ
« **ឈងឈង**  ជាពាក្យកាព្យ
« ពិរោះពិណពេក ស្រួបស្រែក
« ខុតថា  ខ្សែស្រីស្រស់កា – ក
« កែវបងអើយ ៗ  ពិជា
« ក្មិនសួន ហាក់បានឃើញខ្លួ
« ជិតជាប់ចង្កើយ  កាលប
« ទីងពោ!  នៃបនៅ ៗ ទៀយ
« ព្រលឹងបងអើយ  ភ្ជាប់ស្និ



ត្រុងជាតួអង្គយ៉ាងសំខាន់ក្នុងអក្សរសាស្ត្រខ្មែរ ។

ស្នេហា ។ ក្រោយគ្រូឪទៅបាត់ បានបងប្រតិព័ទ្ធ ស្ទាប់
ប្ដងគ្រូឪ ថ្នាក់ថ្នមផ្ដេកផ្ដិត ជួញជិតឱក កេសកើយខ្នើយ
ា - មួយមិនដាច់ ។ ក្រៀមក្សាន្តសាទរ សេពសុខសមពារ
មរសម្បូលមៃ -- ត្រីត្រេកមនោរម្យ បន្សំសុខសេ - យព្រាស
បរគ្រប់ថ្ងៃ ប្រាំពីរទិនបង ។ ឱស្រីបងបាត់ ស្រីស្ងួន
រូបស្ងាត់ សមខ្លួននឹងវង ទុក្ខទល់ម្នាក់ម្នេញ កន្ទេញ
ខ្នង កន្ទេងគិតបង បងបាត់លង់លន់ ។ កុំមានគ្រូឪ
ងនឹងស្ងួនភ្ងា ឲ្យអស់ជីពជន្ម ឥឡូវគ្រូឪត្រង់ មូលផង
បម្ពួន បួនអើយបងអន់ បងអួលឱក ។ ឱបងនឹងយក
មមាសមិត្រមក ផិតដោយអាត្មា មោះបុបងដើរ ដំណើរ
ហាស៍ ដោយសារគ្រូឪ នានាំបងមក ។ . . .

## ឱកញ៉ាសន្ធរវោហារ-ម៉ុក

នៅចុងសម័យឧត្តុង្គ យើងប្រទះឃើញអ្នកនិពន្ធមួយ
ទៀតយ៉ាងតើតណាស់ដែរ ដែលយើងគួរតែលើកយកមក
ាយក្នុងទីនេះ គឺឱកញ៉ាសន្ធរវោហារ - ម៉ុក ។

សន្ធរម៉ុក មានស្រុកកំណើតនៅក្នុងស្រុកសំរោងទង
កំពង់ស្ពឺ ។ កាលពីកុមារបានទៅនៅរៀនសូត្រក្នុងសំណា
លោកគ្រូរាជធម្មអធ គង់វត្តគុកក្នុងភូមិខ្ពង្គ ។ កុមារ
ឧស្សាហ៍ណាស់ខំរៀនសូត្រឥតមានធ្វេស ទើបបានជាទីស
ព្រះទ័យរបស់លោកគ្រូ ។ កាលណាហាត់សរសេរអក្ស
កុមារនេះសរសេរតែដោយធ្យូងលើរំលែងឥដ្ឋឬក្បឿង ព្រ
ខ្លួនជាកូនអ្នកកំសត់ទុគ៌តពេកណាស់ ។ លុះគ្រប់អាយុហើ
លោកគ្រូបំបួសជាសាមណេរ រួចជាភិក្ខុនៅក្នុងវត្តនោះ
កាលដែលលាចាកសិក្ខាបទមក ព្រះរាជធម្មអធ បាននាំ
ថ្វាយព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ដើម្បីធ្វើជាក្មា
ងារក្នុងក្រុមព្រះអាលក្ខណ៍ ។ ប៉ុន្តែព្រះអង្គទ្រង់ជ្រាប
ក្មាក់ងារក្មេងនេះជាអ្នកចេះដឹងក្បួនច្បាប់ពិតប្រាកដ ព្រះអង្គ
ទ្រង់តែងតាំងឲ្យធ្វើជាចាងហ្វាងក្រុមព្រះអាលក្ខណ៍ ហើយ
ជាគ្រូលើនាម៉ឺនទាំងឡាយ ខាងការបង្ហាត់បង្រៀនពីច្បា
រាជការផែនដី ។ តែអកុសល លោកឧកញ៉ាសន្ធរ-ម៉ុ

ពិការថែ ដោយគេតម្កល់ទុកត្រាដៃលោកឲ្យត្រូវនឹងចំណងសន្ធាន ទើបមានពាក្យជំណាលថា « ម៉ែកក្រនឹក-ម៉ុកក្រនឹង » ។ ក្រៅពីកិច្ចការរាជការ លោកតែងតែងសរសេររឿនកាព្យល្អ ៗ ណាស់ដែរ ទើបបានជាទីសព្វព្រះទ័យ របស់ព្រះបាទសម្តេចព្រះនរោត្តម ។ កាលណាព្រះអង្គទ្រង់យាងទៅណាមកណា តែងប្រោសរាជទានឲ្យសន្ធរ-ម៉ុកទៅតាមដង្ហែជានិច្ច សម្រាប់ជួបនឹងហេតុការផ្សេង ៗ សន្ធរ-ម៉ុកនឹងលើកជាកាព្យថ្វាយព្រះអង្គជាទីព្រះសណ្តាប់មួយរំពេច ផ្សិតបណ្ឌិតនេះពូកែខាងលើកកំណាព្យក្នុង ៗណាស់ ហើយបានសមរម្យ ដូចប្រយោគរបស់លោកមួយយ៉ាងខ្ចីថា ៖

« ហើយនែតាចិតតាមួយកាក់ តាចិតកន្ត្រាក់បានសាច់ខ្វែ
« តាញាក់កាប់ខ្ទាប់សាប់ញាប់ដៃ ហើយលៃឲ្យធាប់ប្រញាប់ឆាន់ ។

ប៉ុន្តែបើកាលណាលោកសរសេររឿងវែងលោកមិនប្រើពាក្យកំប្លែងដូច្នេះទេ លោកច្រើនប្រើពាក្យខ្ពស់ខ្ពះ ពាក្យសា-

ចញ្ចូះ ដែលយើងឃើញស្នាដៃពីរប្លែកពីគ្នានី រឿង ទេវន្ត លោកសរសេរសុទ្ធតែពាក្យពិបាកៗ គួរឲ្យចង់សិក្សា; ស្នាដៃលោកមួយទៀតគឺរឿង ទុំ-ទាវ[១] លោកបែរជាសរសេរសុទ្ធតែពាក្យងាយយល់ងាយគិតទៅវិញ ដើម្បីឲ្យសមនឹងការជាក់ស្តែងក្នុងសម័យរឿងនោះ ។

នេះជាសេចក្តីដកស្រង់ពីក្នុងសាស្ត្រារឿងទេវន្ត ៖

«... ទឹកដសីមា ឥស្សូរសុខា ក្សត្រថ្លៃវរវង្ស អធិកពិស្តារ-
«ធិការកិម-ន្តលគាប់ឧត្តុង្គ ឧត្តមឧត្តលា ៗ នៅទាងឧត្តរខម
«ឧត្តខណ្ឌព្រះហេម-ពានូទាងឧត្តក បន្ទាយជុំវិល ក្រុំពីរ
«ជាន់មហា-ទឹឃោរជាយទ្វារ សឹងមានមណ្ឌប ៗ គួរគាក
«ថ្នាក់ថ្នល់ ឥតដលមានជល ពិចិត្រក្រៅគ្រប់ ផ្កាព័ទ្ធផ្កាតែន
«ខ្វាត់ខ្វែងប្រសព្វ ប្រសើរសឹងអ-ក្តិរម្យគួរខ្វាច ៗ វ្រសត្ត
«ប័រ-កណ្ឌសីឧត្តរ ព័ទ្ធសុមេរុពេជ ប្រាសាទវេទនា ក្រុំ

---

១- ស្នាដៃទុំទាវសន្ធរម៉ុកនេះ យើងរកពុំទាន់បានច្បាប់ដើមមកបោះពុម្ពនៅឡើយ ព្រោះតែឃើញសំណៅខ្លះវរហ៊ាត់រហ៊ាយមិនគ្រប់គ្រាន់ ។

« ប្រការស្ងាច ចៃញ្ចងចិញ្ចាច វ្រក្តៈបន្ទន់ ។ ...»

គ្រង់នេះ សន្ទរម៉ុកទិតានប្រាប់យើងពីទ្រង់ទ្រាយប្រាសាទមួយដែលស្ថិតនៅជិតព្រៃហេមពាន្ត មានឈ្មោះកជសីមាកាសេយ្យ ។ បន្តទៅទៀតយើងស្រង់ស្នាដៃរបស់លោកមួយទៀតដែលជាការថ្លែងមនោសញ្ចេតនារបស់លោក ៖

« ស្រឡាញ់ស្រីគួច ស្រីទៀតមិនដូច មិនដល់មាសបង
« មាសបានសាងផល កុសលឥតហ្មង ឥតមានប្រឡង
« ប្រឡះកាំបាន ។ ភ័ព្វនាងបានជួន បានជួបនឹងខ្លួន
« នឹងនាងកល្យាណ កល្យាណ៍កបលក្ខណ៍ ចិត្តស្ម័គ្រស្មោះ-
« ស្មាន ស្មោះស្មើនៅឋាន នៅចំតមូលគ្នា ។ ប្រសិនបេះ
« ហោះ បេះហើរបេះផ្កោះ ទៅថ្នមអង្គា អង្កៀកប៉ះពាល់
« រៀងពល់វេលា ពិលាបដោយនា ដោយនូវកន្ទង (១) ។

សេចក្ដីដកស្រង់ខាងលើនេះ ឧកញ៉ាសន្ទរម៉ុក បានយកសេចក្ដីខ្លះទៅផ្ដិតជាប់ជាមួយការស្រមៃនឹក ។ លោកបេះគ្រង

១- អត្ថបទនេះស្រង់ពីកាសែតស្រុកខ្មែរ បោះពុម្ពនៅព្រៃនគរ, ខែកញ្ញា ១៩២៧ ។

ពាក្យកាព្យ កយគន់ទុក្ខបណ្ដាក់គ្នា ជាមួយសេចក្ដីបំណង
ទឹង លោភណ៍ ភាពនៃនារីដែលគាត់ពេញចិត្ត នាំឲ្យអ្នកផងភាព
ជួយស្រឡាញ់ ជួយកើតទុក្ខ ជួយប៉ុនប៉ង ជាមួយទឹងគាត់
ដែរ ៗ ដូច្នេះហើយ ទើបយើងស្គាល់ជាក់ថា ឧកញ៉ា
សន្ទរពោហារ ម៉ុក ជាកវីយ៉ាងជំនាញក្នុងសម័យឧដុង្គក្រាចុង
បំផុត ៗ





## ជំពូកទីប្រាំបួន

# អក្សរសាស្ត្រសម័យអាណាព្យាបាល

ឥឡូវនេះ យើងត្រូវនិយាយពីរឿងរ៉ាវអក្សរសាស្ត្រខ្មែរយើង ក្នុងសម័យអាណាព្យាបាល ។ គ្រាន់តែឮឈ្មោះសម័យនេះ យើងប្រមាណដឹងខ្លះហើយថា ៖ ជាសម័យដុនដាបមួយរបស់អក្សរសាស្ត្រយើង ។ គឺគ្រានោះឯងដែលប្រទេសខ្មែរយើង ត្រូវធ្លាក់ខ្លួននៅក្រោមឱវាទពួកបស្ចិមប្រទេសអស់រយៈជាងប៉ែតសិបឆ្នាំ គឺតាំងពី គ.ស. ១៨៦៤ រហូតដល់១៩៥៣ ជាគ្រាដែលខ្មែរដោះខ្លួនផុតពីអាណាព្យាបាលរបស់បរទេស ។ លោកអ្នកគង់នៅចាំបានសឹងតែគ្រប់

ន្នះហើយកាលពីសម័យនោះ តើអក្សរសាស្ត្រយើងយ៉ាង
ណា ? យើងមិនដែលឃើញអក្សរខ្មែរលេចមុខមកជា
ង្ប់ការដើម្បីបង្ហាញដល់សាធារណជនទេ ។ ចំណែកក្បួន
ខ្នាតនានាខាងអក្សរសោត ក៏ឥតដែលមាននរណារាប់អាន
លើកឡើងជាគ្រឹមុខឡើយ ។ ហេតុនេះឯងអក្សរខ្មែរក៏រត់ទៅ
ពួនអាត្មាយ៉ាងស្ងាត់ស្ងៀមនៅតាមវត្តអារាម ឬក្រោមខ្នងផ្ទ
ជាប់ទងសិក្សាចារឹកទាំងឡាយ ឥតមានគំរើកខ្លួនឡើយព្រោះ
ខ្លាចមានឧបសគ្គ ឬមហន្តរាយអ្វីដល់ខ្លួន ។ ព្រះសង្ឃពុទ្ធ-
សាសនិកទាំងឡាយ តែងយកព្រះទ័យទុកដាក់ប្រឹកប្រែង
ថែរក្សាគម្ពីរដំណាលទាំងនោះបាននៅគង់គត់មក ។ ព្រោះ
ដូចយើងតែងនិយាយជារឿយៗមកហើយថា អក្សរសាស្ត្រ
យើង បានបោះគោលចារឹកនៅក្នុងលទ្ធិពុទ្ធសាសនាយ៉ាង
ស៊ប់សួនខ្ជាំងណាស់ ។ ព្រះសង្ឃស៊ាធ្យាយធម៌គ្រប់ម៉ាត់
គ្រប់ពាក្យ ឬធម្មិកទេសនាគ្រប់លើកគ្រប់គ្រា សុទ្ធតែជា
មធ្យោបាយផ្សាយអក្សរសាស្ត្រសម័យនោះ ដើម្បីកេយខ្ញ

អានុភាពអក្សរខ្មែរ ឲ្យបានជ្រាបក្នុងសន្ដានចិត្តប្រជាករយើង ទូទៅ ។ ចំណែកទឹកចិត្តជនជាតិយើងវិញ ឃើញថាមាន ភាគច្រើនដែលនៅតាមនិគមជនបទ តែងមិនព្រមឃ្លាត ឆ្ងាយពីអក្សរសាស្ត្ររបស់ជាតិខ្លួនឡើយ ។ គេតែងបញ្ជូន កូនចៅឲ្យទៅរៀនសូត្រជាមួយព្រះសង្ឃ ដើម្បីក្រេបជញ្ជាក់ នូវរសជាតិវិជ្ជាផ្សេងៗ របស់ជាតិខ្លួន ។ ព្រះសង្ឃទៀត ក៏មានមេត្តាធម៌ក្រៃលែង ។ លោកប្រឹងប្រែងបង្ហាត់បង្ហាញ កុមារទាំងនោះលុះត្រាតែបានចេះអាន , ចេះសរសេរល្មមប្រើ ការបាន ទើបលោកឲ្យវិលត្រឡប់មកផ្ទះរកប្រកបអាជីវកម្ម តរៀងទៅ ។

នៅពេលទំនេរ ប្រជាជនខ្មែរ មិនដែលនៅស្ងៀមឥត ប្រយោជន៍ទេ គេតែងតែនាំគ្នាអានសាស្ត្រារឿង និទាន រឿងព្រេង ឬ ច្រៀងលេងតាមទំនុករបស់ខ្មែរបុរាណ គឺជា សាខារបស់អក្សរសាស្ត្រយើង ឬ ជាជាវត្ថុធាតុដែលសំរាប់ ផ្សំឲ្យកើត [illegible] យើង ។ តែគួរអនិច្ចាណាស់

របៀបសរសេរអក្សរក្នុងសម័យនោះ ព្រោះគ្មានឯកភាពសោះ ដោយក្បួនច្បាប់សំខាន់ៗរបស់យើងបានបាត់បង់ទៅជាច្រើន, សេតឯអ្នកប្រាជ្ញនានា ក៏សោះសូន្យមិនមានអើតមុខមកក្នុងមជ្ឈដ្ឋានជាផ្លូវការឡើយ ព្រោះខ្លាចអំណាចបរទេសដែលជាអ្នកគ្រប់គ្រង ៗ ទោះបីជាមានបណ្ឌិតណាធ្លៀតសរសេរបានរឿងរ៉ាវអ្វីមួយ ៗ ទុកមក គេពុំសូវហ៊ានបញ្ចេញឈ្មោះរបស់ខ្លួនឲ្យយើងដឹងទេ នៅសល់ត្រឹមតែស្នាដៃប៉ុណ្ណោះ ជាហេតុនាំឲ្យយើងស្ដាយក្រៃលែង ៗ អក្សរដែលចារនៅក្នុងស្លឹករឹតឬសរសេរនៅក្រាំងផ្សេង ៗ មិនដែលត្រឹមត្រូវតាមអក្ខរាវិរុទ្ធឡើយ ដូចជាពាក្យតែមួយម៉ាត់សោះ ពួកអ្នកសរសេរជាន់នោះអាចសរសេរដាក់តាមចិត្តខ្លួនទៅជាបី ឬ បួនបែប នាំឲ្យអ្នកសិក្សាពិបាកឈោងចាប់យកការរៀនចាត់ក្នុងពិធីសរសេរអក្សរនេះក្រៃលែង ៗ បើឃើញកំហុសយ៉ាងនេះ តើយើងចាត់ជាអ្នកនិពន្ធឬកវីជំនាន់នោះសរសេរខុសឬអ្វី ? បើតាមការស្រាវជ្រាវរបស់យើង គឺមិនមែនអ្នក

ានសរសេរខុសទេ    ព្រោះបើខុសមែនម្តេចក៏អ្នកទិញនោះ
ះយកពាក្យបាលី សំស្រ្កឹតពីបាកៗ មកបញ្ចូលជាមួយបាន ?
បក៏ចេះប្រើពាក្យទាំងនោះឥតឆ្គងសោះ ? ។ ត្រង់នេះហើយ
ញ្ញាក់ប្រាប់យើងថា កវីបុរាណខ្មែរលោកពិតជាចេះសរសេរ
ៀនចាត់ណាស់ ។ ឯកំហុសដែលយើងពោលខាងលើនេះ
កជាកើតឡើងពីពួកអ្នកដែលចារ ឬសរសេរចំឡងក្រោយ ៗ
ន្ទ ៗ មកនេះទេ ។ ដ្បិតពួកអ្នកទាំងនេះច្រើនមិនសូវបានរៀន
ក្រឹមសារអក្សរសាស្ត្រជាតិ ឲ្យជ្រៅជ្រះពិតប្រាកដមែន-
ន ដូចនេះទើបសរសេរឬចារតាមតែគំនិតខ្លួន គឺឲ្យតែថា
វចេះតែពីថាបាន ។ តែទោះបីជាមានហេតុឆ្គាំឆ្គងយ៉ាង
ងក៏ដោយ យើងសូមសរសើរពួកអ្នកមានព្យាយាមប្រឹង
ប្រឹងសរសេរចំឡងនេះដែរ ព្រោះដោយសារតែគំនិតល្អ
ស់អ្នកទាំងនោះហើយ ទើបសាស្ត្រារឿងរ៉ាវជាស្នាដៃអក្សរ-
ាស្ត្រយើង នៅគង់វង់រហូតឲ្យយើងឃើញសព្វថ្ងៃនេះ ។
យើងប្រទះឃើញស្នាដៃជាច្រើនណាស់ដែរ ដែលរៀបរៀង

ឡើងក្នុងសម័យនោះ  ដូចមានតារាងខាងក្រោមដែលម

ពប់រៀបពីស្នាដៃ, នាមអ្នកនិពន្ធ និងកាលបរិច្ឆេទដែលរ

រឿងរឿងនោះឡើង ៖

១- រឿងមរណមាតា ស្នាដៃឧម្ពញ្ញា-អ៊ុក ពី គ.ស.១៨៣

២- រឿងពោធិវង្ស ស្នាដៃ ព្រហ្មបរភក្តី ពី គ.ស. ១៨

៣- រឿងចៅមាស ស្នាដៃឃុនសន្ធរពិទិត្យ ពី គ.ស.១៨

៤- រឿងសព្វសិទ្ធិ ស្នាដៃ ហ្លួនភក្តីអក្សរ-គន់ ពី គ.ស.១៨

៥- រឿងសង្ខសិល្បជ័យ ស្នាដៃ ឧកញ៉ាវង្សាធិបតី-

ពី គ.ស. ១៨៨២

៦- រឿងព្រះលក្ខណវង្ស រៀបរៀងដោយ ចៅអធិការ

ព្រែកប្រណាក ពី គ.ស. ១៨៩០

៧- រឿងអំបែងបែក ឧកញ៉ាសុត្តន្តប្រីជា-ឥន្ទ ពី គ.ស.១៨

៨- កាព្យនិរាសអង្គរ " ពី គ.ស. ១៩

៩- គតិលោក " ពី គ.ស. ១៩

១០- រឿងពិម្ពាពិលាប អ្នកស្រី-សិទ្ធិ ពី គ.ស. ១៩

១–រឿងពិម្ពានិព្វាន លោកវិបុល កន ពី គ.ស. ១៩២០

២– រឿងតាឯក –"– ពី គ.ស. ១៩៤២

៣– រឿងបិសាចស្នេហា លោកញ៉ុក-ថែម ពីគ.ស.១៩៤០

៤– រឿងកុលាបប៉ៃលិន –"– ពីគ.ស.១៩៣៦

៥– រឿងទឹកទន្លេសាប លោក គឹម-ហាក់ ពីគ.ស.១៩៤១

៦– រឿងសេកសោមបណ្ឌិត –"– ពី គ.ស.១៩៣៣

៧– រឿងសុផាត លោករីម-គីន ពី គ.ស.១៩៣៨

៨– កែបមាត់សមុទ្រ លោកគួច-សឹងហាន គ.ស.១៩៤២

៩– មហាអភ័ព្វ លោក អ៊ុម ហ៊ី ពី គ.ស.១៩៤៦

១០– ចៅកើតកុសល លោក នង-ឈុំ ពី គ.ស.១៩៤១

ក្រៅពីនេះ យើងឃើញមានរឿងជាច្រើនដែលយើងរកឈ្មោះអ្នកនិពន្ធមិនឃើញ បានជាយើងមិនបានលើកយកមកប់ក្នុងទីនេះ ។

បើយើងពណ៌នាសរុបផ្តុំរឿងទាំងនោះ មិនសូវខុសគ្នាន្មានទេ ដូច្នេះយើងគ្រាន់តែរែកញែកជាពីរពួកប៉ុណ្ណោះ គឺពួក

រៀបរៀនតាមបែបបុរាណ និងពួករៀបរៀនតាមបែបទំនើប

បែបបុរាណ, អ្នកនិពន្ធបានទូលាយចិត្តណាស់ក្នុងការប
ក្រងផ្ទៃរឿង គេអាចនិយាយតាមចិត្ត ចង់តួនីមួយ ៗ ស្លា
ប៉ុន្មានដងក៏ដោយ តែងតែមានអ្នកមានឫទ្ធិបារមីមានព្រះឥ
ជាដើម មកជួយប្រោសជននោះឲ្យរស់មានជីវិតឡើងវិញ
ឯដំណើរតាន់គ្នាសោតទៀតជួនកាលឃើញថាពិបាកពេក ដូ
ជាដើរកាត់ព្រៃ ធ្វនពលតាមព្រៃកុំគ្រុច, ជួនកាលឃើញប
ងាយពេក ដូចជាជិះសេះ, ជិះហង្ស, ហោះហើរដើរលើ
អាកាសជាដើម ។ ចំណែកមួយបែបទៀត គឺបែបទំនើ
អ្នកនិពន្ធបានសិក្សាវិជ្ជាផ្លូវលោកចេះមុតមាំ ស្គាល់នូវបញ្ហ
របស់ជីវិតមនុស្ស ចេះប្រឌិតការរស់នៅរបស់មនុស្សធម្ម
ឲ្យផ្ចិតជាប់ក្នុងផ្ទៃរឿង ។ តួនីមួយ ៗ លែងចេះហោះហើ
ដើរលើអាកាស, ព្រះឥន្ទព្រះព្រហ្មក៏លែងចុះមកជួយ, មហ
ឫស៊ីឬព្រះឥសូរក៏លែងបង្រៀនមន្តអាគម តួអង្គក៏មិនមែនជ
ពោធិសត្វចុះពីត្រៃត្រឹងឬពីតុសិត ដូចមុន ៗ ទៀតហើយ

ងនេះអ្នកនិពន្ធទំនើប បានយកមនុស្សសាមញ្ញទៅដើរតួក្នុង
រឿង, បានលើកបញ្ហារស់នៅ របស់មនុស្សសព្វថ្ងៃ មក
ភាគត្រងានឲ្យបានសក្តិសម នឹងកម្រឹតសតិស្មារតីរបស់ជន
ប្បុប្បន្ន មិនឲ្យហួសកម្រឹតឡើយ ។ ប៉ុន្តែមានការបំភ្លែក
យក្នុងអក្សរសាស្ត្រយើង ត្រង់ដែលរឿងទំនើបទាំងនេះ
បងតែងជាពាក្យកាព្យទៀតហើយ ។ គេធ្វើជាពាក្យរាយ
បជាភាសាអ្នកស្រុកនិយាយកាន់គ្នាជារាល់ថ្ងៃ ។ ឯគតិរឿង
ហាតក៏ងាយយល់, ងាយគិតល្មមនឹងសមត្ថភាពរបស់ជន
ាមញ្ញ មិនប្រើពាក្យខ្ពស់ៗពេក ហើយក៏មិនប្រើពាក្យទាប
ាកពេកដែរ ។ សរុបសេចក្តីទៅ គឺអ្នកនិពន្ធគ្រានេះ
នស្គាល់អានុភាពវិទ្យាសាស្ត្រ រៀនសូត្រចេះដឹងតាមបែប
ៀធម៌ដុះដាល នៃពិភពលោកដ៏ជាក់ប្រាកដ ។

យើងធ្វើការសិក្សាតទៅទៀតចំពោះស្នាដៃអក្សរសាស្ត្រ
ើង ក្នុងសម័យអាណាព្យាបាល ។ ដូចយើងបានពណ៌-
ន៍រៀករឿងកពីរបៀបតែងក្នុងសម័យនោះ ដូចមកហើយថា៖ ជា

ដំបូងគេឃើញមានអ្នកនិពន្ធសរសេរបៀបក្វើតក្វើន ដូចកា
សម័យកណ្ដាលដែរ ហើយកំណាព្យសម័យនេះ យើងឃើ
មានការប្ដូរបៀបតែងជាបទកាព្យ ៧, ពាក្យ ៨, ពាក្យ ៩ ព
ពីដើមរឿងរហូតចប់រឿង ដូចជារឿងសព្វសិទ្ធិជាដើម ។ ដូច
ដើម្បីបញ្ជាក់ជាក់ស្ដែង យើងលើកយករឿងទាំងនេះ និ
នាមអ្នកនិពន្ធខ្លះៗមកសិក្សាដូចតទៅនេះ ៖

## ម៉ឺនភក្ដីអក្សរ - គង់

៖ **រឿងសព្វសិទ្ធ** ជាស្នាដៃរបស់អ្នកនិពន្ធឈ្មោះ គង់ ដែ
មានគោរម្យងារជាម៉ឺនភក្ដីអក្សរ និពន្ធឡើងពី គ.ស.១៨៩៩
រឿងនេះមានផែនរឿង មិនខុសពីរឿងដទៃៗ កាលពីសម័យមុ
ទេ ប៉ុន្តែយើងឃើញការប្លែក ត្រង់ដែលអ្នកនិពន្ធនេះមិនស
សេរកំណាព្យជាបទពំនោល, ព្រហ្មគីតិ ឬ កាកគតិទេ ។ លោ
សរសេរជាកាព្យពាក្យ៧ រហូតតាំងពីដើមដល់ចប់ប្រកបដោ

ក្យៈពេចន៍ផ្អែមត្រកួនតាមចិត្តណាសៅផៃ   ដែលយើងលើក

កាសពក្ដីមួយទៀតគង់រឿងនោះមកបង្ហាញជូនតទៅ ៖

.ធម្មតាកើតមកជាកូនស្រី   ទោះគ្មានស្វាមីតាមសណ្ដាប់

គេហៅថាប្រើយស្រីគតសត្វ   ខុសនឹងគម្រាប់ពីបូរាណ ។

មិនគួរកំណាញ់ពាក្យមួយម៉ាត់   សម្ងំស្ងាត់មិនសងសាន

មួយម៉ាត់ពីគាត់ថ្លៃប៉ុន្មាន   វៀរអៀនកាក់ហានជូនតាមហ៊ា ។

ប្ដីគ្រងស្ដីនោះផ្ដេសផ្ដាសព្រាក់   ប្ដីមួយគ្រងផ្កាក់ផ្កាបម្រ៉ា

ប្រព្រាប់ចំពោះសោះសង្ការ   ប្ដីមិនបរទាំគេខឹងបង ។

ប្រុសឯទៀតគេខ្ទៀតគងស្ដី   អញ្ចឹងទេស្រីស្នេហ៍ស្នង

ប្ដីមួយគេថ្លៃលង់គន្លង   ទើបមិនសាសងសព្វរ៉ាទី ។

គង់អគ្គបទខាងលើនេះ   មិនកក្ដីអក្សរ គន់ប្រើល្បើច

ស សំនួនហោហាល្ងង់ណោម   ដណោលកាលនាងសុវណ្ណ-

សមិនស្ដីជាមួយប្រុសនោះ   ហើយព្រះបិតាបានចាក់

ប្រគោស្ដូបមាមាតូលទៅស៊ីប្រណាមឲ្យបាននិយាយគប ។



# ឧកញ៉ាសុត្តន្តប្រីជា – ឥន្ទ

លោកឥន្ទមានកំណើតកើតឯរការកោង ស្រុកមុ
កំពូល ខេត្តកណ្តាល ដែលជាដំបន់ទន្លេធំ បរិបូណ៌ទៅ
ទេសភាព ។ បិតាឈ្មោះបញ្ញាន់-កែ; ម្តាយឈ្មោះមុំ លោ
កើតពីឆ្នាំ ១៨៥៩ ។ លុះអាយុ ១០ ឆ្នាំក៏បានទៅនៅ
សិក្សាអក្សរខ្មែរនិងតាមហាត់រៀនប្រគុំភ្លេងផ្សេង ៗ រួចហើ
លោកចូលបួសជាសាមណេរ ។ អាយុ២០ឆ្នាំ លោកទៅ
ទៅបន្តវិជ្ជានៅប្រទេសសៀមបាន ៧ ឆ្នាំ ត្រឡប់មកស្រុកវ
វិញ ។ អាយុ ៣៧ ឆ្នាំបានលាចាកផ្នួសមកមានប្រពន្ធ
នៅខេត្តបាត់ដំបង។ លោកឥន្ទជាអ្នកស្រហ៍សរសេរកា
ទើបពេលនោះ លោក ថាថន ឈុំ បានឲ្យគេទៅចំហ
ទៅហារ ។ លុះលោកអាយុបាន ៥៥ ឆ្នាំ ពលការបានអញ្ជើ
លោកឲ្យមកធ្វើការនៅក្រុងភ្នំពេញ ក្នុងក្រុមពុទ្ធសាសន
បណ្ឌិត្យ ចំណុះមុខងារ ខាងតែងនិពន្ធក្បួនច្បាប់ផ្សេង ៗ និ
ជួយរៀបរៀងវចនានុក្រមខ្មែរ ។ ដល់បានអាយុ ៦៥ ឆ

ហើយលោកសុំលាពីការត្រឡប់ទៅនៅឯបាត់ដំបងវិញ ។ លោកទទួលអនិច្ចកម្មដោយសាររោគក្អក ពីឆ្នាំ ១៩២៨ ។ ឯលក្ខណៈខាងក្រៅរបស់លោក គួរជាជនមួយល្មមស្រឡាញ់រាប់អានក្រៃលែង លោកចូលចិត្តនិយាយក្រមាច់ក្រមើមច្រើន តែជាអ្នកមានស្មារតីរឹងប៉ឹងមិនរវល់នឹងការអ្វីឥតប្រយោជន៍ទេ, មាត់លោកស្រួចមញ្ហាញគិរិយាជាអ្នកនិយាយច្រើន ។ ទៅណាមកណាលោកតែងស្លៀកសំពត់ចងក្បិន, ពាក់អាវគ្រង



កាន់ដំបងប្រាក់ , ពាក់មួកកាស ហើយបន្ទួសស្បែកជើងផ្ទាត់លុង ៗ គ្រាណាដើរទៅមុខ លោកច្រើនងើយមើលលើ ។

ពេលដែលលោកអនិច្ចកម្មទៅ គេរកឃើញស្នាដៃដែលលោកសរសេរបាន

ចំនួន ៤៤ មុខ តែដែលបោះពុម្ពហើយមានតែរឿងអំបែងបែក, សុភាសិតច្បាប់ស្រី, លោកនីតិបករណ៍, ក្បួនមេកាព្យ, កាព្យនិរាសអង្គរ នឹងគតិលោកប៉ុណ្ណោះ ។ ក្នុងចំណោមស្នាដៃរបស់លោកដែលបោះពុម្ពហើយទាំងប៉ុន្មាន យើងឃើញមានសាច់កាព្យគួរឲ្យចាប់ចិត្តណាស់ ចំណែកពាក្យពយសោក ក៏លោកប្រឌិតឡើងជារឿងរ៉ាវប៉ូន្នានសន្តានចិត្តជនា-នុជន គ្រប់រូបឲ្យមានស្មារតីរឹងប៉ឹងបេះពិចារណា មាំមួនមុននឹងធ្វើការអ្វីមួយ ។ យើងដកស្រង់ស្នាដៃ ជាពាក្យកាព្យមួយមក ព្រោះកវីរូបនេះ ល្បីល្បាញជាបំផុតខាងកំណាព្យក្នុងសតវត្សរ៍ទី ២០ នេះ ។ សេចក្តីដកស្រង់នេះ យើងស្រង់ចេញពីរឿងនិរាសអង្គរ ដែលលោកសរសេរក្នុងពេល ដែលលោកបានទៅជួបប្រទះនឹងរូបភាព ចម្លាក់រចនានៃប្រាសាទអង្គរជាដំបូង ដូចមានសេចក្តីរាប់រៀបជាពាក្យកាព្យ ឃ្លោងជូនរណ្តំតទៅ ៖

. . . គយគន់ស្ពានស្ពានថ្មតប្រជិត

ជាក្តារថ្មជាសជិតប្រកិតគោក

ទោះដំរីបរជាន់គគ្រាំនយោគ
ឥន្ទ្រីជ្រោកស្រុតខ្លះតែដើរបាន ។
បង្កាន់ដៃខ្ញរូបរ៉ស្រ្តី
ផប់សិរសីដូចស្និតជិតជុំព្រាណ
លើកពពារទៀនពញ្ចាក់ហាក់ហាវហាន
សំផែនព្រាណប្រញ៉ូរូបជាមួយគ្នា ។
មើលទាគកជអន់អាចអំណាចស្វែន
ខ្លួនក៏វៀនក្បាលក៏វក់តាមទ្វាព
លួនលើស្ពានមានជើងកល់គន្ដា
កន្ទុយបែកញែកគ្នាតាមធ្លាផ្លូវ ។
ឱ ! រូបរ៉ស្រ្តីឥតក្រែងគ្រុឌ
តាំងសំផែនចុច្ចិរទ្ធតសត្រូវ
ប្រសិនគ្រុឌមកយល់យ៉ាងពុំនៅ
គង់ស្ទុះទៅជ្រកក្នុងកសិន្ធុនេះ ។
នាគអើយនាគផ្កាសានបុរាណសាង-

ពីដើមយ៉ានល្អឯកដូចម្ដេចនេះ
ឥឡូវខាតឆាកភ្លាក់បាក់បេះ
ឃើញតែកងយ៉ាននេះអស់លំអរ ។
ខ្លួនកំឃ្លាតក្បាលកំឃ្លៀងទៅដោយខ្លួន
ឃើញតែក្បួនដើងទៀនប្រចាំច្រ
ស្ដាយអើយស្ដាយស្នាដៃលោកតាំងមក
មិនតាំងតហាវរៈឲ្យវែងទៅ ។
ខេមរិន្ទាសន្ធរនាគាថ្ម
ហ្វាយតស្ថិតស្ថេរចេរកាលនៅ
នេះមិនទាន់ប៉ុន្មានមកហ្វងសៅ
មករុះរាយធ្លាក់ទៅទីទៃផ្ដាស់ ។
មែនហ្ន៎សព្វសង្ខារគ្រងលោកីយ៍
មិនថាអ្វីកើតមកគង់វិនាស
ចុះត្រៃលក្ខណ៍ជាក់យ៉ាងពុទ្ធប្រកាស
សង្ខារចាស់គង់ផ្លាស់ទៅជាថ្មី ។

ចំណែកសេចក្ដីខាងលើនេះ លោកឧកញ៉ាសុត្តន្តប្រីជា-អ៊ិន នាំយើងឲ្យស្ទុងទៅគេរូបចំឡាក់នៅអង្គរវត្ត ដែលកសាងមកជាច្រើនសតវត្សហើយ ហើយដែលឥឡូវនេះបាក់បែកទ្រុឌទ្រោមជាច្រើនណាស់ទៅហើយផង ។ ត្រង់នេះហើយដែលកវីឯករបស់យើងបានទាញយកទៅធៀបនឹងសង្ខារអ្វី ៗ ផ្សេងដែលកើតមកក្នុងលោក ហើយតែងតែវិនាសត្រឡប់ទៅវិញជាធម្មតា ។ លោកកវីនេះ ប៉ិនប្រសព្វខាងធ្វើការពប់ទៀបពីពលនាអ្វីមួយបានសំរើក ហាក់ដូចជាយើងអ្នកគានបានទៅឃើញជាមួយលោកដែរ ។ ស្នាដៃលោកទាំងអស់ សុទ្ធតែពប់ជាជាបានការឥតមានចន្លោះមួយឡើយ ដែលអ្នកសិក្សាអក្សរសាស្ត្រទាំងឡាយ គប្បីយកចិត្តទុកដាក់ចំពោះស្នាដៃរបស់លោកឲ្យមែនទែន ។

## ឧកញ៉ាវិបុលរាជសេនា នូ-កន

លោកកនមានស្រុកកំណើតនៅឃុំអង្គតាសោម ស្រុកត្រាំកក់

ខេត្តតាកែវ, បិតានាម ឌូ, ម្តាយនាម អ៊ុក ។ លោកកើត ពី គ.ស. ១៨៧៤; អាយុបាន ៩ ឆ្នាំ ឪពុកម្តាយបាននាំឲ្យទៅនៅសិក្សាក្នុងសំណាក់លោកគ្រូ អ៊ុន-ជា គង់វត្តគោក (អង្គតាសោម) ។ លុះអាយុបាន ១៤ ឆ្នាំ លោកបួសជាសាមណេរបានមួយវស្សារួចសឹកមកវិញ ។ អាយុ ១៧ ឆ្នាំ ចូលធ្វើជាស្មៀនលោកចៅហ្វាយខេត្តទ្រាំង មានមុខងារខាងដើរតាមពន្ធដារ ។ ក្នុងរវាង គ.ស. ១៨៩១-៩៤ លោកបានធ្វើការនៅក្នុងក្រុមព្រះអាលក្ខណ៍ ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះនរោត្តម ។ បន្ទាប់មកពីនេះ លោកបានចូលធ្វើរាជការក្នុងក្រុមសុរិយោដី រួចខាងឃ្លាំងប្រាក់ ។ ក្នុង គ.ស.១៩០២ លោកបានប្រឡងជាប់លេខមួយខាងអក្សរខ្មែរបានសញ្ញាបត្រ រាជការក៏តាំងធ្វើជាចៅហ្វាយខេត្តកំពង់-សៀម ហើយរាជការផ្លាស់លោកទៅធ្វើការនៅជាច្រើនខេត្រទៀត ។ លោកជាអ្នកជំនាញខាងផ្លូវច្បាប់ ទើបក្រោយមកបានធ្វើជាចាងហ្វាងសាលាលុយុន និង សាលា

ទូរណ៍ ។ កាលនោះរាជការអាណាព្យាបាលបានអញ្ជើញ លោកឲ្យទៅបំពេញវិជ្ជាខាងរៀបរាជការ នៅប្រទេសបារាំង អស់រយៈ ៩ ខែ ។ លុះត្រឡប់មកវិញ លោកធ្វើជាគ្រូជួយ សេនាបតីក្រសួងក្សេត្រាធិការ មានគោរម្យងារជាឧកញ៉ា វិបុលរាជសេនា ។ លោកទទួលនិវត្តន៍ពីការរាជការហើយ លោកនៅតែខំព្យាយាមសរសេរតុបតែងជារឿងរ៉ាវ និងប្រែ រឿងណាសំខាន់ៗ ពីភាសាបរទេសមកជាភាសាខ្មែរ ។ កាលពី គ.ស.១៩៤៥ គ្រាដែលប្រទេសខ្មែររៀបចំការបោះឆ្នោតជាដំបូង ដើម្បីបង្កើតរដ្ឋសភាកសាងច្បាប់រដ្ឋធម្មនុញ្ញនោះ លោកបានជាប់ឆ្នោតជាតំណាងរាស្ត្រ ក្នុងមណ្ឌលកោះសូទិន ខេត្តកំពង់ចាម ។ ឯកិរិយាខាងក្រៅរបស់លោក គេចាំបានថា លោកជាអ្នកស្រាប់និយាយតែសំដីលោក មួយៗ មិនសូវញាប់ទេ ហើយច្បាស់លាស់ណាស់ផង ។ មុខលោករាងមូល, ជើងសក់ធ្លូក, លោកទុកពុកមាត់ងខ្នាំ ព្រមទាំងមានកែវតាធំសមជាអ្នកត្រិះរិះពិចារណា

ច្រើន ៗ ក្រោយដែលលោកស្លាប់ទៅគេរកឃើញស្នាដៃរបស់លោក ដែលបានបោះពុម្ពហើយ និងខ្លះទៀតពុំទាន់បានបោះពុម្ពមានជាច្រើនដូចតទៅនេះ ៖

១- រឿងពិម្ពានិព្វាន, ២ រឿងសាមកុក, ៣- រឿងទាវឯក, ៤- បកិណ្ណកកថាគោរព៧ប្រការ, ៥-រឿងមហាសុបស្សីតា-បស, ៦-រឿងឥណារ, ៧-រឿងគុនឈីន, រឿងសុមុទជេដ្ឋា ៗ

តទៅនេះ យើងសូមដកស្រង់សេចក្តីមួយពីក្នុងរឿងទាវឯករបស់លោក ដែលលោកបានសរសេរឡើងទទួលរង្វាន់លេខ ១ ក្នុងការប្រឡងប្រជែងអក្សរសាស្ត្រ គ.ស.១៩៤៤ ដែលលោករៀបជាកំណាព្យពាក្យ ៨ ជូនរណ្តំដូចតទៅ ៖

... លោកនេនទុំពុំធ្លុសទេសន៍បទស្មូត
តរហូតផុតរឿងអ្នកផងឮ
ចេញអស់ថែបលៃបខាយសាយរន្ធី
នោះក៏គឺអាគមផ្សំរេហារ ៗ
ស្រីប្រុសខ្លះក្រាស់កាមជាមប្រឡាក់

គិតតែស្ទុំត្រដាក់ដល់វល់ចិន្តា
នឹកឃើញរឿងក្នុងខ្លួនមានសង្សារ
ពីកាលណានិពសប្រាសទីទៃ ៗ
ខ្លះក៏ព្រាសតាំងរស់ខ្លះព្រាស់ស្លាប់
លុះមកស្ដាប់សព្ទសត្វកើតរងារ
នឹកដល់ដើមកំសត់មិត្តមាសមៃ
ផ្ដួតហឫទ័យន័យនទឹងស្រក់ទឹកនេត្រ ។
ខ្លះអាល័យអាឡោះស្រណោះផ្សេង
ដោយសំឡេងអន្ទុងរងសម្ដេច
ដូចជាដើរក្នុងព្រៃឆ្ងាយទូរេត
ពេលសូរិយេតសាយណ្ហាទន់ត្រដាក់ ៗ
ខ្លះពោះម៉ាយស្ដាយមិត្តគិតខ្មោចនាង
ឯមេម៉ាយស្ដាយកងរូបខ្មោចអ្នក
តាអះណោបខ្មោចយាយកយមាយភ្ញាក់
យាយពាំរញាក់នឹកខ្មោចដល់ខ្មោចតា ៗ

សំនួនពោហាររបស់លោកកវីនេះ ដែលយើងស្រង់ម
ខាងលើនេះ ដំណាលកាលអ្នកស្រុកទាំងប្រុសស្រីអន្ទុយស្តា
នេនទុំស្បូតក័ណ្ឌមទ្រី ត្រង់ដែលនាងមទ្រីលាព្រះវេស្សន្ត
ទៅក្នុងព្រៃ ហើយព្រាហ្មណ៍ជូជកមកសុំយកបុត្រទាំងគូទេ
កយបណ្ដើរតាមផ្លូវ ។ នេនទុំប្រសប់នេបន្ទូនសំឡេងទេ
តាមការសោកសង្រេងរបស់កុមារទាំងពីរ នាំឲ្យអ្នកស្ដាប់អ
ទ្រាំមិនបាន ក៏នឹកគិតលន្ទង់ចិត្តតែរៀងខ្លួន ។ លោកប
កេយសំដីឈាយដោយការកំប្លែងផង ។

## លោក បាន _ តេង

លោក បាន - តេង កើតនៅសង្កាត់លេខ ៤ ក្រុងភ្នំពេញ
មាតាឈ្មោះ ត្រយង់, បិតាឈ្មោះ បាន ជាមន្ត្រីនៅក្នុងព្រះប
ពជវាំង ។ លោកកើតពីឆ្នាំ ១៨៨២ ។ កាលពីកុមា
មាតា - បិតាបានយកទៅឲ្យរៀនសាលាពជការ លុះអាយ
បាន ១៤ ឆ្នាំ ក៏បានចូលផ្នួសជាសាមណេរក្នុងសំណាក់សម្ដ

ះមង្គល អៀម វត្តបទុមវតី បានមួយវស្សាក៏សឹកមកវិញ ។
ោកបានរៀនរបៀបតែងកាព្យខ្មែរ ពីលោកព្រះគ្រូវិយរក្ខិត
ាត វត្តសុគន្ធមានបុណ្យ (ឧគ្គ) ហើយលោកបានបន្ថែម
ានេះក្នុងសំណាក់លោកឧកញ៉ាសុត្តន្តប្រីជា - ឥន្ទ ទៀត ។
ហេតុនេះហើយបានជាលោក បាន · តែង ចេះយ៉ាងស្ទាត់ពី
បៀបតែងកាព្យ ។ ក្រោយពីនោះ លោកបានចូលធ្វើការ
ៅក្នុងព្រះបរមរាជវាំង បន្ទាប់មកទៀតធ្វើជាលេខាធិការនៅ
ន្ទីរឃ្លាំងប្រាក់ ។ លុះដល់ គ.ស. ១៩២១ រាជការបាន
ត់លោកឲ្យទៅធ្វើជាគ្រូបង្រៀននៅកោះកុងអស់រយៈ ៥ ឆ្នាំ
ើយលោកបានត្រឡប់ មកបង្រៀន នៅសាលាវត្ត ស្វាយ
ាព ក្រុងភ្នំពេញវិញ ។ លុះក្រោយមក លោកបានចូល
កធ្វើការនៅក្នុងក្រសួងសិក្សាធិការ ក្នុងក្រុមតែងសៀវភៅ
ពប់សិក្សា ។ ហេតុនេះឯង ទើបយើងឃើញស្នាដៃលោក
ច្រើននៅក្នុងមេសូត្រ នឹងមេរៀនផ្សេងៗ ដែលសុទ្ធតែធ្វើ
ពាក្យកាព្យយ៉ាងងាយស្តាប់ ។ លោកបានទទួលអនិច្ច-

កម្ម ពី គ.ស.១៩៥០ ប៉ុន្តែក្នុងពេលដែលរៀបចំងដល់ចុ
បំផុតរបស់លោកនេះ, លោកហ៊ាន-គេង នៅត្រៀតប្រ
រួមក្នុងគណៈកម្មការ តែងសៀវភៅមូលវិជ្ជាសំរាប់ថ្នាក់មធ្យម
ដ្ឋានបានពីក្បាលទៀត ។ ត្រង់នេះបង្ហាញឲ្យឃើញថាលោ
ហ៊ាន-គេង ជាអ្នកយកចិត្តទុកដាក់ណាស់ចំពោះអក្សរសាស្រ្ត
យើង, ព្រោះបីជាជរាណាស់ទៅហើយ ក៏លោកនៅតែប្រឹ
បំរើអក្សរសាស្ត្ររហូតដល់ទីអវសាន ។

ក្រោយដែលលោកអនិច្ចកម្មទៅ គេរកឃើញស្នាដៃ
លោកដែលបោះពុម្ពហើយខ្លះ មិនទាន់បោះខ្លះ មានជាប្រ
ដូចរាប់ខាងក្រោមនេះ ៖

១– សប្បុរសធម៌, ២– ទុកខនារី, ៣– លោ
ធម្មចរិយា, ៤– រឿងធន្ទុត, ៥– រឿងខានហ្វានជា
៦– រឿងទិព្វសង្ក្រា (មិនមែនទិព្វសង្ក្រាដែលបោះពុម្ពទេ)

ខាងក្រោមនេះ យើងដកស្រង់ស្នាដៃលោកមកធ្វើជាស
ភាពដូចតទៅ ៖

.... មនុស្សយើងនេះ ត្តមហៅយកំណើត
មិនមែនកើតមកក្លាមក៏ខូចជា
លុះប្រូបល់ចូលជាមជាតពាលា
ខូចខិនជាគោនស្អិតចិត្តអស់ស្អាត ។
បុគ្គលបាបផ្លាទមានកន្ទុនអត្ត
ហោតកោកូនសត្វសេកជាអាចិ
កាលញាស់ទៀនដំបូងគ្មានខ្វះខាត
ចិត្តក៏ស្អាតបរិសុទ្ធល់តយោរយៅ ។
លុះខ្យល់បក់ឆក់បាត់សាត់តាកទី
ក៏ព្រាត់ពីសំបុកបែកគ្នាទៅ
សេកមួយនោះជ្រុះធ្លាក់លើលំនៅ
ព្រះតាបសរើសទៅថែរក្សា ។
សេកមួយទៀតកាត់ផាត់សាត់ទៅដល់
ទីមណ្ឌលសំណាក់ពួកចោរ
ចោរក៏រើសយកទៅដោយមេត្តា

ថ្នមរក្សាផតល្អថែទាំទុក ។

សេកដែលនៅសំណាក់ព្រះតាបស

ចិត្តសប្បាយសេកផលខ្វល់ចង់សុខ

បានសន្សំសុចរិតបិទផ្លូវទុក្ខ

ព្រោះតាំងមុខតាមមគ្គលោកអ្នកប្រាជ្ញ ។

សេកដែលនៅទីចោរចិត្តអាក្រក់

រៀនតែឆក់ខឹងលួចប្លន់ក្រកាច

ចេះចិលខ្លួនឲ្យជួបចោរកំណាច

គ្មានគន្ធាបឥតគិតជីវិតក្ស័យ

ចូរមើលចុះតែសត្វជាតិតិរច្ឆាន

បើគប់ពាលមិនមានខ្លួនវិស្ស័យ ។

បើគប់ប្រាជ្ញ ៗ ប្រៀនព្រះធម៌ថ្លៃ

អធ្យាស្រ័យប្រែតាមស្នាមនោះហោង ។

កណាព្យាងនេះ លោកបាន-គេងលើកបង្ហា

យើងពីការគប់មិត្ត តើអាចឲ្យផលយើងយ៉ាងណា ។ ល

បីកយករឿងកូនសេកចាំងពីរមកធ្វើជាគ្រឿងបញ្ជាក់ ឲ្យ
បើងឆាយយល់ផង ។

## អ្នកស្រី សិទ្ធ

នៅចុងសម័យនោះ យើងបានជួបប្រទះអ្នកនិពន្ធស្ត្រីមួយ
ដែលទុកកេរ្តិ៍ស្នាដៃចំណានណាស់ដែរ គឺអ្នកស្រី-សិទ្ធ ។
កស្រីសិទ្ធ យើងអាចទទួលស្គាល់ថាមានតែស្ត្រីនេះមួយទេ
វលបានបញ្ចេញនូវស្នាដៃខាងអក្សរសាស្ត្រជាដំបូងគេបំផុត
ងចំណោមស្ត្រីខ្មែរនៅសតវត្សយើងនេះ ។ អ្នកស្រីបាន
ះស្ទាត់ខាងភាសាសៀមនឹងភាសាខ្មែរ ហើយបានចេះរបៀប
ងកាព្យខ្មែរ យ៉ាងម៉ត់ចត់ត្រឹមត្រូវណាស់ដែរ ។ ចំណែក
ៀបពាក្យពេយធម្មតាវិញ យើងឃើញថាអ្នកស្រីក៏មានថ្វីដៃ
ណានដែរ ។ ហេតុនេះហើយ ទើបគេឃើញស្នាដៃ
របស់អ្នកស្រីមានជាពាក្យកាព្យខ្លះ ជាពាក្យពេយខ្លះ ដែល
បើងកប់រៀបឈ្មោះខាងក្រោមនេះគឺ ៖ ១– រឿងពិម្ពាពិលាប,
– រឿងគូសាងមិត្តមិនទ្រុស្តមិត្ត, ៣– រឿងចិត្តសត្យា ។

យើងសូមបង្ហាញអស់លោកអ្នក នូវស្នាដៃរបស់អ្នក

ដែលយើងដកស្រង់កំណាព្យមួយវគ្គ ពីក្នុងរឿងពិម្ពាពិលាប

"... ថ្វីបើនាងខឹងប្រឹងស្រែកជេរ
មិនទេមិនទើងខឹងសោះឡើយ
ប្ដីនាងត្រូវសរស្លាប់ទៅហើយ
នាងអើយគឺកម្មនាំសរទៅ ។
ចិត្តបងគ្មានប៉ងនឹងប្រមាថ
តែប្រញាប់ផ្ទាតខ្ទាតទៅត្រូវ
បងបាញ់សត្វសោះចុះឥឡូវ
ស្រីពៅនៅថ្វីព្រៃព្រឹក្សា ។
យំសោករកប្ដីអាល័យរស់
គឺមានខឹងបានប្រាណស្នេហា
នេះទៅជាខ្មោចខ្ចបអសារ
សោកាធ្វើអ្វី [illegible] តាមបង ។

បង់នេះជាស្ដេចសោយរាជជ្លេ
នាមព្រះព្រហ្មទត្តសោយរាជ្យផង
មានទាំងប្រាសាទស្អាតកខ្ពង់
ជាច្បងលើសលប់កតមនុស្ស ។
ពុំទាន់មានគូមកយូរឆ្នាំ
ជាកម្មនាំបងឲ្យយាត្រា
កម្មបងប៉ងបាញ់សត្វសកុណា
កម្មស្វាមីប្អូនប្រជួនគ្រោះ ។
កាំសរប្រហារដីរ៉ាក្សេ
កម្មបងអាល័យស្រីសមយស
កម្មប្អូនឲ្យក្ដៅសៅហ្មងមោះ
កម្មប្ដីអស់សស់ហើយមាសថ្លៃ ។

សេចក្ដីដកស្រង់ខាងលើ អ្នកស្រីសិទ្ធ និទានកាល សត្វកិន្នរញី-ឈ្មោល បណ្ដើរគ្នាកណ្ដាលព្រៃ, ព្រះបាទព្រហ្មទត្តបានលបបាញ់កិន្នរ ហើយចូលទៅប្រលោមលួង

លោមនាងកិន្នរីដោយពាក្យផ្អែមល្ហែម ដើម្បីឲ្យនាងទន់ចិ
ស្នេហា ហើយឲ្យនាងលះចិត្តស្រឡះពីខ្មោចស្វាមី ដែល
ប្រដួនគ្រោះត្រូវសរស្លាប់ទៅហើយ ។

នៅភាគខាងចុងនៃសម័យនេះ យើងឃើញការចំរើ
លូតលាស់មួយយ៉ាង គួរឲ្យសរសើរណាស់ដែរ គឺការបង្កើ
ឲ្យមានពុម្ពអក្សរខ្មែរ សម្រាប់បោះពុម្ពផ្សាយសៀវភៅឲ្យបា
ច្រើនក្បាល ។ វចនានុក្រមយើងក៏កើតឡើងក្នុងគ្រានោ
ដែរ ។ ដែលយើងអាចកប់បានថាជាការលូតលាស់គោល
ចារឹកច្បាប់ទម្លាប់មួយខាងអក្សរសាស្ត្រ និង ភាសាជា
យើង ។ សៀវភៅជាច្រើនក៏បានបោះពុម្ពចេញផ្សាយបន្ត
គ្នា ប៉ុន្តែជំនាន់នោះ យើងឃើញច្រើនតែជាសៀវភៅធ
អាថ៌ និងច្បាប់បុរាណខ្លះៗ ប៉ុណ្ណោះ ឯរឿងប្រលោមលោ
និងសៀវភៅនិយាយពីការស្រាវជ្រាវ មិនសូវឃើញមា
បោះពុម្ពផ្សាយទេ ។ ឯសៀវភៅដែលចេញផ្សាយតាំ

នោះសោត សុទ្ធតែត្រូវសុំអនុញ្ញាតពីរាជការអាណាព្យាបាល ថែមទៀតផង ។ ហេតុនេះហើយ ទើបសៀវភៅណាដែលជាគ្រឿងណែនាំឬដាស់តឿនចិត្តគ្នាយើង មិនអាចនឹងចេញផ្សាយបានតាមចិត្តឡើយ ។

បើយើងធ្វើការសង្កេតចំពោះប្រលោមលោកខ្មែរសម័យនោះវិញ យើងនឹងឃើញថា ៖ ប្រលោមលោកខ្លះៗ នោះមានរបៀបសរសេរប្លែកពីសម័យមុនៗ សន្ធឹកណាស់ គឺគេសរសេរជាពាក្យរាយកប់ៗ ដូចជាពាក្យដែលអ្នកស្រុកធ្លាប់និយាយគ្នារាល់ថ្ងៃ នាំឲ្យអ្នកអានងាយយល់ងាយគិតជាជាងស្នាដៃពីមុនមក ។ មួយទៀត ក្នុងរឿងទាំងនោះ ក៏ឈប់មានប្រើមន្តអាគមដូចជាគ្រាមុនៗ ទៀតហើយ , អ្នកនិពន្ធសុទ្ធតែត្រិះរិះ រចនាស្នាដៃខ្លួន ឲ្យស្របទៅតាមការចំរើនលូតលាស់នៃសាកលលោកសម័យថ្មី ។ ហេតុដែលនាំឲ្យកើតដុះដាលរឿងប្រលោមលោកទំនើបជាបន្ត ៗ គ្នាក្នុងគ្រានោះ ព្រោះរាជការបានបង្កើតជាការប្រឡងប្រជែងខាងអក្សរ-

សាស្ត្រជាញឹកញាប់ព្រមទាំងឲ្យឆ្ងាន់យ៉ាំងគាប់គួរ ដល់ម្ចាស់ស្នាដៃណាដែលជាប់លេខផង ៗ ហើយស្នាដៃដែលល្អ ៗ ពោះជាប់លេខក្តី មិនជាប់ក្តី ឲ្យតែគណៈកម្មការមានសេចក្តីសរសើរ, ត្រូវគេយកទៅចុះផ្សាយនៅក្នុងសារពត៌មានកម្ពុជា ដែលជាទិនានុប្បវត្តិ មួយចេញផ្សាយជាយូរអង្វែងណាស់មក ហើយ ៗ ដូច្នេះឯងទើបបណ្តាជនទូទៅនាំគ្នាគ្រប់ជញ្ជួក នូវរសជាតិអក្សរសាស្ត្រទាំងនោះ បានជូរស្រួលជាជាងលើកមុន ៗ ព្រោះមានប្រាកដជាអក្សរពុម្ពយ៉ាំងស្អាត ៗ មានរឿងមួយចំនួនទៀត ត្រូវបានចេញផ្សាយតាមរយៈការផ្សាយរបស់ក្រុមពុទ្ធសាសនបណ្ឌិត្យ គឺដូចកាលក៏ហោះដោយឡែក ាមួយសៀវភៅ ទីនខ្លះទៀតផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយា ដែលជាទស្សនាវដ្តីមួយមានអាយុជាង ៣០ ឆ្នាំមកហើយ ។ ទស្សនាវដ្តីនេះ ជាអង្គការយ៉ាំងចំណានជួយស្ទួយទ្រនូវពុទ្ធសាសនានិងអក្សរសាស្ត្រខ្មែរ ឲ្យកាន់តែមានរស្មីព្រាលរន្ទាលទៅគ្រប់ទិសទីក្នុងព្រះរាជាណាចក្រ ។ យើងសូមទៀត

ឱកាសជាពិសេស សរសើរដល់សន្ដានចិត្ត អស់លោកដែល
ប្រឹងប្រែងផ្ដួចផ្ដើមឲ្យកើតជាទស្សនាវដ្ដីនេះឡើង ។ ប្រសើរ
សំខាន់មួយផ្នែកទៀត គឺអស់លោកអ្នកនិពន្ធដែលប្រឹងប្រែង
សរសេរជារឿងក៏ដី ស្រាវជ្រាវការ្យធម៌ខ្មែរបុរាណមកផ្សាយ
ទុកជាគោលចារឹកក្នុងទីនោះ សំរាប់ឲ្យកូនខ្មែរ ស្នេហាវប្បធម៌
ជាតិ ការគេឃើញជានក្ដីដំណែលដូនតារបស់ខ្លួនយ៉ាងជាក់
ច្បាស់ ។ ពោះជាមានអាយុ ៣០ ឆ្នាំមកហើយក្ដី ទស្សនាវដ្ដី
នេះ ឥតប្រាសចាកពីគោលដើមដែលធ្លាប់មានមកនោះឡើយ
គឺនៅតែមានអត្ថបទជាខ្លឹមសារល្អរហូតសព្វថ្ងៃនេះ ។ ដូច្នេះ
ទស្សនាវដ្ដីកម្ពុជសុរិយា គួររាប់ថា ជាឯកសារមួយយ៉ាងវិ-
សេសសម្រាប់អ្នកត្រូវការរៀនសូត្រ ឬស្រាវជ្រាវពីការ្យធម៌
ខ្មែរ ជាពិសេសខាងផ្លូវវប្បធម៌ ។

ក្រៅពីការផ្សាយតាមរយៈរាជការ ឬ តាមវិធីជាផ្លូវការ
ដូចមានរៀបរាប់ខាងលើនេះ យើងបានប្រទះឃើញមានអ្នក
និពន្ធលាក់មុខជាច្រើនទៀត ដែលបានរៀបរៀងជាកំណាព្យ

ខ្ទីៗ សំកប់ជាសំគៀនគ្គីគ្គាខាងផ្លូវចិត្ត ឲ្យបេះទឹកឃើញផល់ បញ្ហាជាតិដែលស្ថិតនៅក្នុងអាណាព្យាបាលរបស់បរទេស ៗ ខ្លះទៀតនិយាយពីអនុស្សាវរីយ៍ ក្នុងគ្រាដែលកើតវិប្បរិតដោយសារជនបរទេសចូលមកត្រួតត្រាក្នុងប្រទេសយើង ៗ ដោយមានយោបល់ផ្ទុយពីរជការអាណាព្យាបាល ដូចនេះហើយ, ទើបអ្នកនិពន្ធទាំងនោះ មិនហ៊ានបញ្ចេញឈ្មោះឲ្យគេស្គាល់ឡើយ មានត្រឹមតែបទនមស្សការនឹងកាលបរិច្ឆេទដែលរៀបរៀងប៉ុណ្ណោះ ៗ ដើម្បីជាសក្ខីភាពចំពោះសន្ទានចិត្តខ្មែរខាងផ្នែកអក្សរសាស្ត្រក្នុងពេលនោះ យើងសូមស្រង់សេចក្តីបន្តិចពីក្នុងកំណាព្យទាំងនោះមកបញ្ជាក់ជូនតទៅ ៖

“... ខ្ញុំនឹងតាក់តែងសេចក្តី
ពិភពផែនដីកម្ពុជា
ប្រែប្រួលរំជួលក្នុងសាសនា
អស្ចារ្យកោលាហលកើតវិករ ៗ
សត្វថ្ងូរមេទ័ពគេជាធំ

គេមករៀបចំក្នុងនគរ
មានប៉ុស្តិ៍គ្រប់ខេត្តគេត្រួតឈរ
គេរៀបនគរបំរុងតាំង ៗ
តម្រូវត្រូវគេមានឫទ្ធិក្លា
ត្រួតត្រាកដការចិត្តមួនមាំ
លើកថ្កល់ខ្វាត់ខ្វែងវែងវង់ជុំ
បុណ្យគេជាធំក្នុងរដ្ឋា ៗ
តាំងមន្ត្រីស្ត្រុពេញនគរ
សត្វថ្ងៃខ្លាបគេដូចជាខ្លា
តែគេបង់ឲ្យទៅត្រង់ណា
មុខជាលោយត្រង់នោះឯង ៗ
ហៃអ្នកតាំងឲ្យយចូលអ្នកគិត
ស្មាគេគំនិតក្រែងរង្វង
កុំធ្វើផ្តេសផ្តាសតាំងតាស់ក្មេង
ប្រុងប្រែងគំនិតគិតកល់គ្នា ៗ

កំណាព្យនេះយើងស្រង់ចេញពីសាស្ត្រាស្លឹករឹតមួយមាន ចំណងជើងថា ‹‹ល្បើកកម្ពុជា›› ។ នៅក្នុងសាស្ត្រានេះ អ្នកនិពន្ធបានលាតត្រដាងហេតុការណ៍ផ្សេង ៗ ដែលកើតមាន ក្នុងគ្រានោះ ព្រមទាំងពោលនូវពាក្យដាស់តឿនដល់ជនរួម ជាតិគ្រប់គ្នា ឲ្យចេះថែរក្សាចិត្តគំនិតស្រឡាញ់ជាតិនិងថែរក្សា នូវប្រពៃណីជាកេរ្តិ៍ដំណែលរបស់ជាតិពីបូរមបូរាណ ។ តែ អ្នកនិពន្ធនេះឥតបញ្ចេញឈ្មោះឲ្យយើងស្គាល់ទេ ប្រហែល លោកខ្លាចមានឧបសគ្គអ្វីមកដល់រូបលោកទេដឹង ? ទោះបី ជាលាក់លៀមយ៉ាងណាក៏ដោយ សាស្ត្រានេះបានត្រូវ បណ្ដាជននិយមណាស់ដែរ គេចម្លងចែកគ្នាមើលនៅតាម វត្តអារាមជាច្រើន សព្វថ្ងៃនេះមានគង់នូវច្បាប់ដើមយ៉ាង ល្អស្អាតដម្កល់នៅក្នុងបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ។

ក្រៅពីសាស្ត្រា ដែលដូចប្រគេទពប់មកខាងលើនេះ យើងបានប្រទះឃើញនូវកំណាព្យដាស់តឿនជាតិឲ្យខំប្រព្រឹត្ត ខ្លួនក្នុងការជីវកម្មថែមទៀត ។ ជាពិសេសបំផុតគឺស្នាដៃរបស់

្នកព្រះភិរម្យភាសា - អ៊ូ ឬ ក្រមង៉ុយ ដែលជាកវីសាមញ្ញមួយ
ានគំនិតវែងឆ្ងាយគួរយើងលើកយកមកធ្វើការសិក្សាបាន ។

## ព្រះភិរម្យភាសាអ៊ូ ឬ ក្រមង៉ុយ

មុននឹងពិនិត្យនូវស្នាដៃសំខាន់ៗ យើងសូមណែនាំអស់
ហាក់អ្នកជ្រាបបន្តិចពីជីវប្រវត្តិរបស់លោក ។ លោកតាង៉ុយ
ានកើតនៅ នៅឃុំកំបូល ( ខេត្តកណ្ដាល ) លោកជាកវី
ាមញ្ញមួយរូបក្នុងសម័យអាណាព្យាបាល ។ កំណាព្យ
ព្យឃ្លោង ដែលលោកបានរៀនសូត្រហ្វឹងហ្វាត់នេះហើយ
ានធ្វើឲ្យលោកទៅជាអ្នកចម្រៀងមួយយ៉ាងឯក ដែលជូន
ៅក្នុងព្រះរាជាណាចក្រនិយមគោរពរាប់អានគ្រប់ៗគ្នា ។
ពន៍របស់លោក បង្ហាញថាជាអ្នកមានសុខភាពបរិបូណ៌
ាយលោកមានមាឌមាំដុះពោះល្មម នឹងសំឡេងឮក្រអៅ
ោលោកមានដំណើរទៅណាមកណា លោកតែងស្លៀកសំពត់
ាក្បៀន ពាក់អាវចិន នឹងស្ពាយបង្វិចតូចមួយ ដៃកាន់ដំបង
យ៉ប្រាក់រលោងស្រិល ។ ពេលណាលោកត្រូវការច្រៀង,

លោកតាញបន្ទុបមក ស្រាយយកសបកឃ្មោកជាតួសាជ្
មកដំឡើងផ្គុំជាមួយឈើប្រគតាត់ធ្វើជាដុន រួចដាក់ខ្សែរ
ឲ្យតឹងល្មម ទើបដាក់ផ្ទប់នឹងក្បាលពោះ គាត់ដេញរទេ្ទនប
បង្កើតជាសូរយ៉ាងពិរោះ ផ្សំជាមួយសព្ទពោហារដែលលោ
ស្រែកច្រៀងឡើង ៗ បម្រៀនតាំងនោះសោត មិនមែ
និយាយតែពីរឿងកំរ៉ែអណ្តែតអណ្តូងទេ គឺលោកកវីយើ
បានបញ្ចូលនូវពាក្យដាស់តឿន ក្រើនរំលឹក ដល់ជនរួមជាតិឲ្
ខំរកស៊ីធ្វើការកុំទំរេទ់ដេកចាំសំណាង, ខំរៀនសូត្រខាងរប
ពាណិជ្ជកម្មកុំឲ្យជនបរទេសរំលោភបាន, ខំរៀនសូត្ររក្ស
សាស្ត្រ ទីង លេខនព្វន្ត កុំឲ្យពិបាកដើរពឹងគេឯងឲ្យធ្វើជួ
ខ្លួន ៗ ជាពិសេស កវីនេះ ចូលចិត្តដាស់តឿនពួ
កសិករឲ្យខំនាំគ្នាបង្កើនផល ហើយនឹងរក្សាសេចក្តីសុ
រៀបរយកុំឲ្យមានរឿងតាស់ទែងនឹងគ្នាផង ៗ គោលបំណ
របស់លោកដូចមានពប់រៀបមកខាងលើនេះ បង្ហាញឲ្យឃើញ
ថា ឧត្តមគតិរបស់លោកក្នុងគ្រានោះ ដាក់ជាអ្នកជួយណែន

បន្ទានចិត្តជនរួមជាតិ ឲ្យបេះក្សាត់លើកលើការផ្សារប្រចាំខ្លួន ឡើង ៗ ព្រោះលោកឃើញថា ៖ ភាសារបស់ជាតិយើង ក្នុងពេលនោះមានស្ថានភាពដុនដាប ជាងយើងសព្វថ្ងៃនេះ ច្រើនណាស់ ៗ មិនតែប៉ុណ្ណោះច្បាប់ទូន្មានរបស់លោកបាន ជួយបំប៉ន ខាងផ្នែកអក្សរសាស្ត្រយើង យ៉ាងសំខាន់ណាស់ ព្រោះបានជាគ្រឿងចុះមើលការចំរើនរុងរឿង របស់អក្សរ-សាស្ត្រ និង ជីវភាពជនសាមញ្ញក្នុងសម័យនោះ យ៉ាងជាក់ប្រាកដ ៗ

បន្តទៅនេះ យើងស្រង់យកកំណាព្យក្នុងស្នាដៃលោក មកលាតត្រដាងដូចតទៅ ៖

«...សំអាតផ្ចិតផ្ចង់ លើកក្តីឲ្យត្រង់ កុំលើកឲ្យកោង អ្នកកុំប្រហែស ក្រែងមានប្រហោង លើកមើលទំនង ទំនាបទឹកហូរ ៗ ចំនួនទឹកស្ទឹង ទឹកព្រែកទឹកបឹង ទឹកកលទឹកអូរ អ្នកលើលិចស្រូវ ត្រូវបើកបង្ហូរ អ្នកក្រោមកុំថ្ងូរ បន្ទោសហួសទៅ ៗ កំផែងថ្ងៃយប់ ធាប់លើកធាប់

« ទប់ កុំឲ្យបាក់ជ្រៅ កក្តិកចេញខ្យល់ ដក់កល់ទឹកនេ
« បើចង់បានស្រូវ ស្រេចនូវត្រឹមថៃ ៗ កុំយកគ្រាប់គ្ន
« ទៅដាំទៅដោត ពីលើក្តីស្រែ ចិត្តគិតប្រមាណ ចង់បាន
« ផ្កាផ្លែ ដាំដុះបន្លែ បន្លិនខ្លួនឯង ៗ ដល់គ្នាគេឡើងគ.
« ឡើងកើតនាំខ្វល់ ឆាងល្បួតឡើងវែង ក្ដូរពស់ជាប់នឹ
« គ្របីជាប់ស្មួន ទទើសទទែង ក្ដូរឆ្លងមិនត្រូវ
« ដល់គ្នាតវាធំ វាមានស៊ីកន្ទុំ ធ្លាក់ជ្រុះក្នុងស្រូវ ស្រែឆ្ងាយ
« ពីផ្ទះ ឃ្លាតណាស់ពីផ្លូវ ទំពាំតែទៅ រលួយស្រូវអស់
« កូនអើយកុំធោត បើចង់បានគ្នាត ដាំដោយកៀនកោ
« ដីទួលចំការ ឯណាចន្ទោះ ដាំដារបោះ ជាយផ្លូវបង ៗ...»

កំណាព្យខាងលើនេះ លោកតា នុ៉យ បានប្រដៅកូន
ចៅនៅស្រុកស្រែឲ្យចេះរៀបចំភ្ជួរស្រែរបស់ខ្លួន ទាំងចេះយល
អធ្យាស្រ័យគ្នាក្នុងការធ្វើស្រែផង ៗ ជាពិសេសលោកផ្ដ
ថាកុំឲ្យដាំគ្នាតនៅតាមវាលស្រែ ព្រោះនាំឲ្យធ្លាក់ស៊ីកឆា
ទៅបំផ្លាញដល់ស្រូវដែលដុះក្នុងស្រែ ៗ ដំបូន្មានរបស់លោ

ំវែងឆ្ងាយនោះ  យើងសង្កេតទៅពុំឃើញមានប្រដៅអ្វីផ្សេង
ាំរឿងរបរគេស៊ីរបស់អ្នកស្រុកសាមញ្ញាឡើយ  គឺលោកដោះ
ស្រាយរឿងកយរង  ដែលជនអ្នកស្រែអ្នកចំការធ្លាប់ជួបប្រទះ
រៀងរាល់ថ្ងៃ ៗ  ត្រង់នេះហើយដែលយើងសន្មតថាលោក
វី នុ៉យ ជាកវីសាមញ្ញមួយរូបរបស់ខ្មែរយើងទៀតលោកប្រកប
ាជីវកម្មជាអ្នកស្រែចំការធម្មតា ៗ





## ជំពូកទីដប់

# អក្សរសាស្ត្រសម័យបច្ចុប្បន្ន

ដែលហៅថាសម័យបច្ចុប្បន្ននេះ គឺកប់តាំងពី គ.ស ១៩៤៩ (១) ដែលប្រទេសយើងបាន រំដោះខ្លួន ពីអាណាព្យា បាលរបស់បរទេសខាងផ្នែកវប្បធម៌ ៗ ប៉ុន្តែពេលដើមដំបូ នៃសម័យនេះ អក្សរសាស្ត្រខ្មែរ នៅមិនទាន់លេចត្រដែតសុ សាយនៅឡើយទេ ដ្បិតគ្រានោះពិភពលោកទើបតែបានផុ ពីសង្គ្រាមថ្មី ៗ ដូច្នេះប្រទេសយើង នៅខ្វះសម្ភារៈ ដែលជ មធ្យោបាយខាងការផ្សាយអក្សរសាស្ត្រយើង ដូចជាទ្រ ក្រដាសបោះពុម្ព, ខ្វះគ្រឿងបក្រពុម្ព និងអក្សរពុម្ពជាដើម

---

១– ឆ្នាំនេះ មិនទាន់បានឯករាជ្យសម្បូណ៌នៅឡើយទេ រហូតមកដល់ ថ្ងៃទី ៩ វិច្ឆិកា ១៩៥៣ ទើបបានឯករាជ្យបរិបូណ៌ ។ តែពេលនោះបាន បានផ្ទេរវិទ្យាល័យ-អនុវិទ្យាល័យ និងសាលាបាលីមកជាការខ្មែរ ។

ង៉ទៀតមកពីពេលនោះ ស្មារតីយើងទើបតែងើបរួចពីការគ្រប
ណ្តាប់នៃវប្បធម៌គេថ្មី ៗ ។ តែពពួកអ្នកដែលធ្លាប់ចិញ្ចឹមចិត្ត
សានអក្សរសាស្ត្រវិញមិនព្រមចុះញ៉មឧបសគ្គទាំងនេះឡើយ
គនាំគ្នាប្រឹងប្រែងចងក្រង ឬរៀបរៀងជាសៀវភៅរឿងរ៉ាវ
មើលកំសាន្ត ឬក៏ក្បួនខ្នាតអ្វីផ្សេងៗតាមតែសន្ដានចិត្ត ឬស្មារតី
គដែលដក់ជាប់មកយូរហើយ ។ សិទ្ធិខាងការផ្សាយក៏បើក
ានយ៉ាងបរិបូណ៌ ជាពិសេសគឺសិទ្ធិយ៉ាងទូលាយក្នុងរដ្ឋ-
ម្មនុញ្ញនៃព្រះរាជាណាចក្រ ដែលព្រះករុណាជាម្ចាស់ជីវិត
លើត្បូងព្រះបាទសម្តេចព្រះ នរោត្តម-សីហនុ បានទ្រង់
ប្រោសព្រះរាជទាន ដល់ពលរដ្ឋជាទីសព្វព្រះរាជហឫទ័យ
បស់ព្រះអង្គកាលពីឆ្នាំ១៩៤៧ ។ សិទ្ធិទាំងនេះបានជួយបណ្តុះ
ណ្តាលផ្លូវចិត្តឲ្យអ្នកស្នេហាអក្សរសាស្ត្រទាំងប៉ុន្មាន នាំគ្នា
ានសង្ឃឹមកាន់តែខ្លាំងឡើងក៏ខំខ្នះខ្នែងលើសពីពេលមុន ។
ទៅ ជួនជាពេលបន្ទាប់នោះ ប្រទេសយើងក៏បានចំរើនគ្រប់
ៀឡើងផង គឺសម្ភារៈដែលយើងខ្វះខាតកាលពីមុននោះ

កំមានគ្រប់គ្រាន់ឡើង ៗ អក្សរសាស្ត្រខ្មែរខាងផ្នែករឿងរ
ក៏ល្អគួរលាស់ត្រចះត្រចង់យ៉ាងស្រោងស្រាងឡើង ប្រៀបបីដូ
រុក្ខជាតិដែលលាស់ស្លឹកខ្ចីល្អក់ ក្នុងគ្រាដែលមានព្រះពិរុណ
បង្អុរស្រុះស្រប់មកលើជាដំបូង ៗ តែអនិច្ចា ! កម្ភាស្ល
ពន្លកខ្ចីតែងពុំទាន់មានសភាពរឹងមាំមួនទៅឡើយទេ, ស្លឹកឈ
ទន់ហើយពុំមានសណ្ឋានពេញលក្ខណៈ ជាស្លឹកពិតប្រាក
នៅឡើយ ៗ ដូនកលៃនៅស្អាក់ស្ទើរពុំទាន់ពេញជ្រុងជ្រោយ
ដូនកាលអាចនឹងមានអន្តរាយដោយសារសត្វល្អិតបើកាលណ
ហើយអ្នកថែរក្សានោះមិនថែឲ្យដិតដល់មែនទែន ៗ

សេចក្ដីប្រៀបធៀបនេះយ៉ាងណា ក៏សមនាអក្សរសាស្រ
យើងសម័យនេះក៏យ៉ាងនោះដែរ ៗ ពិតមែនហើយ ដែលយើ
ឃើញរូបរាងសៀវភៅខ្មែរ បោះពុម្ពផ្សាយជាច្រើនក្រៃលែ
ស៊ីនតែប្រៀបផ្ទឹមបាននឹងបរទេស ដែលចំរើនខាងផ្នែកឯ
ជាយូរមកហើយដែរ ៗ ប៉ុន្តែយើងដឹងជាក់ដូច ៗ ឧទាហរណ៍ខា
លើថា ៖ ស្នាដៃទាំងនេះមិនសុទ្ធតែល្អគ្រាល់ឬសមមៀត

ទោះតាំងអស់ទេ, មានខ្លះទៅក៏ល្មមកប់យកជាការបាន ចឹង មានខ្លះទៀតដែលពុំអាចលើកយកជាគោលបានឡើយ ។ ត្រង់នេះ ដោយសារតែយោលទៅតាមទឹកដៃរបស់អ្នកនិពន្ធ, មនោគតិរបស់អ្នកនិពន្ធ ឬ សតិសម្បជញ្ញៈរបស់អ្នកនិពន្ធរៀងខ្លួននោះឯង ។ បានន័យថា៖ ប្រសិនជាអ្នកនិពន្ធនោះមានសតិសម្បជញ្ញៈទូលាយ មានគំនិតល្អូតលាស់ច្រើន ស្នាដៃក៏បានល្អប្រសើរទៅ ; ផ្ទុយទៅវិញ បើអ្នកនិពន្ធរវើរវាយ ជាអ្នកខ្វះការពិចារណាឲ្យដិតដល់ ស្នាដៃនោះក៏អន់ខ្សោយទៅតាមនោះដែរ ។

បញ្ហាដូចពោល មកខាងលើនេះ ជាបញ្ហាមួយធំណាស់ដែរ ត្រូវតែអ្នកនិពន្ធគ្រប់រូប លើកយកមកពិភាក្សាក្នុងស្មារតីរបស់ខ្លួនឲ្យល្អិតល្អន់ណាស់មុននឹងសរសេររឿងនិមួយៗ ។ ព្រោះរឿងជាស្នាដៃរបស់យើងនោះ ក៏នៅគង់វង្សជាយូរអង្វែងណាស់ ហើយក៏ជាទ្រព្យរបស់ជាតិពិតៗផង បើយើងកសាងបានល្អ ទ្រព្យនេះក៏បាននៅល្អរហូតអនាគតជាយូរដែរ

តែបើប្រហែសប្រហានវិញ រូបកន៍ទ្រព្យមតិកនេះពុំបានល្អ គត់មត់ទុកឲ្យអនុជនជាន់ក្រោយ ៗ ទៀតទេ ។

ប្រសិនជាយើងធ្វើការសង្កេតតាមពេលតាមវេលាវិញ, យើងគាបវែកញែកសម័យបច្ចុប្បន្ននេះ ជាបីពេលបណ្ដាះអា-សន្នសិន ដើម្បីងាយធ្វើការសិក្សាសង្កេតតាមជាន់អក្ស-សាស្ត្រយើង គឺ ៖

ផ្នែកទីមួយ.- ចាប់តាំងពី គ.ស.១៩៤៩ រហូតមកដល់ ១៩៥១ : កាលនោះ ការបោះពុម្ពផ្សាយនៅមានដំណើរយឺតណាស់ ៗ មានតែសារពត៌មានប៉ុណ្ណោះទេដែលចេញបានច្រើន ទីងសៀវភៅធម៌អាថ៌ក៏បានចំរើនបន្តៗ មកដែរ ឯរឿងប្រលោមលោកដែលមានលក្ខណៈអក្សរសាស្ត្រច្រើនជាងផ្នែកឯទៀតនោះ ពុំសូវមានចេញញឹកញាប់ទេ ៗ តែបើចេញបានមួយៗ វិញ យើងឃើញមានខ្លឹមសារគ្រាន់បើខាងគោលគំនិត ខាងចំរង់សេចក្ដីល្អឲ្យមានសង្ឃឹមថា នៅក្រោយទៀតមុខជាមានល្អតណាស់យ៉ាងសំខាន់ពិតប្រាកដ ៗ

ស្នាដៃដ៏ខាន់នោះ  អ្នកនិពន្ធតែងប្រើពេលវេលាយ៉ាងច្រើន ដើម្បីកសាងស្នាដៃខ្លួន  ឲ្យបានជាទីគប់គានរបស់ជនទូទៅ ហើយអ្នកនិពន្ធដ៏ខាន់នោះ  សុទ្ធតែជាអ្នកចិញ្ចឹមចិត្តខាង អក្សរសាស្ត្រយូរឆ្នាំមកហើយ  ទើបចាំតែពេលវេលាល្អនឹង ចេញផ្សាយស្នាដៃរបស់ខ្លួនបង្ហាញចំពោះសាធារណជន ។

មានរឿងខ្លះទៀតដែលបានសរសេរពីគ្រាមុនមកស្រាប់ក៏ មិនបានបញ្ចេញរូបរាងបង្ហាញដល់សាធារណជនឃើញដែរដូចជា៖

- រឿង «គុណឈិន» របស់លោក នូ-កន,
- — «វណ្ណៈ» — លោក ដៃ្យ-ជុំ,
- — «គូសាងមិត្តមិនទ្រុស្តមិត្ត» របស់អ្នកស្រី សិទ្ធ,
- — «ផ្កាស្រពោន» របស់លោក នូ-ហាច,
- — «ចិត្តឪពុក» របស់លោក ហែល-សុំផា,
- — «ស្ត្រីកំព្រា» របស់លោក រិម-គិន,

- រឿង «កសនាវៃនទានណាគ្រី» របស់អ្នកស្រី ស៊ុយ-ហៀង
- « ផ្ការីកផ្កាពោយ » របស់លោក អៀង-សាយ

។ល។ ...

ក្រៅពីនេះ យើងឃើញមានកំណាព្យចងក្រងតាមបែបទំនើបខ្លះទៀត ដូចជា ៖

- « ប្រជុំរឿងល្បើក » របស់ លោក ហេង - យ៉ាន់,
- « រឿងល្បើក » លោក ឌុច - ស៊ីឌិម,
- « បិត្តក្រមុំ » – លោក កេង-វ៉ាន់សាក់,
- « ព្រះបាទជ័យវរ្ម័នទី ៧ » របស់លោក មៀវ-នន្ទ,
- « សកុន្តលា » (រឿងប្រែ) របស់លោក ក៉យ-ប៊ុក,
- « មេម៉ាយមាំមួន » របស់លោក ថាច - ឈួន

។ល។ ...



ផ្នែកទីពីរ.– ចាប់តាំងពី គ.ស.១៩៥២ ដល់មក ១៩៥៦, ជាសម័យមួយដែលអក្សរសាស្ត្រយើងផុះឡើង តាមផាកប្រលោមលោក, ទស្សនាវដ្ដី, រឿងល្ខោន ឬ សៀវភៅនិយាយពីទ្រឹស្ដីផ្សេង ៗ ។ អ្នកនិពន្ធជាច្រើនឈ្មោះ បានខំប្រឡងប្រជែងស្នាដៃគ្នា បោះពុម្ពផ្សាយពាសពេញ តាមស្រុកភូមិជិតឆ្ងាយ ហើយស្នាដៃទាំងនោះ ក៏ឃើញថា មានសារៈគួរឲ្យចាប់ចិត្តណាស់ដែរ ទាំងខាងផ្នែកសីលធម៌, ទាំងផ្នែកអក្សរសាស្ត្រ ។ មធ្យោបាយបោះពុម្ពផ្សាយ ក៏បានស្រួលលើសពេលមុន ៗ ច្រើនណាស់ ព្រោះពិភពលោកបានជួបនឹងសេចក្ដីសុខបរិបូណ៌ ។ ទំនិញសព្វសារពើ បានហូរចូលមកកាន់ស្រុកយើងបានស្រួល លើសពេលមុន ៗ ។ អ្នកនិពន្ធជាច្រើនរូបស្ទើរតែរាប់ឈ្មោះមិនអស់ បានខំប្រឡូកប្រជែងគ្នា ចេញផ្សាយនូវស្នាដៃរបស់ខ្លួន បង្ហាញដល់សាធារណជន ។ ឯស្នាដៃទាំងនោះសោតយើង ឃើញមានការរចនាសមរម្យគ្រាន់បើដែរ ទាំងទំនងផែនរឿង,

ទាំងពាក្យពេចន៍ធ្ងើយថ្មីជាដើម ៗ អ្នកអានគ្រប់គ្នាបានយកចិត្តទុកដាក់ ពិនិត្យសង្កេតនូវកម្រងរបស់អ្នកនិពន្ធជាតិខ្លួនយ៉ាងយកចិត្តទុកដាក់បំផុត ហាក់ដូចជាចង់ធ្វើការវិនិច្ឆ័យលើស្នាដៃទាំងនោះ ៗ ហេតុនេះឯង ទើបអ្នកនិពន្ធប្រឹងដុះខាត់សិល្បៈរបស់ខ្លួន ឲ្យកាន់តែមានទឹកដមសម្រាប់ឲ្យអ្នកអានបានទទួលរសជាតិឆ្ងាញ់ពិសាតទៅទៀត ៗ ប៉ុន្តែសម័យនេះ បណ្ណាគារ ដែលជាផ្សារសម្រាប់លក់ផ្សាយសៀវភៅមិនទាន់មានច្រើនគ្រប់គ្រាន់នៅឡើយទេ ព្រោះគេទុករបរនេះថាជាពុំទាន់មាំទាំនៅឡើយ ៗ រោងពុម្ពដែលជាឫសគល់នៃការផ្សាយនេះ ក៏ពុំទាន់សម្បូណ៌ហូរហៀរនៅឡើយដែរ ៗ ដូច្នេះឯងហើយ ទើបសៀវភៅយើងដែលចេញផ្សាយបានមួយ ៗ ក្នុងគ្រានោះមាន តម្លៃថ្លៃថ្នូរទាំងផ្នែកសីលធម៌ និងទាំងផ្នែកសម្ភារៈ ៗ គ្រានេះមានទស្សនាវដ្ដីខ្លះចេញផ្សាយដូចយ៉ាងទស្សនាវដ្ដីនារី, ទស្សនាវដ្ដីសុបិននិមិត្ត, ទស្សនាវដ្ដីពត្រីថ្ងៃសៅរ៍, ទស្សនាវដ្ដីមិត្តសាលាបាលី ៗលៗ ដែលយើង

អាចសំគាល់បានថា ទស្សនាវដ្ដីទាំងនេះមានប្រយោជន៍ផ្សាយការចេះដឹងដល់សាធារណជនផង នឹងជាទីប្រជុំហាត់ហ្វឹកហ្វឺនអ្នកនិពន្ធថ្មីៗទៀតផង ។ ដូចយើងពោលហើយខាងលើ សម័យនេះមានប្រលោមលោកចេញផ្សាយច្រើនណាស់ដែរ តែយើងសូមចង្អុលឈ្មោះខ្លះៗ គ្រាន់ជាសក្ខីភាព គឺ៖

រឿង « ចោរបិទមុខ » របស់លោក ហែល - សុំផា,

– « ព្រួញមាស » – ទុ - ជូ,

– « មើលព្រះចន្ទ្រា » – រីម - គិន,

– « ស៊ើបិត្ត, សេរីស្វតបុត្រ, រំដួលកំគូលែន »

របស់ ល៊ី - ធាមតេង,

– « ខេមរកុលបុត្រ, ទុយ៉ិសសង្ស័ក » របស់ ម៉ា - ឡាយខេម,

– « ព្រះខ័នរាជ្យ, វីរបុរស, ព្រះបន្ទូលជា, ... »

របស់ ប៊ិវ - ឆៃលាង,

– « ទៅនិស្សានទុគ៌ត » របស់ អ្នកនិពន្ធ ស្រី - ម្លុប,

– « បន្ទាយលង្វែក » – – រ. គោវិទ ៗល ៗ

មានការវិវត្តន៍មួយទៀត ដែលគួរកត់សំគាល់ក្នុងប្រវត្តិអក្សរសាស្ត្រយើងថា៖ គឺនៅ គ.ស.១៩៤៦ នេះហើយដែលអ្នកនិពន្ធនិងកវីដែលមានឧត្តមគតិប្រពៃៗ បានរួបរួមគ្នាបង្កើតជា សមាគមអ្នកនិពន្ធខ្មែរ សំរាប់ជួយឧបត្ថម្ភដល់ការផ្សាយអក្សរសាស្ត្រទាំងក្នុងប្រទេស, ទាំងក្រៅប្រទេស ដើម្បីឲ្យបានសមនឹងឋានៈប្រទេសឯករាជ្យសម្បូណ៌ ។ ព្រះរាជក្រមលេខ ៦១ ន.ស. ចុះថ្ងៃ១មករា គ.ស.១៩៤៦ ក៏បានបើកសិទ្ធិដល់អ្នកនិពន្ធយ៉ាងបរិបូណ៌ឡើងថែមទៀតនៅគ្រានោះដែរ ។

ផ្នែកទី៣ - ចាប់តាំងពី គ.ស.១៩៤៧ រហូតដល់សព្វថ្ងៃនេះ របៀបសរសេរមានការប្រួលផ្លាស់សឹងតែតាមជាន់ពុំទាន់ៗ អ្នកនិពន្ធពីឆ្នាំមុនៗ បាត់រូបលែងឃើញមានសរសេរឲ្យញឹកញាប់ទៀតហើយ ។ អ្នកនិពន្ធថ្មីៗ បានលេចមុខឡើងដូចផ្សិតនៅរដូវភ្លៀងធ្លាក់ជាដំបូង គេខំប្រណាំងប្រជែងស្នាដៃគ្នាដែលមានចេញផ្សាយជាញឹកញាប់ក្រៃលែង ហើយស្នាដៃទាំងនោះច្រើនតែខ្វះៗ ពុំសូវមាននិក្ខេបបទ (thèse)

អ្វីក្រើមត្រូវទេ ។ ចំពោះរបៀបរៀបចំសាច់រឿងវិញ គេក៏មិន សូវប្រឹតប្រៀនដូចគ្រាមុនៗដែរ ទោះខានអត្ថរសក្តិ, ខានទំរង់ សេចក្តីក្តី ។ មូលហេតុទាំងនេះឯង បាននាំវាសនាអក្សរ-សាស្ត្រយើងឲ្យជួបប្រទះនឹងការរអាក់រអួលមួយគ្រាដែរ ដ្បិត ជួនកាលទៀត ស្នាដៃទាំងនេះ មានពោរពេញទៅដោយរឿង រ៉ាវដែលពិបាកនឹងអានថែមទៀតផង ចំពោះចរិយា ឬ ប្រពៃណី របស់ខ្មែរយើង ។ សម័យនេះ បង្កើតជាបញ្ហាយ៉ាងច្រើនលើ ផ្នែកអក្សរសាស្ត្រខ្មែរ ព្រោះជនអ្នកស្នេហាអក្សរសាស្ត្រម្នាក់ៗ សុទ្ធតែមានការត្រិះរិះ នឹង ការយល់ឃើញប្លែកៗ ពីគ្នា ហើយស្នាដៃទាំងនេះ ស្ទើរជាស្នាដៃបច្ចេកទេស ឬ ស្នាដៃធម្ម-ត. មិនអាចវែកញែកបាន ព្រោះអ្នកនិពន្ធបានកាឡៃបញ្ចូល បែបទាំងពីរធ្វើជារឿងមួយ ។ ម្ល៉ោះហើយ រឿងរ៉ាវ ទាំងនោះពុំបានជាក់លាក់សំរាប់អ្នកអានទេ បានសេចក្តីថា គ្រាន់តែនាំសតិអារម្មណ៍អ្នកអានឲ្យអណ្តែតអណ្តូង ទៅតាម ចំណង់តណ្ហា ឬ មនោសញ្ចេតនាវើរវាយប៉ុណ្ណោះ ។

តែទោះបីយ៉ាងហ្នឹងក៏ដោយ យើងគួរយល់ថា ធម្មតាការ
កសាងជាដំបូង ទោះការកសាងអ្វីក៏ដោយ រមែងតែងជួបប្រទះ
នឹងការខ្វះខាតជាមិនខាន ។ ដូចនេះ យើងគិតយ៉ាងណា
ឲ្យតែបានចំរើនសិនចុះ ចាំដល់ថ្ងៃក្រោយទៅសឹមយើងនាំ
គ្នាស៊ំរិតស៊ំរាំងទៅទៀត ។ ដោយឃើញថាអក្សរសាស្ត្រ
យើងត្រូវលាយប្រចល់ដោយគោលគំនិត ពីបរទេសដូចនេះ
ហើយ អ្នកនិពន្ធដែលមានឧត្តមគតិសុទ្ធសាធក្នុងការកសាង
ភាសនាអក្សរសាស្ត្រជាតិខ្លួន នាំគ្នាក្រោកឈររួមកំឡាំងជា
មួយអង្គការអប់រំផ្សេងៗទៀត ប្រឆាំងនឹងចលនាអក្សរសាស្ត្រ
ក្លែងថ្មី នាំឲ្យខូចដល់ខ្សែជាតិនេះ, ទាល់តែបានជោគជ័យ ។
គឺពួករឿងអាសគ្រាម និងរូបអាក្រាតកាយ ក៏បានបាត់ស្រ-
មោលពីលើទីកខ្មែរតាំងលក់នានាអស់គ្មានសល់ ។

ព្រឹត្តិការណ៍ចំឡែកមួយទៀតនៅក្នុង គ.ស. ១៩៥៧
នោះ រាជរដ្ឋាភិបាលបានកែប្រែកម្មវិធីសិក្សានៅមធ្យមក្ប
បញ្ចូលឲ្យមានការសិក្សាអក្សរសាស្ត្រជាតិ យ៉ាងច្រើនទៅ

ក្នុងវិស័យសិក្សាគ្រប់ជាន់ថ្នាក់ ដើម្បីឲ្យកុលបុត្រ-កុលធីតាយើងបានក្រេបជញ្ជាក់ច្បាស់លាស់នូវរសជាតិវប្បធម៌ជាតិខ្លួន ។ ដូចនេះសៀវភៅទាំងឡាយដែលណែនាំខាងការសិក្សា, ជាជំនួយសាកក្នុងកិច្ចសិក្សា ក៏បានចេញផ្សាយជាច្រើនឈ្មោះបណ្ដុះនូវគំនិតស្រាវជ្រាវរកតម្លៃវប្បធម៌ជាតិកាន់តែខ្លាំងឡើង ៗ ។

នៅឆ្នាំ ១៩៥៨ នេះ អក្សរសាស្ត្រយើងបានលេចមុខលេចមាត់យ៉ាងត្រចះត្រចង់នៅលើឆាកអន្តរជាតិ ដោយកាលនោះរាជរដ្ឋាភិបាលយើងបានបញ្ជូនអ្នកនិពន្ធខ្មែរ (១) ឲ្យទៅរួមសន្និសីទខាងអក្សរសាស្ត្ររវាងអ្នកនិពន្ធជនជាតិអាស៊ី និង អាហ្វ្រិកនៅក្រុងតាស្កេន (សហភាពសូវៀត) ។

អក្សរសាស្ត្រយើងបានចំរើនក្នុងស្រុកទៀត ដោយមានការផ្សាយតាមវិទ្យុ និងការធ្វើបាឋកថាតាមទីជនបទ ឬ ទីប្រជុំនៃការអប់រំផ្សេង ៗ ។ ក្រៅពីនេះ នៅមានការផ្សាយមួយទៀតយ៉ាងសំខាន់គឺនៅក្នុងទំព័រសារពត៌មានអ្នកជាតិនិយម ។

---

១– ប្រតិភូដែលបានទៅកាលគ្រានោះគឺ អ្នកនិពន្ធ ម៉ា-ឡាយខេម និង លី-ធាមតេង ដែលអ្នកនិពន្ធក្នុងសមាគមបានបោះឆ្នោតជ្រើសរើស ។

ការសិក្សាពីអក្សរសាស្ត្ររបស់យើង សុំផ្អួបត្រឹមនេះ ហើយយើងសង្ឃឹមថា នៅពេលក្រោយដែលយើងធ្វើការស្រាវជ្រាវ និង សិក្សាបានវែងឆ្ងាយទៅទៀត យើងនឹងបន្ថែមឲ្យកាន់តែបានពិស្តារឡើងជាលំដាប់ ។ តែមុននឹងបញ្ចប់យើងត្រូវចងចាំថា មូលហេតុដែលនាំឲ្យចំរើនបានហូរហៀមកក្ន សម័យបច្ចុប្បន្ននេះ អាស្រ័យដោយមានសេចក្តីឧបត្ថម្ភយ៉ាងហ្មឹងហ្មាត់របស់ព្រះអគ្គមគ្គុទ្ទេសក៍ និង ជាព្រះបិតាឯករាជ្យជាតិ គឺសម្តេចព្រះ នរោត្តម-សីហនុ ដែលព្រះអង្គទ្រង់ពុំដែលភ្លេចម្តងណាទេ ចំពោះការស្តាបនាវប្បធម៌ជាតិ ឲ្យរើករើតតែវិសេសវិសាលឡើងសមនឹងឋានៈប្រទេស ដែលទ្រង់បានដឹកនាំឲ្យចំរើនគ្មានឈប់ឈរ ។ ជាកស្តុតាងគឺព្រះអង្គសព្វព្រះទ័យទ្រង់នូវព្រះឋានៈជា ប្រធានកិត្តិយស នៃសមាគមអ្នកនិពន្ធខ្មែរដែលជានិមិត្តរូបនៃអក្សរសាស្ត្រនិងវប្បធម៌ជាតិ ។

